00788513

E1/46.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Mar-2012, 15:06
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៩ នាទី**

**សវនាការលើកទី៣៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ច័ន្ទ តារាស្មី

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី ស៊ីន សុវ៉ន

លោក វ៉េន ពៅ

លោកស្រី ទ្រី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនួហ្ស៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលលើអង្គសេចក្តីនៅសំណុំរឿងលេខ០០២/០១។ នៅថ្ងៃនេះដែរ អង្គជំនុំជម្រះចាប់ផ្តើមដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល លើអង្គហេតុទាំងឡាយសម្រាប់វគ្គពីរ នៃសំណុំរឿង០០២/០១ ដែលពាក់ព័ន្ធទៅនឹងបរិបទរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងាររបស់កម្ពុជាប្រជាធិបតេយ្យ និងអង្គហេតុនៅក្នុងកថាខណ្ឌខ្លះ ស្តីពីតួនាទីមុខងាររបស់ជនជាប់ចោទ ដែលមានភាពពាក់ព័ន្ធជិតស្និទ្ធទៅនឹងអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ។

[០៩:១១:១៦]

អង្គជំនុំជម្រះនឹងចាត់តាំងក្រឡាបញ្ជីសវនាការចំនួនបីរូប ឲ្យឡើងអានទូវបណ្តាកថាខណ្ឌទាំងឡាយនៅក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងបរិបទខាងលើនេះជាមុន មុននឹងចាប់ផ្តើមពិភាក្សាដោយការលើកឡើងនូវការជំទាស់នឹងឯកសារ ដែលបានស្នើសុំដាក់ដោយភាគីនៃរឿងក្តី។

អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីផងដែរថា នៅក្នុងកិច្ចដំណើរការសវនាការនៅសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើសវនាការ ដើម្បីស្តាប់ចម្លើយជនជាប់ចោទ ឬស្តាប់សក្ខីកម្មសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញណាម្នាក់ឡើយ ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់ជូននៅក្នុងអនុស្សរណៈរបស់ខ្លួន ឯកសារ E172/5 រួចហើយ។ សប្តាហ៍នេះ សម្រាប់សវនាការលើការជំទាស់របស់ភាគីនៃរឿងក្តី ពាក់ព័ន្ធនឹងឯកសារជាក់លាក់មួយចំនួនដែលភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:១២:២៥]

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី ដែលត្រូវបានអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! ស្ថានភាពវត្តមាន និងអវត្តមានរបស់ភាគីក្នុងសវនាការថ្ងៃនេះ មានដូចខាងក្រោម៖

ការិយាល័យសហព្រះរាជអាជ្ញា មានវត្តមានគ្រប់ចំនួន។

ក្រុមមេធាវីការពារក្តី អៀង សារី មានវត្តមានគ្រប់ចំនួន។

ក្រុមមេធាវីការពារក្តី ខៀវ សំផន មានវត្តមាន តែមេធាវីជាតិ។

ក្រុមមេធាវីការពារក្តី នួន ជា មានវត្តមានគ្រប់ចំនួន។

ជនជាប់ចោទទាំងបីរូប លោក អៀង សារី, ខៀវ សំផន, និង នួន ជា មានវត្តមាន។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានវត្តមានគ្រប់ចំនួន។

សូមអរគុណលោកប្រធាន។

[០៩:១៣:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក។

ជាកិច្ចបន្ត ដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់អំពីអង្គហេតុដែលចោទប្រកាន់ទៅលើជនជាប់ចោទទាំងបីរូបដែលស្ថិតនៅក្នុងវិសាលភាព នៃដំណើរការសវនាការពិភាក្សាដេញដោលសម្រាប់វគ្គពីរ នៃសំណុំរឿង០០២/០១ គឺអង្គហេតុដែលបានកំណត់សម្រាប់ធ្វើសវនាការនៅដំណាក់កាលដំបូង និងជាការអនុវត្តអនុលោកតាមវិធាន៨៩ស្ទួន កថាខណ្ឌមួយ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូងចាត់ក្រឡាបញ្ជី ដែលជាក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង គឺ ១) លោកស្រី សែ កុលវឌ្ឍី, ២) លោក ឌុច ផារី, ៣) លោក ដាវ អានសាន ឡើងអាននូវបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទទាំងបីរូប ដែលមានចែងនៅក្នុងដីកាដំណោះស្រាយនូវបណ្តាកថាខណ្ឌនានាដែលពាក់ព័ន្ធនឹងអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ប្រព័ន្ធទំនាក់ទំនងការងារកម្ពុជាប្រជាធិបតេយ្យ និងកថាខណ្ឌខ្លះ ដែលស្តីពីតួនាទី និងមុខងាររបស់ជនជាប់ចោទ ដែលពាក់ព័ន្ធជិតស្និទ្ធទៅនឹងអង្គហេតុ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ។

[០៩:១៥:០៦]

ដូចដែលមានបញ្ជាក់នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ

២០១១ ឯកសារ E155 Correct-1 ហើយនិងអនុស្សរណៈ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ E172។ ហើយសូមជម្រាបក្រឡាបញ្ជីផងដែរ ក្រឡាបញ្ជីម្នាក់ៗត្រូវអាននូវកថាខណ្ឌ ដែលយើងខ្ញុំបានកំណត់ចែកជូនរួចហើយ។

ជាបន្តនេះ សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងអាននូវផ្នែកដែលកថាខណ្ឌ ដែលបានចែកជូនលោកស្រី។

[០៩:១៥:៤៩]

**ក្រឡាបញ្ជី៖**

**ផ្នែកទីពីរ រចនាសម្ព័ន្ធរដ្ឋបាលមជ្ឈិម៖**

ក) បក្សកុម្មុយនីស្តកម្ពុជា

កថាខណ្ឌ៣៣៖ មកទល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគ្រប់គ្រងដោយលក្ខន្តិកៈ ដែលដំបូងឡើយត្រូវបានអនុម័តក្នុងឱកាសសមាជលើកទី១ របស់បក្ស នៅខែកញ្ញា ឆ្នាំ១៩៦០។ លក្ខន្តិកៈថ្មីនៃបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានអនុម័តដោយសមាជបក្សលើកទី៤ នៅក្នុងខែមករា ឆ្នាំ១៩៧៦។ លក្ខន្តិកៈថ្មីនេះ បានរៀបរាប់អំពីមនោគមន៍វិជ្ជា លក្ខខណ្ឌនៃការចូលជាសមាជិក រចនាសម្ព័ន្ធ និងអង្គការចាត់តាំងនៃបក្សកុម្មុយនីស្តកម្ពុជា និងមានចែងផងដែរ អំពីស្ថាប័នរដ្ឋមួយចំនួនដូចជា កងទ័ពបដិវត្តន៍កម្ពុជា ប្រព័ន្ធគណៈកម្មាធិការបក្សថ្នាក់ជាតិ គណៈមជ្ឈិមបក្ស រួមទាំងមន្ទីរ និងក្រសួងផ្សេងៗជុំវិញគណៈមជ្ឈិម។ បក្សត្រូវបានគ្រប់គ្រងដោយគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ នៃគណៈមជ្ឈិម។

កថាខណ្ឌ៣៤៖ លក្ខន្តិកៈនេះ ក៏បានគូសបញ្ជាក់ទៀតថា បក្សកុម្មុយនីស្តកម្ពុជា ត្រូវដើរតាមប្រព័ន្ធរបបដឹកនាំសមូហភាពដែលផ្អែកលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ នៅពេលគេយកគោលការណ៍នេះមកអនុវត្តចំពោះប្រព័ន្ធគណៈកម្មាធិការនេះ មានន័យថា សមាជិកត្រូវធ្វើសេចក្តីសម្រេចរួមជាមួយសមាជិកមួយផ្សេងទៀត និងពុំអាចសម្រេចជាលក្ខណៈបុគ្គលបានឡើយ ដោយបញ្ជាក់ថា សមាជិកត្រូវបានចាត់ឲ្យទទួលខុសត្រូវ តាមផ្នែកជាក់លាក់តាមការកំណត់។ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ មានសរសេរថា “តាំងពីទូរលេខឡើងទៅ ពេលទទួលបានភ្លាម មន្ទីរត្រូវប្រគល់ឲ្យផ្នែកទទួលខុសត្រូវភ្លាម ឲ្យគេពិនិត្យពិចារណា ហើយស្នើអចិន្ត្រៃយ៍បញ្ជាខ្លះ”។

[០៩:១៧:៤៨]

កថាខណ្ឌ៣៥៖ គណៈមជ្ឈិមក៏ដូចជាគណៈអចិន្ត្រៃយ៍ មានសមាសភាពសមាជិកពេញសិទ្ធិ និងសមាជិកត្រៀម ឬសមាជិកបម្រុង។ សមាជិកត្រៀម មានឋានៈទាបជាងសមាជិកពេញសិទ្ធិ។ សមាជិកពេញសិទ្ធិមានសិទ្ធិពិគ្រោះពិភាក្សានិងរួមមតិសម្រេចក្នុងគ្រប់វិស័យទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ស្ថាប័ននេះ។ ចំណែកឯសមាជិកត្រៀម ត្រូវបានអនុញ្ញាតឲ្យចូលរួមប្រជុំតែប៉ុណ្ណោះ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតសម្រេចនោះទេ។ នៅថ្នាក់គណៈមជ្ឈិម អ្នកដែលមិនមែនជាសមាជិកពេញសិទ្ធិ ពុំមានអំណាចលើការសម្រេចលើការកម្ទេចនរណាម្នាក់នោះទេ។ យោងតាមសក្ខីកម្មរបស់ ឌុច មានតែសមាជិកគណៈគណៈមជ្ឈិមប៉ុន្មាននាក់ប៉ុណ្ណោះ ដែលមានជាផ្លូវការនូវអំណាចមួយនេះ។ ជំនួយការរបស់គណៈមជ្ឈិមដែលទោះបីជាមានឋានៈជាសមាជិកក៏ដោយ ក៏នៅលើទិដ្ឋភាពមួយចំនួន ពួកគេមានឋានៈមួយដែលស្រដៀងគ្នាទៅនឹងសមាជិកផងដែរ ព្រោះពួកគេត្រូវបានអនុញ្ញាតឲ្យចូលរួមជាមួយសមាជិកពេញសិទ្ធិ និងសមាជិកត្រៀមក្នុងវគ្គបណ្តុះបណ្តាលនយោបាយ ដែលត្រូវបានរៀបចំសម្រាប់ថ្នាក់មជ្ឈិមបក្ស។

[០៩:១៨:៥៧]

កថាខណ្ឌ៣៦៖ យោងតាមការបង្ហាញជាផ្លូវការ ស្ថាប័នផ្សេងៗទៀត ដែលចំណុះឲ្យបក្សមានដូចជា សភាតំណាងប្រជាជន ដែលគេបាននិយាយថាត្រូវបានបោះឆ្នោតជ្រើសរើស នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ សូមមើលផ្នែកនៃដីកាដំណោះស្រាយដែលនិយាយអំពីតួនាទីនិងមុខងាររបស់ នួន ជា។ គណៈប្រធានរដ្ឋ សូមមើលផ្នែកនៃដីកាដំណោះស្រាយ ដែលនិយាយអំពីតួនាទីនិងមុខងាររបស់ ខៀវ សំផន ព្រមទាំងគណៈចាត់តាំងនៃគណៈមជ្ឈិមបក្ស ដែលដឹកនាំដោយ នួន ជា ដែលត្រូវបានប្រគល់សិទ្ធិក្នុងការតាមដាននិងត្រួតពិនិត្យសមាជិកបក្ស និងចាត់ចែងការបញ្ជូលពួកគេទៅតាមមន្ទីរនិងក្រសួងនានា។

[០៩:១៩:៤១]

ខ) គណៈកម្មាធិការមជ្ឈិម

កថាខណ្ឌ៣៧៖ អនុលោមតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គណៈកម្មាធិការមជ្ឈិមមានតួនាទីក្នុងការអនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខន្តិកៈរបស់បក្ស នៅក្នុងបក្សទាំងមូល ព្រមទាំងណែនាំអង្គការភូមិភាគតំបន់ ក៏ដូចជាគ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល។

កថាខណ្ឌ៣៨៖ សមាជិកគណៈមជ្ឈិមរួមមាន ប៉ុល ពត ដែលនៅក្នុងប្រព័ន្ធផ្សព្វផ្សាយផ្លូវការត្រូវបានគេស្គាល់ថា ជាលេខាគណៈមជ្ឈិម។ នួន ជា អនុលេខាគណៈមជ្ឈិម, អៀង សារី, ខៀវ សំផន, កុយ ធួន ក្រោយមកត្រូវបានចាប់ខ្លួននិងសម្លាប់, តាម៉ុក, ណៃ សារ៉ាន់ ហៅ យ៉ា ក្រោយមកត្រូវបានចាប់ខ្លួននិងសម្លាប់, សឿង និង កែ ពក។ លើសពីនេះ សៀ វ៉ាស៊ី ហៅ ឌឿន ដែលជាប្រធានមន្ទីរនយោបាយ៨៧០ ក្រោយមកត្រូវបានចាប់ខ្លួននិងសម្លាប់ ក៏ជាសមាជិកមួយរូបនៃគណៈមជ្ឈិមផងដែរ។ ឈឹម សំអោក ហៅ ប៉ង់ ពេលខ្លះត្រូវបានចាត់ទុកថា ជាសមាជិកនៃគណៈមជ្ឈិម ឯពេលខ្លះទៀតជាជំនួយការនៃគណៈកម្មាធិការនេះ។ ជាងនេះទៀត លេខាភូមិភាគដទៃទៀត និងយ៉ាងហោចណាស់ លេខាតំបន់មួយចំនួនក៏ជាសមាជិកគណៈមជ្ឈិមផងដែរ ហើយកម្មាភិបាលយោធាមួយចំនួនក៏ជាសមាជិកផងដែរ។ សាក្សីមួយចំនួន ក៏បានបញ្ជាក់ដែរថា អៀង ធីរិទ្ធ បានចូលប្រជុំគណៈមជ្ឈិមផងដែរ។

[០៩:២១:១៩]

កថាខណ្ឌ៣៩៖ បន្ថែមលើនេះ នៅក្នុងគណៈមជ្ឈិម ក៏មានគណៈយោធាពិសេសមួយ ឬគណៈយោធាជាន់ខ្ពស់ ដែលសមាសភាពដើមដំបូងមានដូចជា ប៉ុល ពត, នួន ជា, សុន សេន, សោ ភឹម និង តាម៉ុក ហើយ វន វ៉េត និង កែ ពក បានក្លាយជាសមាជិគណៈយោធានៅពេលក្រោយមក។ ឌុច បានអះអាងថា លោក សំ ប៊ិត និង សឿង ដែលភ្ជាប់ទៅនឹងគណៈមជ្ឈិមផងដែរនោះ គឺជាជំនួយការដែលទទួលខុសត្រូវផ្នែកយោធា។ ជួនកាល គណៈមជ្ឈិម និងគណៈយោធាធ្វើការជួបប្រជុំរួមគ្នា ដើម្បីពិភាក្សាអំពីបញ្ហាយោធា។ កងទ័ពបដិវត្តន៍កម្ពុជា និងអង្គភាពយោធាមូលដ្ឋានទាំងអស់ត្រូវស្ថិតនៅក្រោមចំណុះរបស់គណៈយោធានិងគណៈមជ្ឈិម។ កងទ័ពត្រូវបានទស្សនាវដ្តីទង់បដិវត្តមួយលេខចុះផ្សាយថា ជាឧបករណ៍ផ្តាច់ការរបស់បក្សដ៏បរិសុទ្ធ។

កថាខណ្ឌ៤០៖ ជារួមទោះបីជាចំនួនសមាជិកភាពមានការប្រែប្រួលក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យក្តី ក៏គណៈមជ្ឈិមមានសមាជិកលើសពី៣០រូប ដែលយោងតាមលក្ខន្តិកៈ ពួក បក្សពួកគេមានកាតព្វកិច្ចដឹកនាំការអនុវត្តដោយខ្ជាប់ខ្ជួននូវគោលនយោបាយបក្សនៅក្នុងសង្គមគ្រប់ជាន់ថ្នាក់និងធ្វើការផ្សព្វផ្សាយអំពីនយោបាយទាំងនេះទៅតាមលំដាប់ឋានានុក្រម។ អនុលោមតាមលក្ខន្តិកៈនេះដដែល ពួកគេជួបប្រជុំគ្នាប្រហែលជារៀងរាល់៦ខែ។

[០៩:២២:៥០]

គ) គណៈកម្មាធិការអចិន្ត្រៃយ៍

កថាខណ្ឌ៤១៖ គណៈអចិន្ត្រៃយ៍គឺជាអង្គការមួយដែលមានសមាជិកតិចជាងគណៈកម្មាធិការមជ្ឈិម។ អង្គការនេះមានសមាសភាពដែលសុទ្ធតែជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា។ យោងតាមការអះអាងរបស់ ខៀវ សំផន បើទោះបីជាយោងតាមលក្ខន្តិកៈជាគោលការណ៍ គណៈមជ្ឈិមមានអំណាចសម្រេចធំបំផុតក្តី ក៏ជាក់ស្តែងអំណាចនេះត្រូវបានអនុវត្តន៍ដោយគណៈអចិន្ត្រៃយ៍ ដែលមានភារកិច្ចគ្រប់គ្រងការងារប្រចាំថ្ងៃ។ ឧត្តមានុភាពរបស់គណៈអចិន្ត្រៃយ៍ត្រូវបានបង្ហាញឡើងជាពិសេសតាមរយៈសិទ្ធិអំណាចរបស់អង្គការនេះ ក្នុងការបញ្ជាឲ្យមានការចាប់ខ្លួនសមាជិកគណៈមជ្ឈិម។

កថាខណ្ឌ៤២៖ នៅក្នុងការសួរយកចម្លើយមួយ ខៀវ សំផន បានបញ្ជាក់ថា ក្នុងនាមជាលេខាគណៈអចិន្ត្រៃយ៍ ប៉ុល ពត គឺជាអ្នកដែលមានអំណាចខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។ និយាយជាមួយ ប៉ុល ពត ក៏ដូចជានិយាយនៅក្នុងអង្គប្រជុំដែរ ពីព្រោះគាត់ជាលេខាបក្ស។ ខៀវ សំផន ក៏បានបន្ថែមទៀតថា ចំពោះការចេញសេចក្តីសម្រេច អ្វីៗត្រូវបានធ្វើនិងសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយគឺនាពេលបន្ទាប់មកប៉ុណ្ណោះ ដែលព័ត៌មានត្រូវបានផ្សព្វផ្សាយបន្តទៅគណៈកម្មាធិការមជ្ឈិមដែលនឹងណែនាំបន្តទៀតទៅមូលដ្ឋាន។

កថាខណ្ឌ៤៣៖ ឧត្តមានុភាពរបស់គណៈអចិន្ត្រៃយ៍ក៏ត្រូវបានបញ្ជាក់ផងដែរ ដោយ ឌុច ដែលបានអះអាងថា នួន ជា គឺជាមនុស្សទីពីរ បន្ទាប់ពី ប៉ុល ពត នៅក្នុងឋានានុក្រមគណៈអចិន្ត្រៃយ៍ ហើយបន្ទាប់មកគឺ អ៊ុង ជឿន ហៅ តាម៉ុក។ កំណត់ហេតុអង្គប្រជុំបង្ហាញថា នៅពេល ប៉ុល ពត អវត្តមាន នួន ជា ជាអធិបតីនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍។ សមាជិកផ្សេងទៀតនៃគណៈអចិន្ត្រៃយ៍រួមមាន សោ យ៉ាន់ ហៅ សោ ភឹម ដែលបានធ្វើអត្តឃាតនៅក្នុងឆ្នាំ១៩៧៨។ អៀង សារី, វន វេត ដែលក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់។ រស់ ញឹម ដែលក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់ និងសុន សេន។

[០៩:២៤:៥៨]

ក្នុងចំណោមសមាជិកទាំង៧រូបនេះ មានសមាជិកចំនួន៥រូប ដែលរស់នៅជាអចិន្ត្រៃយ៍នៅភ្នំពេញ មានដូចជា ប៉ុល ពត, នួន ជា, អៀង សារី, វន វេត និង សុន សេន រហូតដល់ ពេលគាត់ផ្លាស់ទៅភូមិភាគបូព៌ានៅខែសីហា ឆ្នាំ១៩៧៧ ដើម្បីពិនិត្យមើលជម្លោះជាមួយវៀតណាម។

កថាខណ្ឌ៤៤៖ ក្រៅពី ប៉ុល ពត សមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍មានដូចជា នួន ជា, តាម៉ុក និង អៀង សារី។ វន វេត និង សុន សេន ទំនងអាចជាសមាជិកពេញសិទ្ធិ ឬអាចជាសមាជិកត្រៀម។

កថាខណ្ឌ៤៥៖ ទោះជាមានភស្តុតាងបញ្ជាក់ច្បាស់ថា ខៀវ សំផន ពុំមែនជាសមាជិកផ្លូវការនៃគណៈអចិន្ត្រៃយ៍ក្នុងពេលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាចក្តី ក៏វាទំនងជាថា ខៀវ សំផន បានជួយឬចូលរួមចំណែកដល់ការងាររបស់គណៈអចិន្ត្រៃយ៍ ដូចដែលមានរៀបរាប់ក្នុងផ្នែកដែលនិយាយអំពី ខៀវ សំផន ក្នុងដីកាដំណោះស្រាយនេះ។

កថាខណ្ឌ៤៦៖ ក្នុងអង្គប្រជុំមួយនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បានប្រគល់ដល់កម្មាភិបាលជាន់ខ្ពស់បក្ស ដែលក្នុងចំណោមនោះក៏មានសមាជិកគណៈអចិន្ត្រៃយ៍ផងដែរ នូវការទទួលខុសត្រូវប្រតិបត្តិលើវិស័យផ្សេងៗក្នុងសកម្មភាពរបស់រដ្ឋាភិបាល ដូចជា យោធា សេដ្ឋកិច្ច សន្តិសុខ កិច្ចការបរទេសនិងសង្គមកិច្ច។ កម្មាភិបាលទាំងនោះត្រូវរាយការណ៍ជូនគណៈអចិន្ត្រៃយ៍ដែលជាស្ថាប័នមានអំណាចក្នុងការសម្រេច។ ដូច្នេះហើយ បានជានៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះមានសរសេរថា ក្នុងការលើកគម្រោងត្រូវសួរយោបល់អចិន្ត្រៃយ៍ដើម្បីសម្រេចនិងអនុម័ត។

កំណត់ហេតុអង្គប្រជុំដដែលនេះ ដែលមានបញ្ជាក់អំពីការតម្រូវឱ្យមានការរក្សាទុកនូវរាល់សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍បានសរសេរថា សំណូមពរសំខាន់ គឺកំណត់ហេតុត្រូវឱ្យច្បាស់សួរអីដឹងហ្នឹង ពីការសម្រេចរបស់មជ្ឈិម របស់អចិន្ត្រៃយ៍ ឯកសារប្រជុំមជ្ឈិមថ្ងៃណា ខែណា ត្រូវធ្វើយ៉ាងណាឱ្យច្បាស់។

[០៩:២៧:០៦]

កថាខណ្ឌ៤៧៖ គណៈអចិន្ត្រៃយ៍បានជួបប្រជុំគ្នាជាញឹកញាប់ ប្រហែលជារៀងរាល់ប្រាំពីរទៅដប់ថ្ងៃ បើយោងតាមការអះអាងរបស់ ខៀវ សំផន។ បន្ថែមពីលើនេះសាក្សីម្នាក់បញ្ជាក់ថា គណៈអចិន្ត្រៃយ៍នឹងកោះប្រជុំនៅពេលដែលមានកិច្ចការសំខាន់ណាមួយ ត្រូវពិភាក្សាដើម្បីសម្រេច។

ឃ)មន្ទីរ៨៧០

កថាខណ្ឌ៤៨៖ នៅថ្នាក់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អង្គភាពទាំងអស់ពាក់ព័ន្ធនឹងលេខ ៨៧០ ជាលេខកូដមួយដែលសំដៅទៅលើថ្នាក់ខ្ពស់បំផុតរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយនៅក្នុងករណីខ្លះគឺ ប៉ុល ពត តែម្តង។ ស្ថាប័នទាំងនោះបំពេញការងារពាក់ព័ន្ធ និងវិស័យនយោបាយ រដ្ឋបាល យោធា ទំនាក់ទំនង និងសន្តិសុខក្នុងនាមគណៈអចិន្ត្រៃយ៍ និងជួយគណៈអចិន្ត្រៃយ៍ក្នុងការអនុវត្តការងារទាំងអស់នេះ។ ស្ថាប័នទាំងនេះត្រូវរាយការណ៍ជូនសមាជិកគណៈអចិន្ត្រៃយ៍ដោយនៅទីក្រុងភ្នំពេញ។

[០៩:២៨:០៦]

កថាខណ្ឌ៤៩៖ ឈ្មោះផ្លូវការរបស់ស្ថាប័នពីរ ដែលសំខាន់បំផុតនៅក្នុងនោះគឺ មន្ទីរនយោបាយ ៨៧០ និងមន្ទីររដ្ឋបាល ដែលគណៈអចិន្ត្រៃយ៍ផ្តល់ឈ្មោះថា មន្ទីរស-៧១ ឬក្រសួង ស-៧១។ កំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ក៏មានបង្ហាញអំពីស្ថាប័នមួយដែលគេហៅថា ការិយាល័យ៨៧០ ដែលដឹកនាំដោយ ស៊ឹម សុន ហៅ យ៉ែម។ កំណត់ហេតុទាំងនោះបានបង្ហាញថា គាត់គឺជាអ្នកទទួលភារកិច្ចក្នុងការធ្វើកំណត់ហេតុនៃកិច្ចប្រជុំនានារបស់គណៈអចិន្ត្រៃយ៍និងគណៈមជ្ឈិម។

កថាខណ្ឌ៥០៖ ប្រធានមន្ទីរនយោបាយ៨៧០ ដំបូងគេគឺ សឿ វ៉ាស៊ី ហៅ ឌឿន ដែលបានកាន់មុខតំណែងនេះរហូតដល់មានការចាប់ខ្លួនគាត់នៅឆ្នាំ១៩៧៧។ ខៀវ សំផន ដែលធ្លាប់បានធ្វើការនៅក្នុងមន្ទីរមួយនេះដែរនោះ បានបដិសេធថា មិនមានពេលណាមួយដែលគាត់ធ្លាប់ជាប្រធានមន្ទីរនេះនោះទេ។ មន្ទីររដ្ឋបាល មន្ទីរ ស-៧១ ដែលបានគ្រប់គ្រងដោយ ឈឹម សំអោក ហៅ ប៉ង់ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ពេលដែលគាត់ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៨ គាត់ត្រូវបានជំនួសដោយឈ្មោះ កែន ហៅ លីន ដែលបានកាន់កាប់តួនាទីនេះរហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ទោះបីជាសាក្សីមួយរូបបានអះអាងថា មន្ទីររបស់ ប៉ង់ ត្រូវបានគ្រប់គ្រងដោយ ប៉ុល ពត ខ្លួនឯងផ្ទាល់ ដោយមាន ប៉ង់ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ប៉ុល ពត ផ្ទាល់។ ក៏ប៉ុន្តែសក្ខីកម្មផ្សេងទៀតបានបង្ហាញថា មន្ទីររបស់ ប៉ង់ ជាទូទៅក៏បានរាយការណ៍ទៅមជ្ឈិមផងដែរ។

[០៩:២៩:៥៥]

កថាខណ្ឌ៥១៖ ភាពខុសគ្នារវាងមន្ទីរទាំងពីរនេះ គឺមន្ទីរនយោបាយ៨៧០ ដែលដឹកនាំដោយ ឌឿន មានភារកិច្ចទទួលបន្ទុកផ្នែកនយោបាយ។ រីឯមន្ទីរស-៧១ ដែលដឹកនាំដោយ ប៉ង់ ត្រូវទទួលខុសត្រូវលើកិច្ចការរដ្ឋបាល និងការងារជំនួយការផ្សេងៗទៀត។ មន្ទីរនយោបាយ៨៧០ និងមន្ទីរស-៧១ ក៏ដូចជាស្ថាប័នដទៃទៀតជារឿយៗត្រូវបានគេផ្តល់ឈ្មោះឲ្យថា មន្ទីរ៨៧០ ឬមន្ទីររបស់អង្គការ ដោយមិនមានការយល់ច្បាស់ទេថា តើគេសំដៅដល់មន្ទីរមួយណានោះឡើយ។

កថាខណ្ឌ៥២៖ មន្ទីរនយោបាយ៨៧០ មានតួនាទីសំខាន់ក្នុងការធានាក្នុងការធ្វើទំនាក់ទំនងរវាងបុគ្គលនានាដែលមានអំណាចសម្រេចរបស់មជ្ឈិម ព្រមទាំងត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនានាតាមរយៈប្រព័ន្ធទំនាក់ទំនងព័ត៌មានមួយដែលមានលក្ខណៈទៀងទាត់ និងផ្ទាល់ទៅកាន់មន្ទីរនយោបាយ ៨៧០។ ទាក់ទងនឹងមន្ទីរដែលដឹកនាំដោយ ឌឿន កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ បានបង្ហាញថា មន្ទីរគណៈអចិន្ត្រៃយ៍ទាក់ទងពីផ្នែកមួយទៅផ្នែកមួយ។ គណៈអចិន្ត្រៃយ៍

តាមដានផ្នែកនីមួយៗក្នុងការអនុវត្តមាគ៌ា។ ខាងមន្ទីរមានភារកិច្ចតាមដានការអនុវត្ត។

[០៩:៣១:២២]

កថាខណ្ឌ៥៣៖ យោងតាមរៀបរាប់របស់ ឌុច មុខងារផ្សេងៗរបស់មន្ទីរស-៧១ មានដូចជា៖ ការពារមន្ទីរមជ្ឈិម និងកម្មាភិបាលនៃមន្ទីរនេះ ទទួលភ្ញៀវ ទូរគមនាគមន៍ ដែលមានទាំងនីរសារ និងសារទូរលេខ ភស្តុភារ ស្បៀង ការដឹកជញ្ជូន។ ប៉ុន្តែមន្ទីរស-៧១ ក្នុងនាមគណៈអចិន្ត្រៃយ៍ក៏មានភារកិច្ចក្នុងការតាមដានលើសមាជិករបស់បក្ស ក្រសួងនានា គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ខ្លួនឯងផងដែលខ្លួនមានការសង្ស័យ ព្រមទាំងធ្វើការចាប់ខ្លួនអ្នកដែលត្រូវបានចាត់ទុកថាជាជនក្បត់ និងបញ្ជូនពួកគេទាំងនោះទៅកាន់មន្ទីរស-២១។

កថាខណ្ឌ៥៤៖ នៅក្នុងរចនាសម្ព័ន្ធរបស់មន្ទីរស-៧១ មានមន្ទីរចំណុះមួយចំនួនដែលមានឈ្មោះសម្គាល់សម្ងាត់ ផ្តើមជាមួយនឹងព្យញ្ជនៈ “ក” នៅខាងមុខ ហើយទទួលខុសត្រូវលើការងាររដ្ឋបាល ឬភស្តុភារ ដើម្បីជួយដល់គណៈមជ្ឈិមក្នុងការបំពេញការងារ។ មន្ទីរ “ក” ទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ប៉ង់។ ក្នុងចំណោមមន្ទីរទាំងនោះ មន្ទីរដែលសំខាន់ៗរួមមាន មន្ទីរ ក-១, មន្ទីរ ក-៣, មន្ទីរ ក-៧ និងមន្ទីរ ក-១៨។

[០៩:៣២:៤១]

កថាខណ្ឌ៥៥៖ ភស្តុតាងបង្ហាញថាមន្ទីរ ក-១ គឺជាបរិវេណស្នាក់អាស្រ័យ និងធ្វើការរបស់ប៉ុល ពត។ ខណៈដែលសាក្សីមួយចំនួនបានអះអាងថា មន្ទីរ ក-១ គឺគ្រាន់តែជាកន្លែងធ្វើការរបស់ប៉ុល ពត តែ ប៉ុណ្ណោះ។ ម៉្យាងវិញទៀត សាក្សីមួយចំនួនបានលើកឡើងថា មានពេលខ្លះ នួន ជា និង/ឬ ខៀវ សំផន បានស្នាក់នៅ និង/ឬ ធ្វើការជាមួយប៉ុល ពត នៅមន្ទីរ ក-១ ផងដែរ។

កថាខណ្ឌ៥៦៖ មានភស្តុតាងបញ្ជាក់ទៀតថា ទីតាំងដែលគេស្គាល់ថាជាមន្ទីរក-៣ ពេលខ្លះត្រូវបានប្រើប្រាស់ជាកន្លែងស្នាក់នៅ និងកន្លែងធ្វើការរបស់ នួន ជា និង/ឬ ខៀវ សំផន, អៀង សារី, សុន សេន, ឬ វន វ៉េត ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីមួយចំនួនបានបញ្ជាក់ថាបានឃើញប៉ុល ពត ទៅដល់មន្ទីរក-១ មន្ទីរក-៣ ដើម្បីប្រជុំជាមួយ នួន ជា, អៀង សារី, សុន សេន, វន វ៉េត និង ខៀវ សំផន ក៏ដូចជាពេលខ្លះជាមួយ អៀង ធីរិទ្ធ ប្រសិនបើមានអង្គប្រជុំពាក់ព័ន្ធនឹងការងារសង្គមកិច្ច។

កថាខណ្ឌ៥៧៖ មន្ទីរក-៧ គឺជាអង្គភាពនីរសារ ដែលជាកន្លែងឆ្លងកាត់ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរនានា ដែលផ្ញើទៅកាន់គណៈ៨៧០ ឬមន្ទីរ៨៧០ មុននឹងបញ្ជូនទៅឲ្យប៉ុល ពត នៅ

មន្ទីរ ក-១ ក៏ដូចជាទៅឲ្យសមាជិកគណៈ៨៧០ ឬសមាជិកពាក់ព័ន្ធរបស់គណៈ៨៧០ អាស្រ័យលើការទទួលខុសត្រូវតាមផ្នែករបស់ខ្លួន។ មន្ទីរ ក-១៨ គឺជាអង្គភាពទូរលេខដែលមានភារកិច្ចទទួលការទាក់ទងតាមវិទ្យុរួចបញ្ជូនទៅកាន់មន្ទីរ ក-១។

[០៩:៣៤:២៧]

កថាខណ្ឌ៥៨៖ ភស្តុតាងដែលទទួលបាននៅមិនទាន់បង្ហាញឲ្យបានច្បាស់លាស់នៅឡើយទេថា បុគ្គលណាឲ្យពិតប្រាកដដែលត្រូវទទួលលិខិតទំនាក់ទំនងទាំងឡាយដែលផ្ញើទៅកាន់គណៈ៨៧០ ឬមន្ទីរ ៨៧០។ សាក្សីមួយចំនួនបានលើកឡើងថា ពាក្យទាំងនេះត្រូវបានប្រើសំដៅដោយផ្ទាល់ទៅគណៈមជ្ឈិម ខណៈដែលសាក្សីផ្សេងៗទៀត បានលើកឡើងថា សំដៅទៅគណៈអចិន្ត្រៃយ៍ទៅវិញ ឬទៅ ប៉ុល ពត តែម្តង។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីមួយចំនួននិងរួមទាំង ឌុច ផងដែរ បានលើកឡើងអំពីការយល់ឃើញរបស់ខ្លួនថា គណៈ៨៧០ ឬមន្ទីរ៨៧០ អាចនិយាយសំដៅដូចគ្នាចំពោះប៉ុល ពត, នួន ជា, អៀង សារី, វន វ៉េត, សុន សេន និងថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ដោយរួមទាំង ខៀវ សំផន ផងដែរ គឺអាស្រ័យទៅលើខ្លឹមសារនៃលិខិតទំនាក់ទំនងនោះ។

កថាខណ្ឌ៥៩៖ ភស្តុតាងផ្សេងៗទៀតដែលទទួលបានពាក់ព័ន្ធនឹងមន្ទីរ“ក” ដទៃទៀតបានបង្ហាញថា មន្ទីរ ក-៦ គឺជាកន្លែងជួបប្រជុំដែលគេស្គាល់ឈ្មោះថា “បុរីកីឡា”។ មន្ទីរ ក-៨ ទទួលបន្ទុកដាំស្ល បន្លែ។ មន្ទីរ ក-១១ ជាមន្ទីរពេទ្យ និងមន្ទីរ ក-១២ គឺជាអង្គភាពរៀបចំយានជំនិះ និងអ្នកបើកបរសម្រាប់មជ្ឈិមបក្ស។

កថាខណ្ឌ៦០៖ ទោះបីជាអង្គហេតុនានា បានបង្ហាញយ៉ាងច្បាស់ថា ខៀវ សំផន មានតួនាទីនៅក្នុងមន្ទីរ៨៧០ ក៏ចម្លើយដែលទទួលបានទាក់ទងនឹងតួនាទីនេះនៅមិនមានលក្ខណៈច្បាស់លាស់នៅឡើយ។ ឌុច និងសាក្សីពីររូបទៀតបានបញ្ជាក់ថា ប្រហែលឆ្នាំ១៩៧៧ ខៀវ សំផន បានក្លាយជាប្រធានមន្ទីរនយោបាយ៨៧០ ដែលពីមុនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឌឿន ខណៈដែលសាក្សីផ្សេងទៀត បានបញ្ជាក់ត្រឹមថា ខៀវ សំផន បានជួបជាមួយ ប៉ង់ នៅមន្ទីរ ស-៧១ ដើម្បីត្រួតពិនិត្យស្ថានការណ៍ជាមួយគាត់។ ហើយថា ប៉ង់ បានទទួលបញ្ជាពីខៀវ សំផន ក៏ដូចជាពីថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀតផងដែរ។

[០៩:៣៦:៣៧]

ចំពោះ ខៀវ សំផន ផ្ទាល់ គាត់បានបដិសេធចំពោះការទទួលតំណែងជាប្រធានមន្ទីរបន្តពី ឌឿន

ដោយបានលើកឡើងថា នៅក្នុងស្ថាប័ននោះ គាត់គ្រាន់តែទទួលបន្ទុកចម្បងលើបញ្ហាពាក់ព័ន្ធ និងភស្តុភារជាតិប៉ុណ្ណោះ។ ដូចជា ការចែកចាយអំបិល អង្ករ ស្រូវពូជ សម្លៀកបំពាក់ ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ ដល់បណ្តាភូមិភាគនានា និងរួមទាំងបញ្ហាដែលពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយលោកប៉ុណ្ណោះ។ សាក្សីមួយចំនួនដែលបានផ្តល់សក្ខីកម្មស្របតាមកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ផងដែរនោះ បានអះអាងថាសារទូរលេខដែលពាក់ព័ន្ធនឹងសម្ភារៈនិងភស្តុភារ ដែលបានផ្ញើទៅមន្ទីរ៨៧០ ឬលិខិតដែលមន្ទីរនេះបានផ្ញើចេញ គឺមានសរសេរឈ្មោះថា ខៀវ សំផន ដែលធ្វើសកម្មភាពក្នុងនាម និងការទទួលខុសត្រូវរបស់មន្ទីរនេះ។

[០៩:៣៧:៣២]

ទោះបីជាយ៉ាងណាក៏ដោយ ខៀវ សំផន បានធ្វើការអះអាងនៅក្នុងឆ្នាំ១៩៨០ ដោយបានទទួលស្គាល់នូវការជាប់ពាក់ព័ន្ធរបស់គាត់ជាមួយនឹងការតាមដាន និងការអង្កេតលើការចោទប្រកាន់ទៅលើកម្មាភិបាលភូមិភាគ ដែលនេះជាតួនាទីរបស់ ឌឿន បានធ្វើកាលពីពេលមុន។

កថាខណ្ឌ៦១៖ ជាចុងក្រោយ ខៀវ សំផន និង ឌុច ក៏ដូចជាសាក្សីជាច្រើនទៀតបានបញ្ជាក់ថាពាក្យថា “មន្ទីរ៨៧០”, “អង្គការ៨៧០”, “គណៈ៨៧០” ឬ “អង្គការ” ត្រូវបានប្រើប្រាស់ដោយមិនមានការបែងចែក ដើម្បីសំដៅដល់ស្ថាប័នដឹកនាំនានារបស់មជ្ឈិមបក្ស។ ឌុច បានលើកឡើងទាក់ទងនឹងមន្ទីរ៨៧០ នេះថា អ្វីដែលខ្ញុំអាចនិយាយបាននោះ គឺជាទីស្នាក់ការនៃមេដឹកនាំរបស់បក្ស។

ង) ក្រសួងនានា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

កថាខណ្ឌ៦២៖ តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបានធ្វើការកំណត់សមាសភាពរបស់ស្ថាប័នរដ្ឋ ដើម្បីបង្កើតរដ្ឋាភិបាលផ្លូវការជំនួសឲ្យរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ មានការប្រកាសថា រដ្ឋាភិបាលត្រូវជាអង្គការរបស់បក្សសុទ្ធសាធ ជារដ្ឋរបស់យើងផ្ទាល់ ឈ្មោះរបស់រដ្ឋមន្ត្រីទាំងអស់ត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦។

[០៩:៣៩:០០]

កថាខណ្ឌ៦៣៖ ទោះបីជាសមាសភាពនេះអាចត្រូវបានផ្លាស់ប្តូរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ជាគោលការណ៍រដ្ឋាភិបាលត្រូវបានរៀបចំឡើងក្នុងបែបផែនដូចតទៅ៖

-ប៉ុល ពត ជានាយករដ្ឋមន្ត្រីទទួលបន្ទុកទូទៅលើផ្នែកយោធា និងផ្នែកសេដ្ឋកិច្ច។

-អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស

-សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ

-វន វេត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច

-នួន ជា ជាប្រធានសភាតំណាងប្រជាជន

-ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ

-យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងអប់រំ

-តូច ភឿន ជារដ្ឋមន្ត្រីក្រសួងសាធារណការ ដឹកជញ្ជូន និងប្រៃសណីយ៍

-កុយ ធឿន ជារដ្ឋមន្ត្រីពាណិជ្ជកម្ម

-ចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

-អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច

-(លុប) ជារដ្ឋមន្ត្រីទទួលបន្ទុកសុខាភិបាល និង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ដែលធ្លាប់ទទួលបន្ទុកផ្នែកពាណិជ្ជកម្ម ទាក់ទងទៅ នឹងគណនេយ្យ និងការកំណត់តម្លៃ។

[០៩:៤០:១៦]

**ផ្នែកទី៣៖ រចនាសម្ព័ន្ធរដ្ឋបាល ថ្នាក់មូលដ្ឋាន៖**

កថាខណ្ឌ៦៤៖ តាមការកំណត់ទីតាំងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកជាផ្នែកតូចៗទៅជាអង្គភាពរដ្ឋបាល ដែលមានឋានានុក្រមបន្តគ្នា ដែលទាក់ទងទៅនឹងសង្វាក់នៃការបញ្ជាតាមខ្សែបណ្តោយ(ខ្សែឈរ) ដែលគ្រប់គ្រងដោយមជ្ឈិម។ ភូមិភាគធំៗមួយចំនួន គឺស្ថិតនៅក្រោមមជ្ឈិមដោយផ្ទាល់។ ភូមិភាគទាំងនេះត្រូវបានបែងចែកទៅជាតំបន់ ដែលតំបន់នីមួយៗ មានបែងចែកជាស្រុកមួយចំនួន ដែលនៅក្នុងស្រុកមួយចំនួនមានឃុំនិងសហករណ៍។ នៅគ្រប់កម្រិតនីមួយៗនៃភូមិភាគ តំបន់ ស្រុក និងឃុំ ត្រូវបានគ្រប់គ្រងដោយគណៈ ដែលគណៈនីមួយៗត្រូវបានដឹកនាំដោយលេខា។

កថាខណ្ឌ៦៥៖ ភ្លាមៗបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ មានប្រាំមួយភូមិភាគ។ ភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគឦសាន ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា។ នៅឆ្នាំ១៩៧៧ ភូមិភាគឧត្តរត្រូវបានដាក់ឈ្មោះសាជាថ្មីថា ជាភូមិភាគកណ្តាល និងភូមិភាគឧត្តរថ្មីមួយទៀតត្រូវបានបង្កើត។

[០៩:៤១:៣២]

កថាខណ្ឌ៦៦៖ បន្ថែមពីលើភូមិភាគនានា ដែលបានរាយការណ៍ផ្ទាល់ទៅថ្នាក់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតតំបន់ស្វយ័តមួយចំនួន ដែលរំលងថ្នាក់ភូមិភាគក្នុងការរាយការណ៍ផ្ទាល់ទៅថ្នាក់

មជ្ឈិម។ តំបន់ទាំងនេះ គឺតំបន់ស្វយ័ត១០៣ ព្រះវិហារ, តំបន់ស្វយ័ត១០៥ មណ្ឌលគិរី, តំបន់ស្វយ័ត ១០៦ សៀមរាប, តំបន់ស្វយ័ត៥០៥ ក្រចេះ និងតំបន់ស្វយ័តទីក្រុងកំពង់សោម កំពង់ផែសំខាន់បំផុតរបស់ប្រទេសកម្ពុជា។ លើសពីនេះទៀតភ្នំពេញ ត្រូវបានចាត់ថ្នាក់ជាទឹកដីផ្សេងពីគេ ដោយមិនស្ថិតនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋានជាផ្លូវការនោះទេ ដោយធ្វើសេចក្តីរាយការណ៍ផ្ទាល់ទៅថ្នាក់មជ្ឈិមតែម្តង។ នៅឆ្នាំ១៩៧៧ តំបន់ស្វយ័ត១០៦ សៀមរាប ត្រូវបានបញ្ចូលគ្នាជាមួយនឹងតំបន់ស្វយ័ត១០៣ ព្រះវិហារ ដើម្បីបង្កើតជាភូមិភាគឧត្តរថ្មី។

[០៩:៤២:៣៣]

កថាខណ្ឌ៦៧៖ អង្គហេតុដែលសហាចៅក្រមស៊ើបអង្កេតត្រូវបានថ្លឹង ស្ថិតនៅគ្រប់ភូមិភាគនីមួយៗ នៃរចនាសម្ព័ន្ធថ្នាក់មូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជានៅតំបន់ពីរក្នុងចំណោមតំបន់ស្វយ័តនានា។ មន្ទីរសន្តិសុខសង់ និងក្រាំងតាចាន់ សហករណ៍ត្រាំកក់ និងការដ្ឋានស្រែអំបិល និងការដ្ឋានព្រៃស (ស-២៤) មានទីតាំងនៅភូមិភាគនិរតី។ មន្ទីរសន្តិសុខវត្តគិរីរម្យ កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ និងការដ្ឋានត្រពាំងថ្មស្ថិតនៅក្នុងភូមិភាគពាយ័ព្យ។ កន្លែងសម្លាប់មនុស្សស្ទឹងតូច និងមន្ទីរសន្តិសុខវត្តផ្គកស្ថិតនៅក្នុងភូមិភាគបូព៌ា។ មន្ទីរសន្តិសុខភូមិភាគឧត្តរស្ថិតនៅក្នុងភូមិភាគឧត្តរថ្មី។ ការដ្ឋានទំនប់ ១មករា ស្ថិតនៅក្នុងភូមិភាគកណ្តាល ភូមិភាគឧត្តរចាស់។ មន្ទីរសន្តិសុខអូរកន្សែងស្ថិតនៅក្នុងភូមិភាគឦសាន។ មន្ទីរសន្តិសុខព្រៃដំរីស្រុត មន្ទីរសន្តិសុខកោះខ្យង កន្លែងសម្លាប់មនុស្សក្នុងស្រុក១២ និងការដ្ឋានសាងសង់វាលយន្តហោះកំពង់ឆ្នាំង ស្ថិតនៅក្នុងភូមិភាគបស្ចិម។ មន្ទីរសន្តិសុខ ស-២១ ស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ ជាចុងក្រោយមន្ទីរសន្តិសុខភ្នំក្រោលស្ថិតនៅក្នុងតំបន់ស្វយ័ត១០៥ រីឯមន្ទីរសន្តិសុខគោកក្តួចស្ថិតនៅក្នុងតំបន់ស្វយ័ត៥០៥។

[០៩:៤៣:៥៨]

កថាខណ្ឌ៦៨៖ លេខាភូមិភាគត្រូវបានតែងតាំងជាទូទៅដោយគណៈមជ្ឈិម។ ការអនុវត្តសេចក្តីសម្រេចរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ត្រូវបានធ្វើឡើងដោយលេខាភូមិភាគ និងលេខាតំបន់ស្វយ័ត។ គោលនយោបាយនិងសេចក្តីណែនាំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ត្រូវបានផ្សព្វផ្សាយដល់លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត ដែលនឹងផ្សព្វផ្សាយគោលនយោបាយ និងសេចក្តីណែនាំទាំងនោះបន្តទៀតក្នុងចំណោមលេខាតំបន់ និងលេខាស្រុកដើម្បីអនុវត្ត។ ផ្ទុយទៅវិញ ឃុំនានាបានរាយការណ៍ត្រឡប់ទៅគណៈស្រុកវិញ ដែលគណៈស្រុកត្រូវរាយការណ៍បន្តទៅគណៈតំបន់ ដែលគណៈ

តំបន់ត្រូវរាយការណ៍បន្តទៅគណៈភូមិភាគ។

[០៩:៤៤:៤៣]

កថាខណ្ឌ៦៩៖ លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាចែងថា ភារកិច្ច និងមុខងាររបស់គណៈភូមិភាគ គឺដើម្បីដឹកនាំអនុវត្តភារកិច្ច យោងតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាតាមរយៈចុះជាប់ជាមួយតំបន់ ស្រុក និងឃុំនានា។ នៅក្នុងការធ្វើការងារនេះ គណៈភូមិភាគ ត្រូវបានផ្តល់អំណាចឱ្យធ្វើការ កំណាត់ការងារថ្មីតាមមាគ៌ានយោបាយរបស់បក្ស ដែលមានន័យថា មាគ៌ាបក្សត្រូវតែអនុវត្តតាមមាគ៌ានយោបាយ ការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលមានន័យម្យ៉ាងវិញទៀតថា ភូមិភាគទាំងឡាយត្រូវទទួលខុសត្រូវចំពោះស្ថានភាពសន្តិសុខផ្ទៃក្នុង ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន។ ដោយហេតុយ៉ាងនេះហើយ គណៈភូមិភាគត្រូវបានអនុញ្ញាតឱ្យអនុវត្តវិន័យក្នុងក្របខ័ណ្ឌភូមិភាគ។ ម្យ៉ាងវិញទៀត គណៈភូមិភាគត្រូវបានផ្តល់អំណាចឱ្យធ្វើការជ្រើសរើសសមាជិកថ្មី សម្រាប់ការដឹកនាំថ្នាក់ភូមិភាគដែលត្រូវអនុម័តយល់ព្រមពីគណៈមជ្ឈិម។ គណៈភូមិភាគ ក៏ត្រូវបានតម្រូវតាមលក្ខន្តិកៈឱ្យរក្សារបបរាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ភូមិភាគជូនគណៈកម្មាធិការមជ្ឈិម។

កថាខណ្ឌ៧០៖ នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាភារកិច្ច និងមុខងារស្រដៀងគ្នានេះត្រូវបានផ្តល់ឱ្យទៅគណៈតំបន់ គណៈស្រុក និងគណៈឃុំ ដោយតម្រូវឱ្យអនុវត្តសេចក្តីណែនាំ និងសេចក្តីរាយការណ៍ត្រឡប់ទៅរដ្ឋបាលថ្នាក់លើវិញ។

[០៩:៤៦:១៦]

កថាខណ្ឌ៧១៖ បន្ថែមពីការប្រជុំរាល់ប្រាំមួយខែម្តងរបស់គណៈអចិន្ត្រៃយ៍ មានកិច្ចប្រជុំប្រចាំឆ្នាំនៅទីក្រុងភ្នំពេញរវាងលេខាភូមិភាគ និងគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក៏ដូចជាមានការកិច្ចប្រជុំជាញឹកញាប់ថែមទៀតនៅទីក្រុងភ្នំពេញ រវាងថ្នាក់មជ្ឈិមជាមួយនឹងសមាជិកភូមិភាគតំបន់ និងស្រុក។ បន្ថែមពីលើនេះទៀត ការប្រជុំគ្នាផ្ទាល់នឹងធ្វើឡើងរវាងភូមិភាគនិងតំបន់។ បន្ទាប់មកតំបន់នានានឹងធ្វើការអញ្ជើញលេខាស្រុក និងលេខាឃុំឱ្យចូលរួមប្រជុំដែលនឹងត្រូវផ្សព្វផ្សាយសេចក្តីណែនាំបន្តទៀត ដល់អង្គភាពរបស់គេរៀងៗខ្លួន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

ជាបន្តសូមអញ្ជើញលោក ឌុច ផារី ឡើងអានបន្ត។

សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

**ផ្នែកទី៤៖ ប្រព័ន្ធទំនាក់ទំនងការងារ**

កថាខណ្ឌ៧២៖ គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា គឺជាក្បាលម៉ាស៊ីននៃប្រព័ន្ធទំនាក់ទំនងការងាររបស់បក្សនៅទូទាំងប្រទេស។ គណៈអចិន្ត្រៃយ៍ជាចំណុចប្រមូលផ្តុំប្រព័ន្ធព័ត៌មានជាប់លាប់រវាងផ្នែកនីមួយៗនៃឋានានុក្រមរដ្ឋបាល។ គណៈអចិន្ត្រៃយ៍ចេញសេចក្តីណែនាំ រាយការណ៍ជាទិដ្ឋភាពរួមតាមរយៈមុខព្រួញនានា។ ស្នើរាយការណ៍ខ្លីៗតាមរយៈទូរលេខ ការធ្វើដូច្នេះ គណៈអចិន្ត្រៃយ៍ដឹងសភាពការណ៍ដើម្បីណែនាំបានទាន់ពេលវេលា។

[០៩:៤៧:៥៥]

ក) បណ្តាញទំនាក់ទំនង

កថាខណ្ឌ៧៣៖ បណ្តាញទំនាក់ទំនងជាច្រើនត្រូវបានរៀបចំឡើងយ៉ាងហ្មត់ចត់នៅថ្នាក់មជ្ឈិមរវាងក្រសួងនានា និងមន្ទីរនានា ដែលនៅជុំវិញមជ្ឈិម។ ក្នុងចំណោមកងទ័ពរបស់មជ្ឈិម និងនៅក្នុងមន្ទីរសន្តិសុខរបស់មជ្ឈិម។ មន្ទីរស-២១ រវាងមជ្ឈិម និងភូមិភាគ គ្មានការទំនាក់ទំនងផ្ទាល់រវាងភូមិភាគ និងភូមិភាគណាមួយត្រូវបានអនុញ្ញាតឡើយ និងរវាងភូមិភាគ និងតំបន់។

**ទំនាក់ទំនងទៅមជ្ឈិម៖**

កថាខណ្ឌ៧៤៖ ការបែងចែកសារដែលមកដល់មជ្ឈិមពីអង្គភាពខាងក្រៅ ត្រូវបានសម្រួលសម្រួល ដោយមន្ទីរ ក-១ ដែលជាកន្លែងត្រូវសម្រេច ថាតើមេដឹកនាំមួយណាដែលត្រូវទទួលការចម្លងជូន? សេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយ ប៉ុល ពត និងសហការីរបស់គាត់ ដែលហេតុនេះហើយបានជាអ្នកទាំងនោះបានទទួលសារចូលមកជាច្រើនដងក្នុងមួយថ្ងៃៗ។ តាមសាក្សីម្នាក់បញ្ជាក់ថា នួន ជា តែងតែបានទទួលការចម្លងជូននូវសារដែល ប៉ុល ពត បានអាន។

[០៩:៤៩:២២]

កថាខណ្ឌ៧៥៖ មានការទាក់ទងគ្នាញឹកញាប់ជាលាយលក្ខណ៍អក្សរផងដែរ រវាងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាម្នាក់ៗ ជាពិសេសរវាង ប៉ុល ពត និង នួន ជា ដែលធ្វើការឆ្លើយឆ្លងសំបុត្រទៅវិញទៅមកជារៀងរាល់ថ្ងៃ ឬពីរថ្ងៃម្តង។

**ទំនាក់ទំនងពីភូមិភាគទៅមជ្ឈិម៖**

កថាខណ្ឌ៧៦ ភូមិភាគ និងតំបន់ស្វយ័តបានរាយការណ៍ទៅគណៈអចិន្ត្រៃយ៍ ជាពិសេសទៅលើស្ថានភាពកសិកម្ម ដូចជាការធ្វើស្រែ និងទៅលើប្រព័ន្ធធារាសាស្ត្រ ជីវភាពប្រជាជន និងស្ថានភាពខ្មាំង និងស្ថានភាពយោធា។ សាក្សីម្នាក់ជាលេខាតំបន់ស្វយ័ត១០៥ បានបញ្ជាក់ថា គាត់បានបញ្ជូនសារទូរលេខទៅមជ្ឈិម ហើយ ប៉ុល ពត បានបញ្ជូនត្រឡប់មកវិញនូវមតិយោបល់លើការចាប់ខ្លួនកម្មាភិបាល និងលើចម្លើយសារភាពរបស់ពួកគេ។

[០៩:៥០:៣៨]

កថាខណ្ឌ៧៧៖ សារទូរលេខនានាដែលបានរកឃើញ បានបញ្ជាពីបញ្ហានានាដែលជាប់ទាក់ទងនឹងការរត់ចោលជួរ និងការគ្មានវិន័យ ជម្លោះជាមួយវៀតណាម។ មានការរាយការណ៍លម្អិតពីចំនួនខ្មាំងដែលបានសម្លាប់ និងសម្ភារៈដែលត្រូវបានរឹបអូស និងបានរាយការណ៍ប្រាប់មន្ទីរ៨៧០ ពីផែនការប្រយុទ្ធ និងចលនារបស់ខ្មាំង។ បញ្ហាសន្តិសុខផ្ទៃក្នុងជាទូទៅ ឬដោយលម្អិត ជួនកាលសម្តៅដល់បុគ្គលដែលបានត្រូវសង្ស័យ គិញវៀតណាម និងការសួរចម្លើយគិញវៀតណាមនោះ ដែលបញ្ជាក់ពីការប្រើប្រាស់ទារុណកម្ម ឬជនក្បត់ដោយមានបញ្ជាក់ឈ្មោះ។

កថាខណ្ឌ៧៨៖ ភូមិភាគបានឆ្លើយឆ្លងសារទូរលេខមួយ ឬច្រើនក្នុងមួយថ្ងៃជាមួយនឹងតំបន់នីមួយៗ ដោយមិនមានលក្ខណៈទៀងទាត់ទេ។ មានតែទំនាក់ទំនងរវាងមជ្ឈិម និងតំបន់ប៉ុណ្ណោះមិនដែលមានទំនាក់ទំនងរវាងមជ្ឈិមនិងថ្នាក់ស្រុកទេ។

កថាខណ្ឌ៧៩៖ លេខាភូមិភាគម្នាក់ មានតារាងពេលវេលាសម្រាប់ទំនាក់ទំនង ដែលត្រូវកំណត់ដោយមជ្ឈិម ដោយបញ្ជាក់ពីពេលវេលាដែលត្រូវទាក់ទងជាមួយនឹងមជ្ឈិម។ សារទូរលេខជាច្រើនត្រូវបានផ្ញើចេញពីភូមិភាគយ៉ាងហោចណាស់មួយដងដែរក្នុងមួយថ្ងៃ។ ជួនកាលពីរដងក្នុងមួយថ្ងៃ នៅពេលព្រឹកនិងនៅពេលល្ងាច។ នៅក្នុងកាលៈទេសៈពិសេស សារទូរលេខអាចត្រូវបានផ្ញើនៅម៉ោងផ្សេងក៏បាន។ អ្នកប្រតិបត្តិការសារទូរលេខម្នាក់ ក្នុងចំណោមអ្នកប្រតិបត្តិការសារទូរលេខជាច្រើននៅក្នុងភូមិភាគកណ្តាល ភូមិភាគឧត្តរចាស់ បានបញ្ជាក់ថា គាត់បានទទួលសារបានប្រហែលបួន ទៅប្រាំសារក្នុងមួយថ្ងៃពីមជ្ឈិម៨៧០។

[០៩:៥២:៥៦]

កថាខណ្ឌ៨០៖ តារាងពេលវេលាសម្រាប់ទំនាក់ទំនង ដោយសារទូរលេខ ដែលត្រូវបានផ្ញើពី

ភូមិភាគទៅតំបន់នានា ត្រូវកំណត់ដោយភូមិភាគ ដោយធ្វើយ៉ាងណាឲ្យមានលក្ខណៈងាយស្រួលធ្វើការបែងចែករវាងសារទូរលេខនានា ដែលផ្ញើមកពីមជ្ឈិម និងសារទូលេខនានាដែលបានទទួលពីតំបន់នានា។ ការទទួលសារទូលេខនីមួយៗ ត្រូវបានបញ្ជាក់ថា បានទទួលតាមរយៈពាក្យសម្ងាត់ ដោយអ្នកដែលត្រូវទទួលសារទូរលេខ។ ក្នុងអំឡុងឆ្នាំ១៩៧៨ ទំនាក់ទំនងរវាងមជ្ឈិមនិងភូមិភាគមានការកើនឡើង ដោយសារមានការរីកចម្រើនផ្នែកបច្ចេកទេស។

កថាខណ្ឌ៨១៖ សាក្សីជាច្រើនបង្ហាញថា មានគោលការណ៍ដ៏តឹងរ៉ឹងមួយ ដែលហាមមិនឲ្យមានទំនាក់ទំនងដោយផ្ទាល់រវាងភូមិភាគនិងភូមិភាគទេ។ ទំនាក់ទំនងការងាររវាងភូមិភាគនិងភូមិភាគ ត្រូវឆ្លងកាត់តាមមជ្ឈិម។ គ្មានតារាងពេលវេលាសម្រាប់ទាក់ទងសារទូរលេខ ឬតារាងសម្រាប់បកប្រែលេខសម្ងាត់សម្រាប់ទំនាក់ទំនងសារទូរលេខពីភូមិភាគទៅភូមិភាគទេ។ ដូច្នេះហើយ ទំនាក់ទំនងផ្ទាល់រវាងភូមិភាគបែបនេះមិនអាចកើតមានទេ។ ប៉ុន្តែមានអ្នកប្រតិបត្តិការសារទូលេខម្នាក់បញ្ជាក់ថា ទំនាក់ទំនងផ្ទាល់រវាងភូមិភាគទៅភូមិភាគ ត្រូវបានធ្វើឡើងតាមរយៈសំបុត្រ ដែលត្រូវបានផ្ញើតាមនីរសារ ហើយសំបុត្រនោះត្រូវបានបោះត្រារបស់ភូមិភាគ។

[០៩:៥៤:៥៥]

**ទំនាក់ទំនងការងារពីភូមិភាគទៅតំបន់ និងស្រុក៖**

កថាខណ្ឌ៨២៖ តំបន់នីមួយៗ មានអង្គភាពសារទូរលេខផ្ទាល់របស់ខ្លួន ប៉ុន្តែរាល់ការបញ្ជូនសារទូរលេខរបស់តំបន់ ត្រូវឆ្លងតាមរយៈភូមិភាគ។

កថាខណ្ឌ៨៣៖ មានតែតំបន់ស្វយ័តទេ ដែលទាក់ទងដោយផ្ទាល់ជាមួយភូមិភាគ។ សាក្សីម្នាក់បានធ្វើការជាអ្នកប្រតិបត្តិការសារទូរលេខនៅតំបន់ស្វយ័ត១០៥ បញ្ជាក់ថា មន្ទីរស្រុកភាគច្រើនបានរាយការណ៍ពីគម្រោងសាងសង់ទំនប់ និងប្រឡាយទឹក សុខភាព ការត្រួតពិនិត្យកងកម្លាំង និងពីសមាសភាពល្អ និងមិនល្អ សមាសភាពក្បត់ ឬសន្តិសម្ព័ន្ធ។ លេខាតំបន់ជាអ្នករៀបចំរបាយការណ៍ អំពីការងាររបស់ស្រុក ហើយផ្ញើរបាយការណ៍នោះទៅមជ្ឈិមជាប្រចាំថ្ងៃ។

កថាខណ្ឌ៨៤៖ នីរសារជាច្រើនត្រូវបានគេប្រើប្រាស់ជាចម្បង នៅក្នុងទំនាក់ទំនងការងារ រវាងស្រុកនិងតំបន់ ដូចដែលបានចង្អុលបង្ហាញដោយប្រភពអាមេរិកាំង របាយការណ៍*ស្ទូនី ប៊ិច* ស្រុកនីមួយៗ និងតំបន់ នៅក្នុងភូមិភាគ មានបណ្ដាញនីរសារមួយ។ បណ្ដាញនេះធ្វើតាមរយៈសម្ព័ន្ធដ៏តឹងរ៉ឹងមួយ ដែលឆ្លុះបញ្ចាំងពីខ្សែសង្វាក់បញ្ជារបស់ភូមិភាគ។ ឧទាហរណ៍៖ ទោះបីមានអង្គភាពនីរសារ ថ្នាក់

ស្រុកដែលមានទីតាំងនៅជិតនឹងអង្គភាពភូមិភាគក៏ដោយ ក៏អង្គភាពថ្នាក់ស្រុកដំបូងត្រូវផ្ញើសារទៅបញ្ជាការកណ្តាលរបស់ពួកគេ រួចផ្ញើទៅមន្ទីរនីរសារភូមិភាគ។ បន្ទាប់មក សារបានចូលដល់បណ្តាញភូមិភាគ។ នីរសារបានបញ្ជូនសារសំខាន់ៗ ទាក់ទងនឹងការងារសន្តិសុខ ការងារបក្ស ការងារយោធា ព្រមទាំងធ្វើទំនាក់ទំនងផ្ទាល់ឲ្យបុគ្គលដែលនៅតាមទីតាំងនីមួយៗ។

[០៩:៥៧:២៦]

**ទំនាក់ទំនងក្រៅប្រទេស៖**

កថាខណ្ឌ៨៥៖ កម្ពុជាប្រជាធិបតេយ្យ មានមធ្យោបាយបច្ចេកទេស ដើម្បីទំនាក់ទំនងជាមួយនឹងប្រទេសក្រៅ ហើយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បញ្ជូនសារទូរលេខទៅប្រទេសផ្សេងៗភាគច្រើន គឺរដ្ឋដែលជាមិត្តសង្គមនិយម ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីផ្តល់យោបល់និងអបអរសាទរលើព្រឹត្តិការណ៍នានា ឬដើម្បីពន្យល់ថា អ្វីៗប្រព្រឹត្តទៅបានល្អប្រសើរ។

កថាខណ្ឌ៨៦៖ យោងតាម (លុប) ព័ត៌មានក្រៅប្រទេសត្រូវបានផ្សព្វផ្សាយតាមរយៈស្ថានទូតនៅទីក្រុងប៉េកាំង ហើយការទាក់ទងអាចមកពីបក្ស ឬពីរដ្ឋាភិបាល ឬដោយផ្ទាល់ពី ប៉ុល ពត ទៅកាន់ទីស្នាក់ការបក្សនៅទីក្រុងប៉េកាំង។ នៅក្នុងប្រទេសប្រជាជនមិនមានលទ្ធភាពទទួលសេវាព័ត៌មានបរទេសណាមួយទេ។ ក្រសួងឃោសនាការត្រូវបានណែនាំ ឲ្យជម្រាបជូនដល់មេដឹកនាំជាន់ខ្ពស់ជាប្រចាំថ្ងៃដោយសង្ខេប អំពីអ្វីដែលបានកើតមាននៅលើពិភពលោក។ លើសពីនេះទៀត (លុប) បានបញ្ជាក់ថាសាក្សីបានប្រគល់ភារកិច្ចដល់ (លុប) ឲ្យស្តាប់ព័ត៌មានដែលផ្សាយ ដោយសេវាព័ត៌មានបរទេសនានា។

[០៩:៥៩:១៧]

**កិច្ចប្រជុំដើម្បីសិក្សារៀនសូត្រនៅមជ្ឈិម៖**

កថាខណ្ឌ៨៧៖ កម្មាភិបាលមកពីគណៈភូមិភាគ និងតំបន់ រួមទាំងកងទ័ព ត្រូវបានកោះហៅមកចូលរួមកិច្ចប្រជុំសិក្សារៀនសូត្រ នៅទីក្រុងភ្នំពេញ ឬនៅមជ្ឈិម។ សាក្សីជាច្រើនបាននិយាយថា នួន ជា ឬមន្ទីរ ៨៧០ ឬ៨៧០ ឬ ប៉ុល ពត ជាអ្នកធ្វើការកោះហៅនេះ។

កថាខណ្ឌ៨៨៖ នៅក្នុងករណីជាច្រើន នៅពេលដែលកម្មាភិបាលត្រូវបានហៅមកមជ្ឈិម កម្មាភិបាលនោះត្រូវបានចាប់ខ្លួន ហើយមិនដែលត្រឡប់ទៅភូមិភាគរបស់ខ្លួនវិញឡើយ។

កថាខណ្ឌ៨៩៖ កិច្ចប្រជុំប្រចាំខែនៅមជ្ឈិម ត្រូវបានធ្វើឡើងនៅក-១ ដែលមានការចូលរួមពីសំណាក់គណៈស្រុក គណៈតំបន់ និងគណៈភូមិភាគ។ ជារឿយៗ កិច្ចប្រជុំនេះត្រូវបានដឹកនាំនិងចូលរួម

ដោយកម្មាភិបាលជាន់ខ្ពស់របស់បក្ស។ កិច្ចប្រជុំផ្នែកយោធា ដែលប្រមូលផ្តុំមេបញ្ជាការយោធានានា ត្រូវបានធ្វើឡើងនៅពហុកីឡាដ្ឋានជាតិអូឡាំពិក ហើយត្រូវបានដឹកនាំប្រជុំដោយប៉ុល ពត និង សុន សេន។ ជួនកាលកិច្ចប្រជុំពិសេសនានាត្រូវបានធ្វើឡើងដោយអ្នកចូលរួមតែពីរបីនាក់ប៉ុណ្ណោះ។ កិច្ចប្រជុំនោះធ្វើឡើងមិនទៀងទាត់ទេ។

[១០:០១:១៥]

ខ) មធ្យោបាយនៃទំនាក់ទំនង

កថាខណ្ឌ៩០៖ ក្នុងចំណោមភស្តុតាងដទៃទៀត ដោយពិនិត្យរបាយការណ៍ពីកម្មាភិបាលថ្នាក់ក្រោមទៅថ្នាក់លើរបស់ពួកគេ សេចក្តីណែនាំពីថ្នាក់លើទៅថ្នាក់ក្រោមបង្គាប់និងការស្នើសុំផ្តល់ព័ត៌មានដែលអាចត្រូវបានរកឃើញផងដែរនោះ វាទំនងជាបង្ហាញឲ្យឃើញថា ទំនាក់ទំនងជាចម្បងរវាងមន្ទីរ និងមន្ទីរ ឬរវាងបុគ្គល និងបុគ្គល ត្រូវបានធ្វើឡើងតាមសំបុត្រ សារទូរលេខ និងនីរសារ។ ទំនាក់ទំនងការងារ ជាផ្លូវការត្រូវបានធ្វើឡើងផងដែរតាមរយៈការប្រជុំនានាដែលរៀបចំឡើងនៅតាមថ្នាក់រដ្ឋបាលនីមួយៗ និងតាមរយៈការប្រមូលផ្តុំប្រជុំគ្នាដ៏ធំនៅភ្នំពេញ។ ជាទូទៅ ការអញ្ជើញឲ្យមកចូលរួមប្រជុំផ្លូវការបែបនេះ ត្រូវបានធ្វើឡើងតាមរយៈនីរសារ ឬសារទូរលេខ។

លើសពីនេះទៀត បក្សកុម្មុយនីស្តកម្ពុជាបានផ្សព្វផ្សាយនូវសេចក្តីណែនាំនានា និងឯកសារបណ្តុះបណ្តាលមនោគមន៍វិជ្ជានយោបាយនៅទូទាំងប្រទេស។ ឯកសារផ្សព្វផ្សាយបែបនេះ ត្រូវបានបញ្ជូនពីថ្នាក់មជ្ឈិមទៅកម្មាភិបាលរដ្ឋបាលថ្នាក់ក្រោម ដែលជាអ្នកផ្សព្វផ្សាយឯកសារនេះបន្ត នៅក្នុងចំណោមប្រជាជននៅតាមភូមិភាគនានា និងតំបន់នានា។

[១០:០៣:០២]

**សំបុត្រ៖**

កថាខណ្ឌ៩១៖ សំបុត្រនានាត្រូវបានបញ្ជូនមកពីមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី។ សំបុត្រត្រូវបញ្ជូនតាមរយៈនីរសារទៅឲ្យលេខាភូមិភាគនិងលេខាតំបន់នានា។ មានសារទូរលេខមួយនៅក្នុងចំណោមសារទូរលេខជាច្រើន ដែលបានផ្ញើពីភូមិភាគកណ្តាលបង្ហាញថា ពេលខ្លះសំបុត្រទាំងនោះត្រូវបានបញ្ជូនមកផ្ទាល់ដោយកម្មាភិបាលជាន់ខ្ពស់នានាខ្លួនឯង ដូចជាលេខាភូមិភាគ កែ ពក ជាដើម។

[១០:០៣:៥៥]

**នីរសារ៖**

កថាខណ្ឌ៩២៖ នីរសារត្រូវបានគេប្រើប្រាស់ជាចម្បង ដើម្បីនាំយកសេចក្តីរាយការណ៍ និង/ឬ សារទូរលេខ ពីអង្គភាពនាំសារ តាមសារទូរលេខទៅកាន់ក្រសួងនានា ឬត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនងគ្នាទៀងទាត់ និងបញ្ហាការចាប់ខ្លួន។ នីរសារបានធ្វើការទាក់ទងដោយផ្ទាល់តាមរយៈការជិះកង់ និងជិះម៉ូតូ។ នីរសារមានការរវល់ណាស់ និងបានចំណាយពេលដ៏ខ្លីប៉ុណ្ណោះ នៅតាមកន្លែងនីមួយៗ មុនពេលពួកគេត្រឡប់មកមូលដ្ឋានរបស់គេវិញ។ នីរសារមិនមានកាតព្វកិច្ចធ្វើការចំពោះតែខ្សែបណ្ដាយតែមួយគត់ប៉ុណ្ណោះទេ ប៉ុន្តែធ្វើការឲ្យគ្រប់ខ្សែបណ្ដាញទាំងអស់ ដែលបម្រើឲ្យអង្គភាពនីរសាររបស់ពួកគេ។ មានសាក្សីម្នាក់បញ្ជាក់ថា នីរសារពីមជ្ឈិមបានប្រើប្រាស់ទូកលឿនដើម្បីទៅកាន់តំបន់ ស្វយ័ត ៥០៥ នៅខេត្តក្រចេះ។

[១០:០៥:១៩]

**សារទូរលេខ៖**

កថាខណ្ឌ៩៣៖ ក្រោយពេលដួលរលំរបបភ្នំពេញក្នុងឆ្នាំ១៩៧៥ អង្គភាពសារទូរលេខមជ្ឈិម ដែលបានប្រតិបត្តិការតាំងពីនៅក្នុងតំបន់រំដោះត្រូវបានផ្លាស់មកភ្នំពេញដែរ។ មានកុមារប្រហែលជា ៤០នាក់ ត្រូវបានគេជ្រើសរើសមកពីបណ្ដាខេត្តនានា និងត្រូវបានបង្រៀនពីបច្ចេកទេសការងារជាមូលដ្ឋាននៃទំនាក់ទំនងការងារតាមសារទូរលេខ។ របៀបដាក់លេខកូដសម្ងាត់សារទូរលេខ វាយអត្ថបទ ។ល។ និងជួនកាលមានរៀនភាសាបារាំង និងអង់គ្លេសផងដែរ។ គណៈអចិន្ត្រៃយ៍បានសម្រេចនាថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៧៥ អំពីរបៀបដំណើរការនៃអង្គភាពសារទូរលេខ។

[០៩:០៦:២៥]

កថាខណ្ឌ៩៤៖ អង្គភាពសារទូរលេខដែលត្រូវបានបែងចែកជាពីរផ្នែក មួយផ្នែកទទួលខុសត្រូវសម្រាប់ការបញ្ជូនសារនិងទទួលសារទូរលេខ និងមួយផ្នែកទៀតទទួលខុសត្រូវសម្រាប់ការដាក់លេខសម្ងាត់និងបកប្រែខ្លឹមសារសារទូរលេខ ត្រូវបានដាក់លេខសម្ងាត់ថាជា ក-១៨។ មន្ទីរនេះមានទីតាំងនៅទីក្រុងភ្នំពេញនៅឯអតីតស្ថានទូតសហរដ្ឋអាមេរិក បច្ចុប្បន្នជារដ្ឋបាលជលផល។ មន្ទីរ ក-១៨ រួមមានផ្នែកទំនាក់ទំនងក្នុងប្រទេសដែលមាន (លុប) ជាអ្នកទទួលខុសត្រូវ និងផ្នែកទំនាក់ទំនងក្រៅប្រទេសដែលមានឈ្មោះ (លុប) ជាអ្នកទទួលខុសត្រូវ។ មានមនុស្សប្រហែលពី ២០-៣០ នាក់ បានធ្វើការងារនៅក្នុងផ្នែកនីមួយៗ។ ប្រធានផ្នែកសារទូរលេខក្រោយមកទៀត មានឈ្មោះ (លុប) ត្រូវបានគេស្គាល់

ថាជាអនុប្រធាន និង (លុប) នាឆ្នាំ១៩៧៩។

[១០:០៧:៥០]

កថាខណ្ឌ៩៥៖ នៅតាមភូមិភាគនានាអង្គភាពសារទូរលេខ រួមមាន អ្នកបកប្រែ និងដាក់លេខសម្ងាត់សារទូរលេខ អ្នកបញ្ជូនសារទូរលេខ ឬអ្នកប្រតិបត្តិការ និងម្នាក់ផ្សេងទៀតជាលេខា ឬវាយអត្ថបទ។

កថាខណ្ឌ៩៦៖ សារទូរលេខដែលផ្ញើចេញពីមជ្ឈិម ជាដំបូងត្រូវផ្ញើមកផ្នែកបកប្រែសារទូរលេខដែលមានទីតាំងនៅមន្ទីរមជ្ឈិមបក្ស ក-១ ដើម្បីបកប្រែទៅជាលេខកូដសម្ងាត់។ បន្ទាប់មក សារដែលមានលេខកូដសម្ងាត់នោះ ត្រូវបញ្ជូនបន្តទៅក្រុមប្រតិបត្តិការនៅ ក-១៨ ដែលជាអ្នកត្រូវបញ្ជូនសារនោះជាលេខកូដសម្ងាត់ទៅអ្នកទទួលដែលជាអ្នកបកប្រែទៅជាខ្លឹមសារអត្ថបទធម្មតា។ សារទូរលេខដែលផ្ញើចូលពីភូមិភាគនានា ដំបូងត្រូវចូលទៅ ក-១៨ ដើម្បីឲ្យក្រុមអ្នកវាយអត្ថបទបំប្លែងជាលាយលក្ខណ៍អក្សរ ហើយបន្ទាប់មកសារជាលេខកូដសម្ងាត់នោះត្រូវបានបញ្ជូនទៅ ក-១ ដើម្បីបកប្រែសារទូរលេខហើយត្រូវបញ្ជូនទៅកម្មាភិបាលបក្សដែលជាអ្នកទទួល។

សារទូរលេខទាំងអស់ដែលបានទទួល ត្រូវបញ្ជូនទៅកម្មាភិបាលផ្សេងទៀតតាមសេចក្តីសម្រេចរបស់ ប៉ុល ពត និងសហការីរបស់គាត់ ដែលអ្នកទាំងនោះបានទទួលការចម្លងជូនគ្រប់សារ។ ពាក្យថា "ឯកសារ" ដែលនៅលើសារទូរលេខមានន័យថា សារទូរលេខនេះត្រូវតែរក្សាទុកនៅក្នុងបណ្ណសាររបស់អ្នកបកប្រែសារទូរលេខ។ ឯកសារជាលេខសម្ងាត់ និងឯកសារបកប្រែជាអក្សរ នៃសារទូរលេខត្រូវបានរក្សាទុករយៈពេលប្រាំមួយខែ មុនពេលត្រូវបានដុតចោល។

[១០:១០:១៦]

កថាខណ្ឌ៩៧៖ ឈ្មោះសម្ងាត់របស់អ្នកទទួលខាងក្រោមនេះត្រូវបានប្រើញឹកញាប់នៅក្នុងសារទូរលេខ៖

- អ៊ំ សម្រាប់ ប៉ុល ពត
- អ៊ំនួន សម្រាប់ នួន ជា
- អ៊ំវ៉ាន់ សម្រាប់ អៀង សារី
- បងវ៉ន សម្រាប់ វន វេត
- អ៊ំហែម សម្រាប់ ខៀវ សំផន

- បងជាទីគោរពសម្រាប់ ប៉ុល ពត
- ក-៣ សម្រាប់មន្ទីររបស់ ខៀវ សំផន និង នួន ជា
- ក-១ សម្រាប់មន្ទីររបស់របស់ប៉ុល ពត។

[១០:១០:៥៤]

កថាខណ្ឌ៩៨៖ លេខ៨៧០ ត្រូវបានបញ្ជាក់ដោយសាក្សីជាច្រើនថា ជាលេខសម្ងាត់របស់មជ្ឈិម។ ទាក់ទងនឹងរឿងនេះជនត្រូវចោទ ខៀវ សំផន បានបញ្ជាក់ថា ប៉ុល ពត ចុះហត្ថលេខាលើឯកសារដោយដាក់លេខ៨៧០។ ពាក្យ "ម-៨៧០" ត្រូវបានបញ្ជាក់ដោយសាក្សីជាច្រើនថា ជាលេខសម្ងាត់របស់មន្ទីរគណៈមជ្ឈិម ឬចួនកាលជារបស់ នួន ជា និង ចួនកាលជារបស់ ប៉ុល ពត។ ពាក្យ "គណៈ៨៧០" សំដៅទៅលើគណៈមជ្ឈិម។ យោងតាមចម្លើយជនត្រូវចោទ ឌុច សារទូរលេខ ឬក៏សំបុត្រណាដែលមានដាក់ឈ្មោះ ប៉ុល ពត ដោយឈ្មោះ ប៉ុល ៨៧០ ឬមន្ទីរ៨៧០ ទាំងអស់នេះ សុទ្ធតែសំដៅទៅលើ ប៉ុល ពត។

**ឯកសារនយោបាយ និងអប់រំ ការបោះពុម្ពផ្សាយ៖**

កថាខណ្ឌ៩៩៖ ទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត គឺជាទស្សនាវដ្ដីមានសារៈសំខាន់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការផ្សព្វផ្សាយ ហើយបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់បក្ស។ ជាពិសេសទស្សនៈរបស់គណៈអចិន្ត្រៃយ៍ ទោះជាក្នុងរបបនោះមានទស្សនាវដ្ដីផ្សេងៗទៀតក៏ដោយ។

[១០:១២:៤៧]

ទស្សនាវដ្ដីនេះត្រូវបានបោះពុម្ពនៅមន្ទីរ ក-២៥ ដោយក្រសួងឃោសនាការ។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ និងរហូតដល់មានការចាប់ខ្លួនគាត់នៅក្នុងឆ្នាំ១៩៧៧ ហ៊ូ នឹម គឺជារដ្ឋមន្ត្រីក្រសួងឃោសនាការ។ បន្ទាប់ពីការចាប់ខ្លួនគាត់មក យុន យ៉ាត បានគ្រប់គ្រងក្រសួងឃោសនាការនេះ។

កថាខណ្ឌ១០០៖ នៅខណៈដែលទស្សនាវដ្ដីទង់បដិវត្តមានអត្ថិភាព ឡើងជាទស្សនាវដ្ដីសម្ងាត់ដែលលាក់កំបាំងនានា-- ដែលលាក់កំបាំងនាមុនឆ្នាំ១៩៧៥ ទស្សនាវដ្ដីនេះបានក្លាយជាការបោះពុម្ពផ្សាយផ្លូវការរបស់បក្សដែលត្រូវបានប្រើក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:១៣:៤៩]

កថាខណ្ឌ១០១៖ ទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត គឺជាឧបករណ៍

ឃោសនាមួយដែលត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងអំពីនយោបាយរបស់បក្សមួយដងក្នុងមួយខែ។ មានតែបក្ខជនទេដែលមានសិទ្ធិទទួលបាននូវទស្សនាវដ្ដីទាំងនោះ ហើយទស្សនាវដ្ដីទាំងនោះត្រូវបានផ្សព្វផ្សាយដើម្បីបង្រៀនដល់កម្មាភិបាលទាំងផ្នែកនយោបាយ និងយោធា។

ពួកគេត្រូវសិក្សារៀនសូត្រពីទស្សនាវដ្ដីទាំងនោះ ហើយត្រូវផ្សព្វផ្សាយគោលនយោបាយដែលមាននៅក្នុងទស្សនាវដ្ដីទាំងនោះទៅអ្នកដែលស្ថិតនៅក្រោមបង្គាប់របស់ខ្លួន និងត្រូវអនុវត្តនូវគោលនយោបាយទាំងនោះ។ ពួកគេត្រូវចូលរួមវគ្គសិក្សាស្ដីអំពីទស្សនាវដ្ដីនោះផងដែរ។ ទស្សនាវដ្ដីយុវជនយុវនារីបដិវត្តត្រូវបានចែកចាយដល់សមាជិកនៃសម្ព័ន្ធយុវជន។

[១០:១៥:០០]

កថាខណ្ឌ១០២៖ ទស្សនាវដ្ដីទាំងនោះ មានឥទ្ធិពលគ្រប់ដណ្ដប់លើគ្រប់ប្រព័ន្ធទំនាក់ទំនងការងារ ជាសាធារណៈរបស់រដ្ឋាភិបាល។ ខ្លឹមសារនៃការផ្សព្វផ្សាយតាមវិទ្យុត្រូវបានដកស្រង់ពីអត្ថបទនានាដែលមានក្នុងនោះ។ ឯកសារទស្សនាវដ្ដីទង់បដិវត្តជាច្រើនច្បាប់ត្រូវបានប្រទះឃើញផងដែរនៅក្នុងមន្ទីរស-២១ និងនៅផ្ទះជុំវិញបរិវេណនោះ។ ឌុច ខ្លួនឯងក៏បានបញ្ជាក់ថាគាត់បានប្រើប្រាស់ទស្សនាវដ្ដីទង់បដិវត្តសម្រាប់ជាព័ត៌មានស្ដីពីមាគ៌ានយោបាយទូទៅរបស់បក្ស។ ភស្ដុតាងបានបង្ហាញផងដែរថា ទស្សនាវដ្ដីត្រូវបានទទួលដោយមន្ទីរ៨៧០ ព្រមទាំងត្រូវបានផ្សព្វផ្សាយទៅបរទេសតាមរយៈស្ថានទូតខ្មែរប្រចាំប្រទេសចិន។

[១០:១៦:០២]

កថាខណ្ឌ១០៣៖ ទស្សនាវដ្ដីទាំងនេះក៏ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការបង្រៀនជាពិសេសបង្រៀនដោយ នួន ជា និង អៀង សារី។ វគ្គសិក្សារៀនសូត្រទូទៅជាច្រើន ត្រូវបានធ្វើឡើងដើម្បីប្រមូលផ្ដុំ និងអប់រំឲ្យយុវជននិងយុវនារីដើម្បីចូលរួមបដិវត្តន៍។ យោងតាមសាក្សីមួយចំនួនគោលការណ៍ណែនាំនៅក្នុងទស្សនាវដ្ដីត្រូវបានបង្ហាញពីរបៀបធ្វើការដ៏ហ្មត់ចត់ ហើយប្រសិនបើមនុស្សណាម្នាក់មិនសម្របខ្លួនតាមខ្លឹមសារទស្សនាវដ្ដីទេនោះ អ្នកនោះនឹងត្រូវចាត់ទុកថាជាខ្មាំងដោយស្វ័យប្រវត្តិ។ ហើយសារៈសំខាន់គឺថា បុគ្គលដែលប្រឆាំងនឹងបក្សត្រូវបានចាត់ទុកថាខ្មាំង។

កថាខណ្ឌ១០៤៖ សាក្សីម្នាក់បញ្ជាក់ថានៅក្នុងហេតុការណ៍មួយនោះ ខិត្តប័ណ្ណដែលត្រូវបានបោះពុម្ពនៅឯ ក-២៥ ត្រូវបានទម្លាក់ពីលើយន្តហោះនៅក្នុងភូមិភាគបូព៌ា ហើយមានខ្លឹមសារចោទប្រកាន់ សោ ភឹម ថាជាជនក្បត់ និងអំពាវនាវឲ្យប្រជាជនកុំមានការភ្ញាក់ផ្អើល។

[១០:១៧:២៦]

**ខ្សែភាពយន្ត និងការថតរូប៖**

កថាខណ្ឌ១០៥៖ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយច្បាស់លាស់លើវិស័យភាពយន្ត។ គោលបំណងនៃខ្សែភាពយន្ត គឺដើម្បីបង្ហាញពីជោគជ័យរបស់វណ្ណៈកសិករ និងផ្សព្វផ្សាយសេចក្តីណែនាំដ៏ច្បាស់លាស់មួយដែលនៅក្នុងនោះ តើត្រូវថតអ្វី? យើងត្រូវថតយកចលនានៃការកសាងប្រទេស ការពារប្រទេស ជាពិសេសការកសាងប្រទេសនៅជនបទ។ យើងថតសកម្មភាពធ្វើតាំងពីគេចាប់ផ្តើមធ្វើ ដល់គេធ្វើហើយក៏យើងថតទៀត។

កថាខណ្ឌ១០៦៖ ការថតខ្សែភាពយន្តត្រូវបានគេមើលឃើញថា ជាមធ្យោបាយមួយដ៏សំខាន់ក្នុងការធ្វើឱ្យមហាជនចូលពាក់ព័ន្ធនៅក្នុងគោលនយោបាយរបស់បក្ស ដូចដែលបានលើកឡើងនៅក្នុងអង្គប្រជុំការងារនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦។

និយាយជាទូទៅ ការថតខ្សែភាពយន្តគឺជាបញ្ហាសំខាន់មួយ មហាជនទាមទារណាស់ បើគេមើលឃើញពីបច្ចុប្បន្នភាព ពួកគេរីករាយណាស់ដោយសារពួកគេបង្ហាញពីស្នាដៃ ហើយពួកគេជាអ្នកតំណាងលើកិច្ចការរបស់ពួកគេផ្ទាល់។

[១០:១៨:៥៩]

កថាខណ្ឌ១០៧៖ ការថតរូបត្រូវបានគេមើលឃើញថា ជាបញ្ហាសំខាន់បន្ទាប់ពីការថតភាពយន្ត ហើយមានការណែនាំតែមួយគត់ថា ត្រូវថតរូបភាពពិធីផ្សេងៗ ឬភ្ញៀវបរទេសដើម្បីទុកជាឯកសារ។ មានផ្នែកថតរូប និងផ្នែកភាពយន្តនៅសាលាបច្ចេកទេសសូវៀត ដែលស្ថិតនៅក្រោមក្រសួងឃោសនាការ វិទ្យុ។

កថាខណ្ឌ១០៨៖ វិទ្យុត្រូវបានមើលឃើញដោយថ្នាក់ដឹកនាំថាជាវិធីសាស្ត្រដ៏ចម្បង ដើម្បីផ្សព្វផ្សាយទស្សនៈបដិវត្តន៍ក្នុងចំណោមប្រជាជន។ ទាក់ទងនឹងរឿងនេះ មានការផ្តល់គោលការណ៍ណែនាំលើរបៀបធ្វើការសម្ភាសន៍ប្រជាជននៅតាមភូមិភាគនានា និងលើរបៀបផ្សព្វផ្សាយព័ត៌មាន រួមទាំងលើខ្លឹមសារនៃកម្មវិធីផ្សេងៗផងដែរ។ អ្នកជំនាញការចិនត្រូវបានពិគ្រោះពិភាក្សាជាមួយ ពីការបង្កើតបច្ចេកទេសក្នុងការផ្សព្វផ្សាយតាមវិទ្យុ។

កថាខណ្ឌ១០៩៖ ក្នុងឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាមានស្ថានីយវិទ្យុចល័តមួយនៅស្រុកស្ទឹងត្រង់។ ចម្រៀងត្រូវបានគេថតនៅស្ទឹងត្រង់ ហើយត្រូវបញ្ជូនទៅស្ថានីយ៍វិទ្យុរួបរួមជាតិកម្ពុជានៅទីក្រុង

ហាណូយ ដែលត្រូវបានដឹកនាំដោយ អៀង ធីរិទ្ធ។ នៅខណៈដែលការងារបច្ចេកទេសត្រូវបានផ្ដល់ឲ្យដោយជនជាតិវៀតណាម។ អង្គភាពវិទ្យុចល័តបានដំណើរការនិងផ្សព្វផ្សាយជាធម្មតា នៅក្នុងអំឡុងពេលធ្វើការជម្លៀសប្រជាជនពីភ្នំពេញ ហើយក្រោយមកអង្គភាពនេះត្រូវបានផ្ទេរមកកាន់រដ្ឋធានី ហើយក្លាយជាអង្គភាពផ្សព្វផ្សាយតែមួយគត់នៅក្នុងប្រទេស។

[១០:២១:០៥]

កថាខណ្ឌ១១០៖ ក្រសួងឃោសនាការមានផ្នែកនិពន្ធ ផ្នែកសម្ភាស ផ្នែកសរសេរអត្ថបទ និងផ្នែកពិនិត្យកែសម្រួល។ ការផ្សាយវិទ្យុរួមមានដំណឹងអន្តរជាតិដកស្រង់ពីវិទ្យុបរទេស និងព័ត៌មានក្នុងស្រុកដែលត្រូវបានផ្សព្វផ្សាយដោយក្រសួង ដែលផ្សាយជាចម្បងជុំវិញរឿងការសរសើរសហករណ៍ជនបទ និងសមិទ្ធិផលរបស់របប ពន្យល់ពីមាគ៌ារបស់បក្ស និងសុន្ទរកថាថ្នាក់ដឹកនាំនានា ការការពារប្រទេស និងការអប់រំប្រជាជនផងដែរ។

កថាខណ្ឌ១១១៖ មានព័ត៌មានត្រូវបានដកស្រង់ពីប៉ុស្តិ៍វិទ្យុវៀតណាម ចិន ឡាវ និងប្រទេសថៃ។ ប៉ុន្តែមិនមានព័ត៌មានណាដែលមានលក្ខណៈទិតៀនដល់របបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្សព្វផ្សាយនោះទេ។ មានការផ្សាយជាភាសាអង់គ្លេស និងភាសាវៀតណាម។ កម្មវិធីផ្សាយជាភាសាថៃត្រូវបានគ្រោងទុកផងដែរ។ កម្មវិធីវិទ្យុ ពិសេសសម្រាប់ជនជាតិខ្មែរដែលរស់នៅវៀតណាម ដែលបក្សកុម្មុយនីស្តកម្ពុជាហៅថា "កម្ពុជាក្រោម" បានផ្សព្វផ្សាយព័ត៌មានស្តីអំពីជម្លោះព្រំដែនខ្មែរ-វៀតណាម និងការផ្លាស់ទីលំនៅរបស់ខ្មែរកម្ពុជាក្រោម មកភ្នំដនរបស់កម្ពុជា ព្រមទាំងការធ្វើទុក្ខបុកម្នេញដែលត្រូវបានសន្មតថា វៀតណាមបានប្រព្រឹត្តមកលើខ្មែរក្រោមទាំងនោះ។

កថាខណ្ឌ១១២៖ ចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាមជាច្រើន ដែលត្រូវបានគេសួរចម្លើយនៅមន្ទីរស-២១ ត្រូវបានគេចាក់ផ្សាយតាមវិទ្យុ ដើម្បីបង្ហាញថា ជនជាតិវៀតណាមបានឈ្លានពានយកទឹកដីកម្ពុជា។ សាក្សីបញ្ជាក់ថា ឈ្លើយសឹកវៀតណាមត្រូវបានសួរចម្លើយនៅសមរភូមិ និងថាការថតសំឡេង ការសួរចម្លើយនោះត្រូវបានផ្ញើមកវិទ្យុដើម្បីចាក់ផ្សាយ។

[១០:២៣:៤០]

**តួនាទី និងមុខងារ៖ សមាជិកគណៈមជ្ឈិម និងសមាជិកគណៈអចិន្ត្រៃយ៍**

កថាខណ្ឌ៨៦៩៖ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា គឺជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម។ នួន ជា បានកាន់តួនាទីជាអនុលេខាមជ្ឈិមបក្សតាំងពី១៩៦០ និងត្រូវបានតែងតាំងជាអនុលេខា

ដដែលនៅឆ្នាំ១៩៦៣។ ក្នុងអំឡុងពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា នៅតែមានតួនាទីជាអនុលេខាមជ្ឈិមបក្ស។ ទោះបីជាគាត់ពិតជាបានកាន់តួនាទីនេះនៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ គាត់ត្រូវបានប្រកាសជាសាធារណៈ ថាជាអនុលេខាគណៈមជ្ឈិម នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុណ្ណោះ ដំណាលពេលដែលអត្ថិភាពរបស់បក្សត្រូវបានប្រកាសឲ្យដឹងជាផ្លូវការ។

[១០:២៤:៥៧]

កថាខណ្ឌ៨៧០៖ ក្នុងឋានៈជាអនុលេខាមជ្ឈិមបក្ស នួន ជា គឺមនុស្សទី២ នៅក្នុងឋានានុក្រមបក្ស និងត្រូវបានស្គាល់ថា ជាបងធំទី២ និងជាដៃស្តាំរបស់ ប៉ុល ពត។ ក្នុងនាមជាសមាជិកពេញសិទ្ធិ នួន ជា អាចពិគ្រោះពិភាក្សា និងរួមមតិសម្រេចពាក់ព័ន្ធនឹងបញ្ហាទាំងអស់។ ឌុច យល់ឃើញថា នួន ជា ជាអ្នកទទួលខុសត្រូវអនុវត្តរាល់សេចក្តីសម្រេចធ្វើឡើងដោយ ប៉ុល ពត ខណៈដែលកម្មាភិបាលជាន់ខ្ពស់ឈ្មោះ (លុប) ពន្យល់ថា ប៉ុល ពត មិនអាចសម្រេចតែម្នាក់ឯងបានទេ។ នួន ជា ប្រាប់នៅក្នុងបទសម្ភាសន៍មួយដែលឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យថា "រួមគ្នាទាំងអស់ គាត់ ប៉ុល ពត ក៏រួមចំណែក យើងខ្ញុំក៏រួមចំណែក"។ ប៉ុន្តែនៅក្នុងបទសម្ភាសន៍មួយទៀត នួន ជា បញ្ជាក់ថា "ប៉ុល ពត ជាលេខាបក្ស គឺខ្ញុំជាអនុលេខាទេ ប៉ុន្តែអនុលេខាតាមបញ្ជាគេដែរ"។

កថាខណ្ឌ៨៧១៖ នួន ជា ក៏ជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា។ យោងតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានចែងថា ក្នុងថ្នាក់ជាលេខា និងអនុលេខានៃសាខាបក្សដែលមានសមាជិកតិចតួច ដូចជាគណៈអចិន្ត្រៃយ៍នេះ ប៉ុល ពត និង នួន ជា ទទួលខុសត្រូវចាត់ចែងការងារប្រតិបត្តិការ នៅក្នុងចន្លោះពេលពីការប្រជុំមួយ ទៅមួយទៀតរបស់គណៈអចិន្ត្រៃយ៍។

[១០:២៦:៥៧]

នៅក្នុងចំណោមកំណត់ហេតុអង្គប្រជុំចំនួន១៩ របស់គណៈអចិន្ត្រៃយ៍ដែលនៅសល់ មានកំណត់ហេតុចំនួន១៥ ដែលបានបញ្ជាក់ពីវត្តមានអ្នកចូលរួម។ នួន ជា ត្រូវបានកត់ត្រាថា មានវត្តមានចំនួន១៤ដង។ ដូចនេះ ហាក់ដូចជាបង្ហាញថា នួន ជា បានចូលរួមប្រជុំជាច្រើន ឬស្ទើរតែគ្រប់ពេលប្រជុំទាំងអស់។ តាមការឲ្យដឹងរបស់ ខៀវ សំផន គណៈអចិន្ត្រៃយ៍ជួបប្រជុំជាទៀងទាត់ប្រហែលពីប្រាំពីរ ទៅដប់ថ្ងៃម្តង និងអាចញឹកញាប់ជាងនេះ ក្នុងករណីបន្ទាន់។ នៅរាល់ពេលប្រជុំនោះ នួន ជា ផ្តល់យោបល់សេចក្តីណែនាំ និងបទបញ្ហាផ្សេងៗ។ រាល់ទំនាក់ទំនង-- វាទំនងជាថា នួន ជា បានដឹកនាំប្រជុំគណៈ

អចិន្ត្រៃយ៍នៅពេលដែល ប៉ុល ពត អវត្តមាន។

កថាខណ្ឌ៨៧២៖ នៅក្នុងតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍ និងសមាជិកគណៈមជ្ឈិម នួន ជា បានចូលរួមប្រជុំកម្រិតខ្ពស់នានារបស់បក្សកុម្មុយនីស្តកម្ពុជាជាទៀងទាត់ ដើម្បី-- (សុំទោស) ជាទៀងទាត់ ដែលធ្វើជាប្រចាំនៅ ក-១ និងក-៣ និងបានជួបប្រជុំប្រចាំខែនៅមន្ទីរក-១ ជាមួយនឹងកម្មាភិបាលថ្នាក់ដឹកនាំមកពីបណ្តាភូមិភាគ តំបន់ ព្រមទាំងគណៈស្រុក ដែលការប្រជុំនេះ មានរយៈពេលពីប្រាំ ទៅប្រាំមួយថ្ងៃ ដោយមានកម្មាភិបាលប្រហែល ២០រូប។ នួន ជា ក៏បានជួបជាញឹកញាប់នៅក្រៅទីក្រុងភ្នំពេញ ជាមួយមេដឹកនាំតំបន់ស្វយ័ត និងមេដឹកនាំភូមិភាគ ជាពិសេសនៅពេលសន្និបាតតាមតំបន់ និងភូមិភាគ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។

ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះសូមប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណ ហើយសូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម។ ហើយនៅពេលនេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងសវនាការទាក់ទងប្រធានបទនេះ សម្រាប់ថ្ងៃនេះ ដោយសូម-- ប៉ុន្តែសូមចូលរួមសវនាការនេះ នៅបន្ទប់រង់ចាំខាងក្រោម។

អាស្រ័យហេតុនេះ-- ពីព្រោះបញ្ហាសុខភាពទាន។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣០:៤៥]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តី

របស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ នៅព្រឹកនេះដោយមូលហេតុបញ្ហាសុខភាព។

អង្គជំនុំជម្រះយល់ឃើញថា បញ្ហានៃកិច្ចដំណើរការសវនាការនេះ គឺការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ចំពោះជនជាប់ចោទ នៅក្នុងអង្គហេតុវគ្គពីរនៃសំណុំរឿង០០២/០១។ ដូច្នេះ វត្តមានរបស់ជនជាប់ចោទនៅក្នុងកិច្ចដំណើរការសវនាការនេះគឺជាការចាំបាច់។ ដូច្នេះ អង្គជំនុំជម្រះបដិសេធនូវសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់ខ្លួន មិនចូលសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយសុំបន្តទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍សម្រាប់សប្ដាហ៍នេះ-- អ៎!សម្រាប់ព្រឹកនេះ ហើយអង្គជំនុំជម្រះបង្គាប់ឲ្យមានវត្តមានជនជាប់ចោទ អៀង សារី នៅក្នុងអំឡុងពេលនៃដំណើរការសវនាការ ក្រឡាបញ្ជីអាននូវផ្នែកកថាខណ្ឌនៃបទចោទប្រកាន់សម្រាប់វគ្គពីរ នៃសំណុំរឿង០០២/០១ រហូតដល់ចប់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៧ នាទី)*

[១០:៥៦:៥៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

[១០:៥៧:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ជាបន្តនេះសូមអញ្ជើញលោក ដាវ អានសាន ឡើងអានបន្តនូវបណ្ដាកថាខណ្ឌដែលត្រូវអាននៅព្រឹកនេះ ពាក់ព័ន្ធជាមួយនឹងវគ្គពីរ នៃសំណុំរឿង០០២/០១។

សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

**សមាជិកគណៈចាត់តាំងមជ្ឈិម និងការទទួលខុសត្រូវលើការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ៖**

កថាខណ្ឌ៨៨០៖ នួន ជា ទទួលខុសត្រូវខាងគណៈចាត់តាំងមជ្ឈិមបក្សដែលមានអំណាចតាមដាន និងត្រួតពិនិត្យសមាជិកបក្សទាំងអស់ និងពិនិត្យការតែងតាំងបុគ្គលិកថ្មីនៅក្នុងមន្ទីរ និងក្រសួងនានា។ ឌុច យល់ឃើញថា នួន ជា ទទួលខុសត្រូវលើការជ្រើសរើស និងតែងតាំងសមាជិកថ្មី និងលើការតែងតាំងកម្មាភិបាល និងសមាជិកឱ្យកាន់តួនាទីផ្សេងៗ។ នៅពេលណាដែលមានការដំឡើងថ្នាក់នរណាម្នាក់ គឺអ្នកផ្សេងទៀតត្រូវបានដកចេញមានន័យថា "កម្ទេច" ។ នួន ជា បានចូលរួមក្នុងការតែងតាំងលេខាតំបន់ ឬភូមិភាគជាពិសេសដូចជាការតែងតាំង (លុប) ជាលេខាតំបន់ស្វយ័ត ១០៥។ ការតែងតាំង កង ចាប ហៅ សែ ជាលេខាភូមិភាគឧត្តរថ្មី។ នួន ជា ប្រកាសបង្កើតភូមិភាគឧត្តរ និងការតែងតាំង (លុប) ជាលេខាតំបន់១០៣។ ក្នុងបទសម្ភាសន៍ធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិប-តេយ្យ នួន ជា ឆ្លើយនឹងសំណួរដែលសួរថា តើលោកបានដោះស្រាយបែបដូចម្ដេចចំពោះសមមិត្តដែលមិនល្អ ដោយនិយាយថា ខ្ញុំបានធ្វើការអប់រំកែប្រែពួកគេ ហើយមិនអនុញ្ញាតឱ្យពួកគេស្ថិតនៅក្នុងមុខតំណែងរបស់ពួកគេទេ។

[១០:៥៩:៤៧]

កថាខណ្ឌ៨៨១៖ នៅឯកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នាថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ នួន ជា ត្រូវបានគេឱ្យទទួលខុសត្រូវការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ។ ឌុច យល់ថាសេចក្ដីសម្រេចនេះបានតែងតាំង នួន ជា ជាអ្នកទទួលខុសត្រូវក្រសួងចំនួនបួន ដូចជា ក្រសួងឃោសនាការ ក្រសួងអប់រំ ក្រសួងសង្គមកិច្ច និងក្រសួងវប្បធម៌។ ឌុច ពន្យល់ថា ហេតុផលនៃការតែងតាំងនេះដោយសារតែរដ្ឋមន្ត្រីទាំងបួន ដែលដឹកនាំក្រសួងទាំងនោះមិនមែនជាសមាជិកពេញសិទ្ធិរបស់គណៈមជ្ឈិម។

[១១:០០:៣៨]

កថាខណ្ឌ៨៨២៖ ចំពោះការងារបក្ស ឃោសនាការ និងសិក្សាធិការ សេចក្ដីសម្រេចនេះ បានធ្វើឱ្យ នួន ជា ក្លាយជាអ្នកទទួលខុសត្រូវចម្បង ក្នុងការផ្សព្វផ្សាយមាគ៌ានយោបាយ ដែលសម្រេចដោយបក្ស ទៅដល់សមាជិកបក្សកុម្មុយនីស្តកម្ពុជា យោធា និងមហាជន។

កថាខណ្ឌ៨៨៣៖ រដ្ឋមន្ត្រីដំបូងនៃក្រសួងព័ត៌មាន និងឃោសនាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឈ្មោះ ហ៊ូ នឹម ដែលគាត់ត្រូវបានចាប់ខ្លួននិងបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ នាខែមេសា ឆ្នាំ១៩៧៧។ បន្ទាប់មកក្រសួងនេះត្រូវបានរៀបចំឡើងវិញ និងច្របាច់បញ្ចូលគ្នាជាមួយនឹងក្រសួងវប្បធម៌ អប់រំ និងសិក្សាធិការ ដែលមាន យុន យ៉ាត ប្រពន្ធរបស់ សុន សេន ជារដ្ឋមន្ត្រី និងក្រោយមក យុន យ៉ាត បានក្លាយជារដ្ឋមន្ត្រីកាន់ក្រសួងទាំងពីរនេះ។ លើសពីនេះទៀត នៅខណៈពេលដែលសារ-ព័ត៌មានផ្លូវការបានផ្សាយថា យុន យ៉ាត កាន់ក្រសួងនេះ យ៉ាងហោចណាស់រហូតដល់ខែមករា ឆ្នាំ១៩៧៩ ប៉ុន្តែមានសាក្សីពីររូបដែលធ្លាប់ធ្វើការនៅក្នុងក្រសួងនោះបានបញ្ជាក់ថា នួន ជា ក្លាយជារដ្ឋមន្ត្រីក្រសួងអប់រំ និងព័ត៌មាន ចាប់ពីចុងឆ្នាំ១៩៧៨ រហូតដល់ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ។

កថាខណ្ឌ៨៨៤៖ នួន ជា បានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា នាថ្ងៃទី ៩ ខែមករា ឆ្នាំ១៩៧៦ ដែលនៅពេលប្រជុំនោះ គុណសម្បត្តិ និងការខ្វះខាតកម្មវិធីឃោសនាអប់រំ ត្រូវបានលើកយកមកពិភាក្សា។ តាមរយៈកំណត់ហេតុនៃការប្រជុំការងារឃោសនាការដែលបានបន្សល់ទុក មានភស្តុតាងបង្ហាញឲ្យឃើញផងដែរថា មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា បានតាមដានយកចិត្តទុកដាក់អំពីមធ្យោបាយឃោសនា និងបានចេញសេចក្តីសម្រេចផ្សេងៗអំពីបញ្ហានេះ។

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ នៅក្នុងកិច្ចប្រជុំស្តីអំពីការងារឃោសនាការ ដែលមានវត្តមានរបស់ នួន ជា បញ្ហាផ្សាយតាមវិទ្យុអំពីការបោះឆ្នោត ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ត្រូវបានពិភាក្សាយ៉ាងពិស្តារ រួមមានទាំងខ្លឹមសារផ្សាយ និងពេលវេលាផ្សាយ ដែលបង្ហាញឲ្យឃើញថា នួន ជា មានពាក់ព័ន្ធក្នុងដំណើរការធ្វើសេចក្តីសម្រេចទាក់ទិននឹងការផ្សព្វផ្សាយទាំងនោះ។

[១១:០៣:២៧]

នៅក្នុងកិច្ចប្រជុំមួយទៀត ធ្វើឡើងនាថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ ដោយមានវត្តមានផងដែររបស់ នួន ជា រាល់ទិដ្ឋភាពនៃការងារឃោសនាការរបស់បក្សកុម្មុយនីស្តកម្ពុជា ការផ្សាយតាមវិទ្យុ ការបោះពុម្ពផ្សព្វផ្សាយ និងភាពយន្តឃោសនា ត្រូវបានពិភាក្សាជាមួយនឹងកម្មាភិបាលមកពីក្រសួងឃោស-នាការ។ នៅក្នុងកិច្ចប្រជុំនោះ នួន ជា បានផ្តល់ការណែនាំ និងយោបល់ទៅលើទិដ្ឋភាពចំៗនៃការងារឃោសនាការ។ មានភស្តុតាងបង្ហាញផងដែរថា នួន ជា មានអំណាចណែនាំថ្នាក់ក្រោមអំពីបញ្ហាព័ត៌មាន និងឃោសនាការ។

កថាខណ្ឌ៨៨៥៖ នៅក្នុងបទសម្ភាសន៍មួយ នួន ជា ទទួលស្គាល់ថា នៅមុនថ្ងៃទី១៧ ខែសីហា

ឆ្នាំ១៩៧៥ គាត់ពិតជាបានដឹង និងមានការពាក់ព័ន្ធនឹងការបោះពុម្ព និងសរសេរទស្សនាវដ្ដីទង់បដិវត្ត ហើយគាត់បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំងនោះ។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានស្នើសុំដោយផ្ទាល់ឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាសរសេរអត្ថបទមួយចំនួន សម្រាប់ទស្សនាវដ្ដីឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា។

[១០:០៤:៥០]

កថាខណ្ឌ៨៨៦៖ នៅពេលបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបអង្កេត នួន ជា អះអាងថា គាត់ទទួលបន្ទុកអប់រំកម្មាភិបាល និងបក្ខជន។ ឌុច យល់ថាការទទួលខុសត្រូវរបស់ នួន ជា ក្នុងការងារបក្សមានន័យជាពិសេសថា នួន ជា ទទួលបន្ទុកកិច្ចការប្រចាំថ្ងៃនៅក្នុងបក្ស។ ខ្ញុំនៅចាំថា ការងារនយោបាយរបស់បក្សផ្ដោតសំខាន់លើការរៀនសូត្រប្រចាំឆ្នាំ ការអប់រំនយោបាយ សតិអារម្មណ៍ និងចាត់តាំង។ នៅរាជធានីភ្នំពេញ នួន ជា បានបង្រៀនវគ្គនយោបាយជាច្រើនដល់មហាជន ដោយបានបង្រៀនមាគ៌ា ឬគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ប្រជុំរៀនសូត្រនេះ ជាចម្បងធ្វើឡើងនៅបុរីកីឡា។ វគ្គរៀនសូត្រទាំងនោះ ត្រូវបានរៀបចំសម្រាប់កម្មាភិបាលនិងកម្មកររបស់បក្សនៅភ្នំពេញ ព្រមទាំងសម្រាប់កម្មាភិបាលផ្សេងៗមកពីកន្លែងនានានៅក្នុងប្រទេសកម្ពុជា។ ភូមិភាគ តំបន់ និងសមាជិក គណៈស្រុក ប្រធានសហករណ៍ និងលេខាគណៈឃុំមួយចំនួន។ នួន ជា បានចូលរួមប្រជុំដូចគ្នានេះជាមួយសមាជិកកងទ័ពបដិវត្តន៍កម្ពុជា។ វគ្គអប់រំនយោបាយទាំងនេះ អាចមានអ្នកចូលរួមរហូតដល់រាប់រយនាក់។ សមាជិកបក្សត្រូវចូលរួមវគ្គរៀនសូត្រនេះ យ៉ាងហោចណាស់ឲ្យបានម្ដងក្នុងមួយឆ្នាំ។ កម្មាភិបាលយោធា និងយោធាដែលឈរជើងនៅក្រៅទីក្រុងភ្នំពេញត្រូវបានហៅឲ្យចូលរួមវគ្គរៀនសូត្រទាំងនេះ តាមរយៈទូរលេខ និងលិខិតអញ្ជើញដែលធ្វើចេញដោយ នួន ជា។

[១១:០៦:៤៥]

សាក្សីមួយចំនួនបានរៀបរាប់ផងដែរថា នួន ជា បានធ្វើបទឧទ្ទេសនាមផ្សេងៗដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជានៅពេលសន្និបាតភូមិភាគ និងសន្និបាតនៅតំបន់ស្វយ័ត។ អតីតអនុកងពលលេខមួយបានប្រាប់ថា ជាធម្មតា ក្នុងសន្និបាតរបស់ភូមិភាគ គឺមានតា នួន ជា ឬតា ប៉ុល ពត គាត់បានចូលរួម។ សាក្សីខ្លះប្រាប់ថា បន្ទាប់មកវគ្គសិក្សារៀនសូត្រស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយសមាជិកបក្សដើម្បីណែនាំដល់ប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនឲ្យដើរតាមមាគ៌ារបស់បក្ស។

[១១:០៧:៣៥]

កថាខណ្ឌ៨៨៧៖ ចំពោះការងារសង្គមកិច្ច អៀង ធីរិទ្ធ ធ្លាប់មកជួបមេដឹកនាំមជ្ឈិមបក្ស និងជាពិសេសជួបជាមួយ នួន ជា និង ក-៣ និង/ឬ ក-១ ម្តង ឬពីរដងក្នុងមួយខែ។ នួន ជា មានវត្តមាននៅក្នុងអង្គប្រជុំស្តីអំពីការងារសង្គមកិច្ច និងសុខាភិបាល ដែលធ្វើឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ដោយនៅក្នុងអង្គប្រជុំនោះ អៀង ធីរិទ្ធ និងកម្មាភិបាលថ្នាក់ដឹកនាំរបស់ក្រសួងសង្គមកិច្ច បានរាយការណ៍យ៉ាងលម្អិត អំពីសកម្មភាពរបស់ក្រសួង និងមន្ទីរចំណុះផ្សេងៗរបស់ក្រសួង ហើយ នួន ជា បានផ្តល់មតិ យោបល់អំពីប្រធានបទផ្សេង ដែលបានពិភាក្សានៅក្នុងអង្គប្រជុំ។ នួន ជា បានធ្វើទស្សនកិច្ច និងបានមកប្រជុំនៅមន្ទីរពេទ្យមួយចំនួន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច និងបង្រៀនវគ្គអប់រំនយោបាយ ដល់បុគ្គលិករបស់ក្រសួង។

[១១:០៨:៥០]

**នាយករដ្ឋមន្ត្រីស្តីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ៖**

កថាខណ្ឌ៨៨៨៖ នួន ជា ត្រូវបានតែងតាំងជាផ្លូវការជានាយករដ្ឋមន្ត្រីស្តីទីរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ ដើម្បីជំនួស ប៉ុល ពត បន្ទាប់ពីការ មានការប្រកាសជាផ្លូវការរបស់បក្សថា ប៉ុល ពត សម្រាកជាបណ្តោះអាសន្នដើម្បីថែទាំសុខភាព។ ទោះជាយ៉ាងណាក៏ដោយចាប់តាំងពីថ្ងៃនោះរហូតដល់ខែធ្នូ ឆ្នាំ១៩៧៦ សេចក្តីសម្រេចនោះហាក់បីដូចជាមិនត្រូវបានអនុវត្តពេញលេញទេ ដោយសារក្នុងអំឡុងពេលនោះសារព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យនៅតែផ្សាយដដែលៗថា ប៉ុល ពត ជានាយករដ្ឋមន្ត្រី ហើយ នួន ជា មិនត្រូវបានគេផ្សាយថាជានាយករដ្ឋមន្ត្រីស្តីទីទេ។ លើកលែងតែនៅក្នុងឱកាសដ៏កម្រប៉ុណ្ណោះ។

[១១:១០:០០]

ចាប់ពីខែមករារហូត (សុំទោស) ចាប់ពីខែមករាដល់ខែកញ្ញា ឆ្នាំ១៩៧៧ នួន ជា ត្រូវបានប្រកាសជាសាធារណៈ និងជាញឹកញាប់ដោយសារព័ត៌មានបក្សកុម្មុយនីស្តកម្ពុជាថាជា "នាយករដ្ឋមន្ត្រីស្តីទី"។ ជាពិសេសនៅក្នុងសុន្ទរកថាដែលគាត់បានធ្វើឡើងនៅក្នុងខួបអនុស្សាវរីយ៍លើកទីប្រាំបួន នៃកងទ័ពបដិវត្តន៍កម្ពុជានាថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧។ នៅឆ្នាំបន្ទាប់ សុន្ទរកថាខួបអនុស្សាវរីយ៍ដូចគ្នានេះត្រូវបានធ្វើឡើងដោយ ប៉ុល ពត។

ស្ទើរតែគ្មានការនិយាយយោងជាសាធារណៈអំពី ប៉ុល ពត ក្នុងឋានៈគាត់ជានាយកមន្ត្រីនៅក្នុង

អំឡុងពេលនោះ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៧៧ ដែលជាថ្ងៃដែលគាត់ត្រូវបានគេដឹងឮជាសាធារណៈ ជាលើកដំបូងថាជា "លេខាបក្សកុម្មុយនីស្តកម្ពុជា" ។ ឌុច យល់ថាពេល នួន ជា បានធ្វើជានាយករដ្ឋមន្ត្រីស្តីទីមានន័យថា "លេខាបក្សស្តីទី"។

**ប្រធានសភាតំណាងប្រជាជននិងប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន៖**

កថាខណ្ឌ៨៨៩៖ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល នួន ជា មានតួនាទីជាប្រធានសភាតំណាងប្រជាជន និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជននេះ។ គាត់ត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នេះ នៅក្នុងសម័យប្រជុំសភាពេញអង្គលើកទីមួយដែលប្រារព្ធធ្វើឡើងនាថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦។

[១១:១១:៥៥]

កថាខណ្ឌ៨៩០៖ ក្នុងឋានៈជាប្រធានសភាតំណាងប្រជាជន និងប្រធានគណៈកម្មាធិការអចិ-ន្ត្រៃយ៍នៃសភាតំណាងប្រជាជននេះហើយ ដែល នួន ជា ភាគច្រើនត្រូវបានគេស្គាល់ជាសាធារណៈ។ នៅក្នុងតួនាទីទាំងនោះ នួន ជា បានដឹកនាំគណៈប្រតិភូរបស់បក្សកុម្មុយនីស្តកម្ពុជាទៅធ្វើទស្សនកិច្ចជាផ្លូវការទៅកាន់ប្រទេសចិន និងប្រទេសកូរ៉េខាងជើង ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៨ បានធ្វើទំនាក់ទំនងជាមួយមេដឹកនាំបរទេសនានា ព្រមទាំងបានចេញសេចក្តីថ្លែងការណ៍ជាផ្លូវការនានា។ នៅក្នុងការអនុវត្តជាក់ស្តែង តួនាទីជាប្រធានទាំងពីរនេះបាននាំមកនូវការទទួលខុសត្រូវតិចតួចប៉ុណ្ណោះ។ លើកលែងតែការអនុម័តសេចក្តីសម្រេចមួយចំនួន ដូចជាសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្តីពីការកាត់ផ្តាច់ទំនាក់ទំនងបណ្តោះអាសន្ន រវាងកម្ពុជា និងវៀតណាមចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។

[១១:១៣:១៧]

**តួនាទីផ្សេងទៀត៖**

កថាខណ្ឌ៨៩១៖ បន្ថែមលើអ្វីដែលបានលើកឡើងខាងលើ នួន ជា បានក្លាយជាលេខាតាមជាក់ស្តែងរបស់ភូមិភាគចំនួនពីរ បន្ទាប់ពីលេខារបស់ភូមិភាគទាំងនោះត្រូវបានចាប់ខ្លួន។ បន្ទាប់ពីការចាប់ខ្លួនលេខាភូមិភាគពាយ័ព្យឈ្មោះ ម៉ែន សាន ហៅ យ៉ា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ តួនាទីនេះត្រូវបានជំនួសដោយ អ៊ុំ ណេង ហៅ វី ហៅ វង់ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ និងបន្ទាប់មក ក៏ត្រូវបានជំនួសដោយ នួន ជា ក្នុងរយៈពេលខ្លីមួយ។ ឌុច និងសាក្សីមួយចំនួនបញ្ជាក់ថា នួន ជា បានក្លាយជា

លេខាភូមិភាគបូព៌ាក្នុងអំឡុងពេលមួយក្នុងខែមិថុនា ឆ្នាំ១៩៧៨ បន្ទាប់ពី សោ ភឹម ធ្វើអត្តឃាត។

[១១:១៤:១៥]

កថាខណ្ឌ៨៩២៖ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ នួន ជា រួមចំណែកទទួលខុសត្រូវមន្ទីរនយោបាយ៨៧០ និងមន្ទីរស-២១។

**តួនាទីនិងមុខងារសមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍៖**

កថាខណ្ឌ១០០១៖ លោក អៀង សារី ចូលរួមក្នុងគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៦០ និងគណៈអចិន្ត្រៃយ៍នៅឆ្នាំ១៩៦៣។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការទាំងពីរ។ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម អៀង សារី អាចពិគ្រោះពិភាក្សា និងរួមមតិសម្រេចទាក់ទងនឹងបញ្ហាទាំងអស់។

កថាខណ្ឌ១០០២៖ ក្នុងចំណោមកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ចំនួន១៩លើក ដែលនៅសល់មានតែ ១៥លើកតែប៉ុណ្ណោះ ដែលបញ្ជាក់ពីវត្តមានអ្នកចូលរួម មានការកត់ត្រាថា អៀង សារី ធ្លាប់បានចូលរួមចំនួន១០លើក។ គាត់ត្រូវបានកត់ត្រាថា ធ្លាប់បានចូលរួមក្នុងអង្គប្រជុំពិសេសរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាចំនួនម្តង។ តាមការពិត អៀង សារី ទំនងជាបានចូលរួមប្រជុំច្រើនជាងនេះ ព្រោះ ខៀវ សំផន និយាយថា គណៈអចិន្ត្រៃយ៍កោះប្រជុំរវាងប្រាំពីរទៅដប់ថ្ងៃម្តង ហើយប្រជុំកាន់តែញឹកញាប់ទៅទៀតនៅពេលចាំបាច់។

[១១:១៦:០៦]

ឯកសារដែលនៅសេសសល់ទាំងនោះ បង្ហាញថា អៀង សារី ធ្លាប់បានធ្វើបទឧទ្ទេសនាមលើបញ្ហានានាជាច្រើន ដូចជាផ្នែក ឧស្សាហកម្ម ពាណិជ្ជកម្ម ការដឹកជញ្ជូន ការចូលរួមនៅសន្និសីទបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ ជំនួយបរទេស ជម្លោះជាមួយប្រទេសវៀតណាម ការអំពាវនាវដល់ប្រជាជនកម្ពុជាដែលនៅបរទេសឲ្យវិលត្រឡប់ និងទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសដទៃទៀត។ ទាក់ទិនជាមួយនឹងអង្គប្រជុំដែលគាត់មិនបានចូលរួម អៀង សារី អាចនឹងទទួលបានកំណត់ហេតុអង្គប្រជុំដែលប្រហែលជាត្រូវបានធ្វើឡើងជាប្រចាំ។

កថាខណ្ឌ១០០៣៖ ក្នុងតួនាទីជាសមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ អៀង សារី បានចូលរួមការប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាជាទៀងទាត់នៅក-១ និងក-៣។ ជាពិសេសកិច្ចប្រជុំប្រចាំខែនៅក-១ ដែលមានរយៈពេល ៥-៦ថ្ងៃ ជាមួយគណៈភូមិភាគ គណៈតំបន់ និង/ឬគណៈស្រុក។

មានកម្មាភិបាលចំនួន២០រូប ចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះ។ អៀង សារី ក៏បានចូលរួមការប្រជុំប្រចាំឆ្នាំរវាងលេខាមជ្ឈិម និងលេខាភូមិភាគផងដែរ។

កថាខណ្ឌ១០០៤៖ អៀង សារី មានតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍ពេញមួយរយៈកាលនៃរបបគ្រប់គ្រងដោយបក្សកុម្មុនីយស្តកម្ពុជា និងនៅពេលដែលថ្នាក់ដឹកនាំបក្សនេះបានភៀសខ្លួនទៅនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

[១១:១៧:៥៨]

**ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស៖**

កថាខណ្ឌ១០០៥៖ ដំណើរការបង្កើតក្រសួងការបរទេស ដែលមានឈ្មោះសម្គាល់ ប-១ ស្ទើរតែត្រូវបានធ្វើឡើងភ្លាមបន្ទាប់ពីការចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ក្រសួងនេះត្រូវបានសម្ពោធជាផ្លូវការនៅខែធ្នូ ឆ្នាំ១៩៧៥។ ដំបូងឡើយ ប-១ មានទីតាំងស្ថិតនៅអាគារចំនួនពីរលើវិថីព្រះសីសុវត្ថិ តាមមាត់ទន្លេក្រុងភ្នំពេញ។ ក៏ប៉ុន្តែនៅឆ្នាំ១៩៧៦ ប-១ ត្រូវបានរើទៅនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ីវិញ។ ប-១ មានផ្ទះទទួលភ្ញៀវពីរកន្លែងទៀត គឺផ្ទះទីមួយនៅជិតវត្តភ្នំ និងផ្ទះទីពីរ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។

[១១:១៩:០០]

កថាខណ្ឌ១០០៦៖ សាក្សីម្នាក់អះអាងថា មានមនុស្សជាង ១.០០០នាក់ធ្វើការនៅប-១ ពីដំបូងគេជ្រើសរើសបុគ្គលិកពីក្រុមមនុស្សដែលមានភាពស័ក្តិសម ស្អាតស្អំ ដែលមន្ទីរ៨៧០ គ្រប់គ្រងដោយប៉ង់ និង ឌឿន ជាអ្នកជ្រើសរើសពីតាមភូមិភាគផ្សេងៗដោយផ្អែកលើវណ្ណៈ ឬសមត្ថភាព និងមកពីតាមមូលដ្ឋានបដិវត្តន៍ចាស់ៗ ដូចជាខេត្តព្រះវិហារ និងខេត្តកំពង់ចាម។ ក្រៅពីបុគ្គលិកដែលជ្រើសរើសពីបណ្តាភូមិភាគផ្សេងៗនោះ បុគ្គលិករបស់ប-១ ក៏រួមមានផងដែរ នូវបញ្ញាជនមួយចំនួន ដែលភាគច្រើននៃអ្នកទាំងនោះ បានវិលត្រឡប់ពីបរទេសមកកម្ពុជាវិញ។ ជាងនេះទៀត អៀង សារី ក៏បានជ្រើសរើសកុមារកម្មាភិបាលមួយចំនួន ដែលជាកុមារមិនបានទទួលការអប់រំ និងមានអាយុពី៨ ទៅ ១៥ឆ្នាំ។ មានពេលមួយប-១ បានរៀបចំវគ្គរៀនសូត្រកម្មាភិបាលបដិវត្តន៍ដល់កុមារ ដែលត្រូវបញ្ជូនទៅឲ្យរៀនសូត្រនៅទីនោះ។

[១១:២០:២០]

កថាខណ្ឌ១០០៧៖ ពីដំបូងប-១ មិនមានមន្ទីរផ្សេងៗទេ ប៉ុន្តែកម្មាភិបាលទាំងនោះបានទទួល

ឋានៈផ្លូវការនៅពេលពួកគេជួបជាមួយភ្ញៀវបរទេស។ ឧទាហរណ៍អតីតកម្មាភិបាលប-១ (លុប) និយាយថា "គាត់ត្រូវបានគេណែនាំនៅអង្គការសហប្រជាជាតិថាជាសមាជិកខាងកិច្ចការទូទៅ ដែលតាមពិតមិនមានផ្នែកនេះទេ"។ ក្រោយមក ប-១ ប្រហែលជាមានការរៀបចំជារចនាសម្ព័ន្ធត្រឹមត្រូវ។ អតីតកម្មាភិបាលប-១ (លុប) និយាយថា "ខុសពីក្រសួងផ្សេងៗទៀត មានតែ ប-១ទេ ដែលមានរចនាសម្ព័ន្ធជាក្រសួង"។ យោងតាមឯកសារមួយដែលមានចំនួន១៥២ទំព័រ ប្រហែលជាកំណត់ត្រាសរសេរដោយដៃរបស់កម្មាភិបាលជាន់ខ្ពស់នៅប-១ ប៉ុន្តែមិនអាចកំណត់អត្តសញ្ញាណបានចុះនៅខែកក្កដា ឆ្នាំ១៩៧៦ ប-១ត្រូវបានបែងចែកជាប្រាំពីរផ្នែកគឺៈ ការអប់រំ ដាំដុះ ការិយាល័យ រួមមានផ្នែកសម្ងាត់នយោបាយ ពិធីការ លេខាធិការ និងអាកាសចរស៊ីវិល។

កំណត់ត្រាទាំងនេះដែលមាននៅក្នុងសៀវភៅទិនានុលេខន៍មួយត្រូវបានយកទៅបង្ហាញសាក្សីជាច្រើន ហើយពុំមានសាក្សីណាម្នាក់បដិសេធពីយថាភូតភាពរបស់ឯកសារនោះទេ ក្នុងអំឡុងពេលស៊ើបអង្កេត។

[១១:២២:០៥]

កថាខណ្ឌ១០០៨ៈ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៥ វិទ្យុនៅភ្នំពេញបានផ្សាយថា អៀង សារី ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។ ការតែងតាំងនេះ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ក្នុងផ្នែកស្តីអំពីការងារបរទេស ទាំងបក្ស ទាំងរដ្ឋ។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបក្សបានកត់ត្រាការតែងតាំងក្នុងឯកសារមួយដែលមានចំណងជើងថា "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបង្ហាញផ្សេងៗមួយចំនួន"។ ការតែងតាំងត្រូវបានគាំទ្រដោយសភាតំណាងប្រជាជនកម្ពុជានៅខែបន្ទាប់។ អៀង សារី បានទទួលស្គាល់ថាខ្លួនធ្លាប់ធ្វើជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ក្នុងអំឡុងរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាមែន ដោយនិយាយថា គាត់ទទួលយកតួនាទីនេះក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៦ ក៏ប៉ុន្តែគាត់មិនចាំថាថ្ងៃណាពិតប្រាកដទេ។ នៅក្នុងតួនាទីនេះ គាត់ក៏ជាសមាជិកនៃគណៈរដ្ឋមន្ត្រីដែរ។

[១១:២៣:៣៣]

កថាខណ្ឌ១០០៩ៈ សៀវភៅទិនានុលេខន៍ដែលរកឃើញ មានខ្លឹមសារទាក់ទងនឹងប-១ ក្រោមចំណងជើង "សន្និបាតសាខា ២២/៥/៧៦" មានកត់ត្រាថា អៀង សារី ជាប្រធានសាខាបក្ស។ ហើយ

ចំពោះទិដ្ឋភាពរដ្ឋបាល គាត់ជាគណៈប្រធានដឹកនាំទូទៅ និងជាប្រធានផ្នែកនយោបាយ។ បន្ទាប់មកទៀត នៅក្នុងឯកសារដដែលនោះ ក្រោមចំណងជើងថា “ផែនការ សាខា១៩៧៧” អៀង សារី ត្រូវបានសរសេរថាជាលេខាគណៈសាខាក្រសួងជាមួយ (លុប) ដែលជាអនុរបស់គាត់។

[១១:២៤:២២]

កថាខណ្ឌ១០១០៖ មានទិដ្ឋភាពជាច្រើនទាក់ទិននឹងតួនាទីរបស់អៀង សារី នៅប-១។ តួនាទីមួយក្នុងចំណោមតួនាទីជាច្រើន គឺការងារគ្រប់គ្រងស្ថានទូតកម្ពុជានៅក្រៅប្រទេស។

ក្នុងខែឧសភា ឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានតែងតាំងអ្នកការទូតសម្រាប់ស្ថានទូតកម្ពុជាប្រជាធិតេយ្យចំនួនបួន៖ ចិន កូរ៉េខាងជើង វៀតណាម និងឡាវ។ អ្នកការទូតដែលតែងតាំងដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាចុងក្រោយនៅមាន ឯស្ថានទូតកម្ពុជាប្រជាធិបតេយ្យក្នុងប្រទេសអាល់បានី, យូហ្គោស្លាវី និងរ៉ូម៉ានី។ បើតាម (លុប) ដែលជាអ្នកមានតួនាទីជាន់ខ្ពស់ជាច្រើននៅ ប-១ រួមមានតំណែងជាប្រធាននាយកដ្ឋានឃោសនាការ និងព័ត៌មាន អៀង សារី ជាប្រធានផ្នែកនយោបាយ ដែលមានបុគ្គលិកជាបញ្ញវន្តនានា ដូចជា (លុប) ដឹកនាំអង្គប្រជុំនានាក្នុងកម្រិតក្រសួង ដឹកនាំអង្គប្រជុំបក្សនៅក្នុងក្រសួង ដឹកនាំការងារទីភ្នាក់ងារសារព័ត៌មានកម្ពុជា និងផ្នែកផ្សាយជាភាសាបរទេសនៃវិទ្យុកម្ពុជាប្រជាធិបតេយ្យ និងការ-- និងផ្តល់ការណែនាំនៅអ្នកក្រោមបង្គាប់ អំពីការរៀបចំវគ្គរៀនសូត្រដល់បុគ្គលិកក្រសួង ដោយផ្អែកលើការផ្សាយប្រចាំថ្ងៃនៃវិទ្យុកម្ពុជាប្រជាធិបតេយ្យ។

[១១:២៦:០៤]

កថាខណ្ឌ១០១១៖ បើតាម (លុប) ក៏ជាអ្នកមានតួនាទីជាន់ខ្ពស់ជាច្រើនផងដែរនៅប-១ រួមមានឋានៈជាប្រធានសន្តិសុខអះអាងថា អៀង សារី ជាអ្នកដឹកនាំរួមនៅប-១ ដែលមានន័យថា គាត់ក៏ដឹកនាំសាខាបក្សក្នុងក្រសួង ទទួលខុសត្រូវកិច្ចការផ្ទៃក្នុងរបស់ក្រសួង ផ្សព្វផ្សាយបទបញ្ជាពីថ្នាក់លើ ជាពិសេសពី ប៉ុល ពត និង នួន ជា។ ជួបប្រជុំជាមួយបញ្ញវន្តដែលជាបុគ្គលិកស្ទើររៀងរាល់ថ្ងៃ គ្រប់គ្រងមន្ទីរអប់រំកែប្រែ ដែលជាសាខារបស់ក្រសួងដូចជា ច្រាំងចំរេះ និងព្រែកប្រា ទទួលភ្ញៀវបរទេស និងធ្វើដំណើរទស្សនកិច្ចផ្លូវការទៅបរទេស។ រួមមានការចូលរួមប្រជុំរបស់អង្គការសហប្រជាជាតិ និងអមដំណើរគណៈប្រតិភូបរទេស ដែលមកទស្សនកិច្ចនៅទីជនបទ។ (លុប) បាននិយាយផងដែរថា អៀង សារី ទទួលខុសត្រូវកិច្ចការសន្តិសុខផ្ទៃក្នុងរបស់ប-១ ដោយធ្វើការពិគ្រោះយោបល់ជាមួយមន្ទីរនយោបាយ៨៧០ និងជាមួយ ប៉ង់។ ឌុច ក៏បានថ្លែងបញ្ជាក់ដូចនេះដែរ។

[១១:២៧:២៧]

កថាខណ្ឌ១០១២៖ ក្នុងតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស អៀង សារី បានធ្វើដំណើរទៅបរទេសជាច្រើនទៀតទាត់ទៅកាន់ប្រទេសនានាដូចជា ស្រីលង្កា, រ៉ូម៉ានី, ចិន, ភូមា, ប៉ាគីស្ថាន, ឡាវ, បារាំង, ម៉ិកស៊ិក្កូ, គុយបា, វៀតណាម, សិង្ហបុរី, កូរ៉េខាងជើង, ឥណ្ឌូនេស៊ី, ថៃ, ហ្វីលីពីន, ប៉េរូ, ម៉ាឡេស៊ី, ជប៉ុន, សហរដ្ឋអាមេរិក, ហុងហ្គារី, យូហ្គោស្លាវី និងប៉ូលហ្គារី។ អតីតបុគ្គលិកប-១ ម្នាក់និយាយថា អៀង សារី ឧស្សាហ៍ធ្វើដំណើរទៅប្រទេសចិន វៀតណាម និងកូរ៉េខាងជើងញឹកញាប់ជាងគេ។ ក្នុងពេលដែលគាត់នៅបរទេស អៀង សារី នៅតែគ្រប់គ្រងប-១ បានតាមរយៈមន្ទីរ៨៧០ ដែលគ្រប់គ្រងដោយ ប៉ង់។ នៅពេល អៀង សារី អវត្តមានជាទូទៅ (លុប) ត្រូវបានចាត់តាំងជាអ្នកកាន់ការជំនួស ក៏ប៉ុន្តែ (លុប) មិនមានអំណាចធ្វើសេចក្តីសម្រេចទេ ហើយបំពេញការងារក្រោមការណែនាំរបស់មជ្ឈិម។ នៅពេលដែល អៀង សារី និង (លុប) អវត្តមាន ប-១ ត្រូវគ្រប់គ្រងដោយសមាជិកជាន់ខ្ពស់ផ្សេងទៀតក្នុងក្រសួង ឬដោយ ខៀវ សំផន ម្តងម្កាលដែរ។

កថាខណ្ឌ១០១៣៖ នៅប្រទេសកម្ពុជា អៀង សារី តែងតែទទួលគណៈប្រតិភូបរទេស រៀបចំពិធីជប់លៀង ចូលរួមប្រជុំពិភាក្សាពីទំនាក់ទំនងអន្តរជាតិ និងពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងអបដំណើរគណៈប្រតិភូទាំងនោះទៅទស្សនកិច្ចនៅទូទាំងប្រទេសកម្ពុជា។

កថាខណ្ឌ១០១៤៖ ច្បាស់ណាស់ថា អៀង សារី មានអំណាចលើប-១ ទោះបីជាអតីតបុគ្គលិកនៅទីនោះបាននិយាយថា ការសម្រេចលើកិច្ចការសំខាន់ៗរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍តែឯងប៉ុណ្ណោះ។

[១១:២៨:៥២]

**តួនាទីផ្សេងទៀត៖**

កថាខណ្ឌ១០១៥៖ បន្ថែមលើតួនាទីខាងលើ អៀង សារី មានតួនាទីមួយចំនួនទៀត ក្នុងអំឡុងរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា។ តួនាទីទាំងនោះរួមមាន អំណាចឧទ្ទេសនាមមនុស្សចូលក្នុងបក្ស ដឹកនាំគណៈកម្មការកិច្ចការបរទេសនៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សរសេរលិខិតឆ្លើយឆ្លងក្នុងនាម (លុប)។ អៀង សារី ក៏ជាសមាជិកគណៈកម្មាធិការនានា ដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហានានា ដូចជា ធនាគារ ការទិញសម្ភារៈ និងឃ្លាំងរដ្ឋ នៅក្រុងភ្នំពេញ។ ជាងនេះទៀត--ជាងនេះទៅទៀត គាត់ប្រហែលជាបានចូលរួមរៀបចំទស្សនាវដ្តីឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា

ទោះបីជាមានសាក្សីម្នាក់បានបដិសេធពីការអះអាងនេះក៏ដោយ។ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ អៀង សារី ចូលរួមទទួលខុសត្រូវលើមន្ទីរនយោបាយ៨៧០ និងមន្ទីរស-២១ ផងដែរ។

[១១:៣១:១៦]

**តួនាទី និងមុខងារសមាជិកគណៈមជ្ឈិម និងការចូលរួមក្នុងការងារគណៈអចិន្ត្រៃយ៍៖**

កថាខណ្ឌ១១៣១៖ ខៀវ សំផន ត្រូវបានបញ្ចូលជាសមាជិកត្រៀមនៃគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា នៅឆ្នាំ១៩៧១ និងបានក្លាយជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ១៩៧៦។ ក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម ខៀវ សំផន អាចពិគ្រោះ ពិភាក្សា និងរួមមតិសម្រេចរាល់បញ្ហាដែលពាក់ព័ន្ធ។

កថាខណ្ឌ១១៣២៖ ខៀវ សំផន ធ្លាប់បានអះអាងថា គាត់មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ ទោះបីគាត់ធ្លាប់ ឬមិនធ្លាប់ជាសមាជិកផ្លូវការក៏ដោយ ក៏មានឯកសារជាច្រើនបង្ហាញថា គាត់បានចូលរួមប្រជុំក្នុងគណៈអចិន្ត្រៃយ៍ជាច្រើនដងដែរ។ ក្នុងចំណោមកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ចំនួន១៩ដែលនៅសល់ មានតែ១៥ប៉ុណ្ណោះ ដែលកត់ត្រាពីសមាសភាពអ្នកចូលរួម។ មានការកត់ត្រាថា គាត់បានចូលរួមប្រជុំចំនួន១៣ដង ព្រមទាំងបានចូលរួមអង្គប្រជុំពិសេសនានារបស់គណៈមជ្ឈិមយ៉ាងតិចពីរដង។ ខៀវ សំផន បានថ្លែងថា "នៅពេលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បើកទូលាយ ក៏ដូចនៅពេលប្រជុំគណៈកម្មាធិការមជ្ឈិមបក្ស ខ្ញុំមិនដែលមានមតិអ្វីទាំងអស់"។ ប៉ុន្តែមានឯកសារជាច្រើនបង្ហាញថាគាត់ជាអ្នករាយការណ៍ទៅគណៈអចិន្ត្រៃយ៍ចំនួនពីរដង។ ចំពោះការប្រជុំដែល ខៀវ សំផន មិនបានចូលរួម គាត់ប្រហែលជានៅតែអាចទទួលបាននូវកំណត់ហេតុប្រជុំទាំងនោះ តែទំនងជាត្រូវបានគេកត់ត្រាជាប្រចាំ។

[១១:៣៣:២៧]

កថាខណ្ឌ១១៣៣៖ កំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ដែលបានដាក់ចូលក្នុងសំណុំរឿងបានចុះកាលបរិច្ឆេទត្រឹមពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៦។ ប៉ុន្តែ ខៀវ សំផន បានអះអាងនៅពេលសួរចម្លើយថា គណៈអចិន្ត្រៃយ៍បានកោះប្រជុំជារៀងរាល់ប្រាំពីរ ទៅដប់ថ្ងៃ ឬញឹកញាប់ជាងនេះ ក្នុងករណីបន្ទាន់។ សាក្សីម្នាក់ ដែលជាអ្នកបើកបររថយន្តឲ្យ ខៀវ សំផន ពីឆ្នាំ១៩៧៨ បានបញ្ជាក់ថា គាត់បានបើករថយន្តដឹក ខៀវ សំផន ពីមន្ទីរក-៣ ទៅកាន់មន្ទីរក-១ ចំនួនពីរ ឬបីលើកក្នុងមួយសប្តាហ៍ ហើយនួន ជា និង អៀង សារី ក៏ត្រូវបានដឹកតាមរថយន្តទៅកាន់មន្ទីរក-១ ក្នុងពេលជា

មួយគ្នានោះដែរ។ សាក្សីម្នាក់ទៀត បានអះអាងថា ខៀវ សំផន, អៀង សារី និង នួន ជា បានចូលរួមប្រជុំសម្ងាត់នៅមន្ទីរក-១។

[១១:៣៤:៤១]

កថាខណ្ឌ១១៣៤៖ ខៀវ សំផន មានទំនាក់ទំនង និងគ្រប់គ្រងកម្មាភិបាលថ្នាក់ក្រោម តាមរយៈការចូលរួមប្រជុំប្រចាំខែ នៅមន្ទីរក-១ ជាមួយ ប៉ុល ពត, នួន ជា, អៀង សារី និង ប៉ង់ ដែលជាប្រធានមន្ទីរស-៧១។ ការប្រជុំទាំងនោះ មានរយៈពេលពីប្រាំទៅប្រាំមួយថ្ងៃ ហើយមានកម្មាភិបាលជាថ្នាក់ដឹកនាំប្រហែល២០នាក់មកពីភូមិភាគតំបន់ ឬ/និង គណៈស្រុកផ្សេងៗចូលរួម។

[១១:៣៥:២៦]

**ប្រធានគណៈប្រធានរដ្ឋ៖**

កថាខណ្ឌ១១៣៥៖ ក្នុងសម័យប្រជុំដំបូង នៃសភាតំណាងប្រជាជនកម្ពុជា ដែលបានប្រារព្ធធ្វើឡើងពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ។ ក្នុងតួនាទីនេះ គាត់បានទទួលតំណែងជាប្រមុខរដ្ឋបន្តពី (លុប)។

កថាខណ្ឌ១១៣៦៖ ជំពូក៨ មាត្រា១១ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងថា "គណៈប្រធានរដ្ឋមានភារតំណាងឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេស និងក្រៅប្រទេស។" ខៀវ សំផន បានអះអាងថា ទាក់ទងនឹងជំពូក៨ ស្តីពីប្រធានគណៈប្រធានរដ្ឋ សេចក្តីសម្រេចចិត្តបង្កើតស្ថាប័ននេះ គឺដើម្បីអនុវត្តគោការណ៍សម្ធហភាពក្នុងគ្រប់វិស័យ។ ក៏ប៉ុន្តែ ខៀវ សំផន បានប្រកាសជាដដែលៗថា តួនាទីរបស់គាត់ ជាប្រធានគណៈប្រធានរដ្ឋ គ្រាន់តែជាតួនាទីកិត្តិយស និងជានិមិត្តរូបប៉ុណ្ណោះ ហើយថាគាត់គ្មានអំណាចជាក់ស្តែងទេ។ មានសាក្សីជាច្រើនបាននិយាយថា "ពួកគេជឿថា ខៀវ សំផន មិនមែនជាបុគ្គលដែលមានអំណាចទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"។

[១១:៣៧:០៥]

កថាខណ្ឌ១១៣៧៖ លើសពីនេះ ខៀវ សំផន បានប្រកាសថា "ការងាររបស់គាត់ គឺគ្រាន់តែថ្លែងសុន្ទរកថា ទទួលលិខិតសារតាំង ពីឯកអគ្គរដ្ឋទូតបរទេស ចូលរួម និងដឹកនាំការទទួលប្រមុខរដ្ឋពីប្រទេសនានាប៉ុណ្ណោះ"។ ទោះបីជា យើងសន្មតថា តួនាទីរបស់គាត់ត្រូវបានកម្រិតត្រឹមនេះក៏ដោយវាហាក់ដូចជាច្បាស់លាស់ណាស់ថា ការទទួលខុសត្រូវចម្បងនានារបស់ ខៀវ សំផន ក្នុងតំណែងនេះគឺដើម្បីជួយលើកស្ទួយ គោលនយោបាយផ្សេងៗ របស់បក្សកុម្មុយនីស្តកម្ពុជាលើឆាកអន្តរជាតិ។ គាត់

បានផ្ញើនិងទទួលលិខិតឆ្លើយឆ្លង និងសារតាំងពីបណ្ដាមេដឹកនាំ និងឯកអគ្គរដ្ឋទូតផ្សេងៗ លើពិភពលោក។ គាត់បានធ្វើដំណើរបំពេញទស្សនកិច្ចជាតំណាងកម្ពុជាប្រជាធិបតេយ្យ ទៅកាន់ប្រទេសនានា ដូចជា ចិន ស្រីលង្កា សាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ យូហ្គោស្លាវី រូម៉ានី និងបានថ្លែងសុន្ទរកថាម្ដង នៅឯសន្និសីទកំពូលលើកទី៥ របស់បណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ ក្នុងឆ្នាំ១៩៧៦។

[១១:៣៨:៣២]

ប៉ុន្តែគាត់បានបញ្ជាក់ថា អៀង សារី ជាអ្នកសរសេរសុន្ទរកថានេះឲ្យគាត់។ គាត់ក៏បានទទួលគណៈប្រតិភូ និងឯកអគ្គរដ្ឋទូតបរទេសជាច្រើននៅប្រទេសកម្ពុជា ជូនកាលគាត់អមដំណើរជាមួយពួកគេ ដើម្បីទៅធ្វើទស្សនកិច្ចនៅជុំវិញប្រទេសកម្ពុជា និងបានរាយការណ៍ប្រាប់គណប្រតិភូទាំងនោះ អំពីការកសាងប្រទេសឡើងវិញ អំពីសហករណ៍ និងបដិវត្តកសិកម្មផងដែរ។

កថាខណ្ឌ១១៣៨៖ ខៀវ សំផន បានដឹកនាំសកម្មភាពនានា ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ដូចជា ប្រកាសឲ្យប្រើបទប្បញ្ញត្តិដែលកំណត់អំពីការប្រព្រឹត្តទៅរបស់សភាតំណាងប្រជាជន និងគណៈអចិន្ត្រៃយ៍ នៃសភាតំណាងប្រជាជនកម្ពុជា និងបានទទួលព័ត៌មានទាក់ទងតាមទូរលេខ អំពីជីវភាពរស់នៅ ការចាប់ខ្លួន និងការឃុំឃាំងមនុស្សនៅខេត្តព្រះវិហារ។

[១១:៣៩:៥២]

**អង្គភាពចំណុះមន្ទីរ៨៧០៖**

កថាខណ្ឌ១១៣៩៖ ចាប់ពីថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ជាកម្មាភិបាលដឹកនាំមួយរូប នៃអង្គភាពរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានឈ្មោះជាផ្លូវការថា "មន្ទីរនយោបាយ៨៧០"។ ខៀវ សំផន បានទទួលស្គាល់ថា គាត់ជាមនុស្សម្នាក់ក្នុងចំណោមកម្មាភិបាលតែពីរនាក់ប៉ុណ្ណោះ ដែលត្រូវបានចាត់តាំងឲ្យបំពេញការងារនៅទីនោះ ដែលកម្មាភិបាលម្នាក់ទៀតគឺជាប្រធានមន្ទីរនេះដំបូងឈ្មោះ សឿ វ៉ាស៊ី ហៅ ឌឿន ជាសមាជិកមួយរូបនៃគណៈមជ្ឈិម ដែលបានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ជាទៀងទាត់។

ឌុច បានអះអាងថា ខៀវ សំផន បានកាន់តួនាទីជាប្រធានមន្ទីរ៨៧០ នៅឆ្នាំ១៩៧៦ នៅពេលដែល ឌឿន ចាកចេញទៅគ្រប់គ្រងនៅក្រសួងពាណិជ្ជកម្ម។ លើសពីនេះ ឌុច បានអះអាងថា តំណែងរបស់ ខៀវ សំផន ជាប្រធានមន្ទីរកាន់តែមានលក្ខណៈរឹងមាំនៅក្នុងឆ្នាំ១៩៧៧ នៅខណៈ ឌឿន ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១។

(លុប) ដែលជាអ្នកបានកាន់តំណែងជាន់ខ្ពស់ជាច្រើននៅប-១ និងជាអ្នកបញ្ជូនសំបុត្រដោយផ្ទាល់ពី ប-១ និងពី អៀង សារី ទៅឲ្យ ខៀវ សំផន អះអាងបន្ថែមថា ខៀវ សំផន បានជំនួសតំណែងសឿ វ៉ាស៊ី ហៅ ឌឿន ក្នុងឋានៈជាប្រធាននៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ សាក្សីម្នាក់ទៀតដែលធ្លាប់ធ្វើការនៅប-១ ក៏បានបញ្ជាក់ដូចគ្នាផងដែរ។ នៅក្នុងកិច្ចសម្ភាសន៍មួយ នៅឆ្នាំ១៩៩៩ អៀង សារីបានបញ្ជាក់ថា ខៀវ សំផន ជាប្រធានមន្ទីរនយោបាយ៨៧០ ទោះបីជាថ្មីៗនេះ គាត់បានបដិសេធលើការលើកឡើងនេះក៏ដោយ។

[១១:៤២:១៦]

កថាខណ្ឌ១១៤០៖ លើសពីនេះទៀត ខៀវ សំផន អាចជាអ្នកទទួលខុសត្រូវនៅក្នុងមន្ទីរស៧១។ សាក្សីម្នាក់និយាយថា ប៉ង់ ជាប្រធានមន្ទីរស-៧១ ហើយគាត់ជាអ្នកទទួលបញ្ជាពី ខៀវ សំផន និងពីមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ទៅតាមជំនាញការងារ។

កថាខណ្ឌ១១៤១៖ ខៀវ សំផន បានប្រកែកជាបន្តបន្ទាប់ថា គាត់មិនធ្លាប់ធ្វើជាប្រធានមន្ទីរនយោបាយ៨៧០ ទេ។ គាត់បានអះអាងថា តួនាទីរបស់គាត់នៅក្នុងមន្ទីរចំណុះមន្ទីរ៨៧០ ត្រូវបានកំណត់ត្រឹមតែបញ្ហាសេដ្ឋកិច្ច ការផ្គត់ផ្គង់ស្បៀងអាហារនៅទូទាំងប្រទេសកម្ពុជា និងការទាក់ទងជាមួយ (លុប) តែប៉ុណ្ណោះ។

[១១:៤៣:១២]

សាក្សីម្នាក់ដែលធ្លាប់ធ្វើការជាអ្នកបកប្រែទូរលេខនៅតំបន់ស្វយ័ត១០៥ និងជានីរសាររបស់មជ្ឈិមបក្សអះអាងថា គាត់ត្រូវបញ្ជូនទូរលេខទាំងអស់ ដែលទាក់ទិននឹងការងារសម្ភារៈ សុខាភិបាល ឬសង្គមកិច្ច និងការងារក្រៅពីសន្តិសុខផ្ទាល់ទៅឲ្យ ខៀវ សំផន នៅមន្ទីរ៨៧០។

**ក្រសួងពាណិជ្ជកម្ម៖**

កថាខណ្ឌ១១៤២៖ ខៀវ សំផន ត្រូវបានតែងតាំងឲ្យទទួលខុសត្រូវពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ ក្នុងអំឡុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ដែលជាក់ស្តែងគឺធ្វើការនៅកៀកនឹងសមាជិកគណៈមជ្ឈិម កុយ ធួន ដែលត្រូវចាត់តាំងឲ្យទទួលបន្ទុកខាងពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស។ នៅក្នុងតួនាទីនេះ ខៀវ សំផន អាចបានចូលរួមប្រជុំក្នុងគណៈរដ្ឋមន្ត្រីផងដែរ។

[១១:៤៤:១៩]

កថាខណ្ឌ១១៤៣៖ ខៀវ សំផន បានអះអាងជាសាធារណៈថា ការទទួលខុសត្រូវរបស់គាត់រួមមាន៖ ធ្វើការងារជាមួយនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសសម្រាប់ការនាំចេញ និងនាំចូលទំនិញ អនុវត្តសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ទាក់ទិននឹងការចែកស្បៀងអាហារនៅទូទាំងប្រទេស និងរៀបចំតម្លៃផលិតផល ដែលបានទទួលពីតាមសហករណ៍។

សាក្សីនានាបានបញ្ជាក់ថា គាត់ទទួលខុសត្រូវផ្នែកពាណិជ្ជកម្ម និងចែកទំនិញ និងស្បៀងនៅទូទាំងប្រទេសមែន។ ហើយមានសាក្សីជាច្រើននាក់ទៀតអះអាងថា គាត់បានទៅក្រសួងពាណិជ្ជកម្មជាទៀងទាត់។ លេខាតំបន់១០៥ បាននិយាយថា ខ្ញុំធ្លាប់ឲ្យបញ្ជីពាណិជ្ជកម្មស្នើសម្ភារៈឲ្យទៅ ខៀវ សំផន ផ្ទាល់ដៃ ហើយធ្លាប់បាននិយាយជាមួយគាត់ពីការងារសេដ្ឋកិច្ចនៅពេលបាយ ឬក្រៅពេលប្រជុំផ្លូវការ។ ក្នុងពេលសួរចម្លើយ ឌុច បានផ្តល់សក្ខីកម្មថា ខៀវ សំផន ធ្លាប់បានគ្រប់គ្រងរោងចក្រអគ្គិសនីរដ្ឋាករទឹក និងឃ្លាំងរដ្ឋ។

[១១:៤៥:៤១]

កថាខណ្ឌ១១៤៤៖ ខៀវ សំផន បានទទួលទូរលេខ និងលិខិតឆ្លើយឆ្លងជាច្រើនពីគណៈកម្មាធិការពាណិជ្ជកម្ម និងក្រុមហ៊ុនហ្គូតត្រា ពាណិជ្ជកម្មក្រៅប្រទេសនៅទីក្រុងភ្នំពេញ ទាក់ទងនឹងបញ្ហានានាដូចជា ការនាំចូល នាំចេញស្បៀងអាហារ និងទំនិញ។ ទំនាក់ទំនងសេដ្ឋកិច្ចជាមួយបរទេស ក៏ដូចជាការដែលសមាជិកគណៈកម្មាធិការពាណិជ្ជកម្មធ្វើដំណើរទៅតាមទីជនបទនៃប្រទេសកម្ពុជា ដើម្បីប្រមូលភោគផល។

[១១:៤៦:១៥]

នៅពេលត្រូវបានសួរអំពីទូរលេខមួយដែលផ្ញើទៅឲ្យ ខៀវ សំផន សាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅក្រសួងពាណិជ្ជកម្មបានអះអាងថា វ៉ាន់ រិទ្ធ មិនមានអំណាចសម្រេចទៅលើការទិញទំនិញពីបរទេសទេ ហើយថារាល់លិខិតដែលទាក់ទងនឹងបញ្ហានេះ ត្រូវតែផ្ញើទៅឲ្យ ខៀវ សំផន ដើម្បីសម្រេច។ ទោះបីជាគណៈកម្មាធិការពាណិជ្ជកម្មដែលនៅក្រោមការគ្រប់គ្រងរបស់ វ៉ាន់ រិទ្ធ ត្រូវទទួលខុសត្រូវចំពោះមុខ វន វ៉េត ក៏ដោយក៏ការដែលថា វ៉ាន់ រិទ្ធ ស្ថិតនៅក្រោមបង្គាប់របស់ ខៀវ សំផន នោះត្រូវបានបង្ហាញយ៉ាងច្បាស់តាមហេតុការណ៍ដែលថា គាត់បានធ្វើចំណារជាទៀងទាត់លើសេចក្តីចម្លងនៃរបាយការណ៍ពាណិជ្ជកម្មដែលត្រូវផ្ញើជូនទៅបង ហែម ដោយប្រើពាក្យស្វាគមន៍ជាភាតរភាព។

[១១:៤៧:១២]

ឌុច បានបញ្ជាក់ថា ជាធម្មតាត្រូវប្រើពាក្យនេះជាមួយថ្នាក់លើ។ សាក្សីមួយរូបដែលធ្វើការនៅខាងពាណិជ្ជកម្មក្នុង និងក្រៅប្រទេស បានអះអាងថា ខៀវ សំផន មានអំណាចលើ វ៉ាន់ រិទ្ធ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ខៀវ សំផន បានទទួលគណៈប្រតិភូសេដ្ឋកិច្ច និងពាណិជ្ជកម្មក្រៅប្រទេសមួយក្រុមមកពីប្រទេសយូហ្គោស្លាវី ហើយគាត់អះអាងថា គាត់ធ្លាប់បានទៅប្រទេសយូហ្គោស្លាវី ពីរដង។

**ផ្នែកកិច្ចការបរទេស និងអ្នកធ្វើមាតុភូមិនិវត្តន៍៖**

កថាខណ្ឌ១១៤៧៖ មានភស្តុតាងបញ្ជាក់ថា នៅពេល អៀង សារី នៅក្រៅប្រទេស ខៀវ សំផន ទទួលខុសត្រូវដឹកនាំក្រសួងការបរទេស។ ខៀវ សំផន ពាក់ព័ន្ធនឹងការហៅប្រជាជនដែលរស់នៅបរទេសឲ្យត្រឡប់មកកម្ពុជាវិញ ដោយអប់រំពួកគេ ពេលពួកគេមកដល់។ សាក្សីបីនាក់បាននិយាយថា ខៀវ សំផន មានតួនាទីជាអ្នកបង្រៀនវគ្គរៀនសូត្រនយោបាយដល់ប្រជាជនកម្ពុជាដែលត្រឡប់ចូលស្រុកវិញ។ មានសាក្សីម្នាក់ដែលវិលត្រឡប់មកកម្ពុជាវិញនៅចុងឆ្នាំ១៩៧៥ ជាមួយក្រុមនិស្សិតមួយក្រុមដែលមានគ្នាដប់នាក់បានអះអាងថា ខៀវ សំផន ធ្លាប់បានប្រាប់ពួកគាត់ថា បច្ចុប្បន្ននេះមានវណ្ណៈតែពីរប៉ុណ្ណោះ គឺវណ្ណៈកសិករ និងកម្មករ។ ហើយថាប្រទេសជាតិត្រូវការពួកយើងដើម្បីកសាងប្រទេសឡើងវិញ។ ប៉ុន្តែមុនដំបូងគឺត្រូវទៅជនបទដើម្បីរៀននូវអ្វីៗដែលយើងមិនដែលបានធ្វើពីមុនមកទាល់តែសោះ។ ជាឧទាហរណ៍ដូចជា៖ រៀនដាំស្រូវ ដើម្បីស្វែងយល់ថា តើមានការលំបាកបែបណា? ទម្រាំទទួលបានបាយមួយចានយកមកហូប។ អ្នកត្រឡប់មកវិញភាគច្រើន បានត្រូវបញ្ជូនទៅមន្ទីរស-២១ បន្ទាប់ពីការហៅឲ្យទៅរៀនសូត្រ។

[១១:៤៩:៤១]

**សុន្ទរកថា និងការបង្រៀននយោបាយ៖**

កថាខណ្ឌ១១៤៨៖ លើសពីនេះទៀត ខៀវ សំផន ជាអ្នកទទួលខុសត្រូវថ្លែងសុន្ទរកថាក្នុងនាមបក្សកុម្មុយនីស្តកម្ពុជា និងដឹកនាំសកម្មភាពបណ្តុះបណ្តាល។ ខៀវ សំផន បានថ្លែងសុន្ទរកថាជាច្រើនដងដើម្បីលើកស្ទួយ និងផ្សព្វផ្សាយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានថ្លែងសុន្ទរកថានៅសន្និសីទធំៗរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីអបអរសាទរខួបកំណើតជ័យជម្នះថ្ងៃទី១៧ ខែមេសា និងដើម្បីអបអរសាទរបុណ្យចូលឆ្នាំខ្មែរ។ មានសាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅមន្ទីរទូរលេខរបស់មជ្ឈិមបក្ស បានអះអាងថា ខៀវ សំផន ជាអ្នកណែនាំគាត់ក្នុងការរៀបចំកម្មវិធីបុណ្យជាតិផ្សេងៗ។ សាក្សីជាច្រើនផ្តល់ភស្តុតាងថាពួកគេធ្លាប់បានស្តាប់សុន្ទរកថា

របស់គាត់នៅក្នុងអង្គមីទ្ទិង និងការប្រជុំធំៗដែលបានប្រារព្ធធ្វើឡើងនៅតាមទីកន្លែងនានាដូចជា ពហុកីឡាដ្ឋានអូឡាំពិក និងបុរីកីឡា។ សាក្សីនានាបានផ្តល់ភស្តុតាងថា ខៀវ សំផន បានថ្លែងសុន្ទរកថាទៅកាន់មនុស្សប្រហែល២ម៉ឺននាក់ ដែលមកពីគ្រប់ទិសទីនៃប្រទេសកម្ពុជាក្នុងពេលមានមីទ្ទិង និងការប្រជុំទាំងនោះ។

[១១:៥១:២៣]

កថាខណ្ឌ១១៤៩៖ ខៀវ សំផន បានអះអាងថា គាត់ភាគច្រើនឯកភាពទៅលើខ្លឹមសារនៅក្នុងសុន្ទរកថាទាំងនោះ ប៉ុន្តែគាត់មិនយល់ស្របចំពោះចំណុចខ្លះ។ ឧទាហរណ៍ ការលុបបំបាត់លុយ តែគាត់មិនហ៊ានបញ្ចេញការជំទាស់ទេ ព្រោះខ្លាចត្រូវគេសម្លាប់។ គាត់អះអាងថា សុន្ទរកថារបស់គាត់វាមិនមានសារៈសំខាន់ច្រើននោះទេ ហើយថាមានតែប៉ុល ពត និង នួន ជា ទេ ដែលថ្លែងសុន្ទរកថាសំខាន់ៗ។ ខៀវ សំផន បានទៅ ប-១ ដើម្បីរកឯកសារ និងពិភាក្សាអំពីបញ្ហាណាដែលគាត់គួរលើកឡើងនៅក្នុងសុន្ទរកថារបស់ខ្លួន។

កថាខណ្ឌ១១៥០៖ ខៀវ សំផន ក៏មានការទទួលខុសត្រូវផងដែរ ក្នុងការរៀបចំវគ្គរៀនសូត្រនយោបាយជាទៀងទាត់ជាមួយកម្មករ និងកម្មាភិបាលគ្រប់ជាន់ថ្នាក់ដែលមកពីទូទាំងប្រទេសកម្ពុជា។ មានសាក្សីជាច្រើនផ្តល់សក្ខីកម្មថា ពួកគេតម្រូវឲ្យចូលរៀនវគ្គរៀនសូត្រទាំងនោះជាមួយ ខៀវ សំផន។ ខ្លឹមសារនៅក្នុងសុន្ទរកថា និងវគ្គរៀនសូត្រនយោបាយគ្របដណ្តប់ទៅលើបញ្ហានានាដូចជា ជោគជ័យរបស់បដិវត្តន៍ ជម្លោះប្រដាប់អាវុធជាមួយវៀតណាម គោលនយោបាយកសិកម្ម និងសេដ្ឋកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជា។ បញ្ហាផ្នែករដ្ឋបាលដូចជា ការថែទាំសម្ភារបរិក្ខារ តម្រូវការក្នុងការកម្ចាត់ពួកសក្តិភូមិ និងពួកមូលធន ផ្តួលរលំពួកក្បត់លន់ នល់ និងលុបបំបាត់ខ្សែរយៈលន់ នល់ ឬអំពីសភាពការណ៍នៅក្រុងភ្នំពេញ។

សូមគោរពលោកលោកប្រធាន កថាខណ្ឌដែលពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយនេះបានចប់សព្វគ្រប់ហើយ។

[១១:៥៣:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ដារ អានសាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៤:១៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះកិច្ចដំណើរការនៃការអានន្ទូវបណ្តាកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងអង្គហេតុចោទប្រកាន់លើជនជាប់ចោទ ក្នុងក្របខ័ណ្ឌរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ប្រព័ន្ធទំនាក់ទំនងការងារកម្ពុជាប្រជាធិបតេយ្យ និងកថាខណ្ឌខ្លះស្តីអំពីតួនាទីមុខងាររបស់ជនជាប់ចោទដែលមានការពាក់ព័ន្ធជិតស្និទ្ធទៅនឹងអង្គហេតុទាំងពីរខាងលើនេះ បានចប់ហើយ។ ប៉ុន្តែ តាមដែលអង្គជំនុំជម្រះបានទទួលតាមព័ត៌មានតាមអ៊ីម៉ែលឃើញថា ខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសុំលើកឡើងនូវការជំទាស់ និងដាក់សំណើរបស់ខ្លួន។ ប៉ុន្តែបញ្ហានេះដោយសារការផ្ញើហ្នឹងមិនទាន់មានភាពជាក់ច្បាស់នៅឡើយ ដើម្បីបានមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្រេច អង្គជំនុំជម្រះសូមអញ្ជើញមេធាវី-- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនូវការជំទាស់ ឬក៏សំណើផ្សេងៗពាក់ព័ន្ធទៅនឹងនីតិវិធីនៃកិច្ចដំណើរការសវនាការ ដែលយើងគ្រោងដាក់ពិភាក្សាដេញដោលទៅលើឯកសារ ដែលភាគីដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសប្តាហ៍នេះ។ ថាតើមានវាមានបញ្ហាអ្វីខ្លះដែលខ្លួនមានបញ្ហាប្រឈម? ហើយនិងមានបញ្ហាអ្វីខ្លះដែលខ្លួនមានបំណងស្នើសុំ? ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានពិចារណាសម្រេចបញ្ហានេះជាមុន មុនពេលដាក់បញ្ហាជូនទៅភាគី ដើម្បីលើកឡើងនូវការជំទាស់របស់ខ្លួន។

[១១:៥៥:៥៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំសូមទោសលោកប្រធាន យើងខ្ញុំមិនទាន់ច្បាស់លាស់ មានភាពច្បាស់លាស់ក្នុងការផ្តល់នូវ-- ចំពោះអ្វីដែលយើងត្រូវនិយាយនោះទេ។ តើយើងខ្ញុំអាចសុំការបញ្ជាក់បានទេ តើវាជាសំបុត្រដែលយើងផ្ញើជូនលោកប្រធាន ឬក៏យ៉ាងណា? សូមលោកប្រធានបំភ្លឺឲ្យបានច្បាស់សិន ដើម្បីយើងអាចបំភ្លឺបាននៅពេលក្រោយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រគល់នាទីទៅចៅក្រម ហ្សង់ម៉ាក ដើម្បីឆ្លើយបញ្ជាក់អំពីបញ្ហានេះ ចំពោះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវបញ្ហាដែលកើតមាន តាមសំណើដែលបានផ្ញើដោយ

សារអេឡិចត្រូនិច។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រីបានផ្ញើជូនលោកស្រី ស៊ូហ្សាន ឡេម នូវសំបុត្រមួយតាមអ៊ីម៉ែលដែលបញ្ជាក់ថា ឯកសារមួយចំនួនដែលលោកចង់ដាក់ចូលទៅក្នុងការពិភាក្សាគ្នានោះ គឺថាមិនទាន់មានបកប្រែជាបីភាសានៅឡើយទេ។ ហើយតុលាការចង់ដឹងថា តើលោកស្រីបានធ្វើសំណើទៅកាន់អង្គភាពបកប្រែហើយឬនៅ? ដើម្បីសុំឲ្យខាងអង្គភាពបកប្រែឯកសារ ហើយតើស្ថានភាពបច្ចុប្បន្ននោះវាទៅដល់ណាហើយ? ថាហេតុអីបានជាឯកសារមិនទាន់បានបកប្រែ? ហើយលោកស្រីបានគ្រោងយ៉ាងណាសម្រាប់ការបកប្រែឯកសារទាំងអស់នេះ?

[១១:៥៧:៤៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន ចំពោះការបញ្ជាក់នេះ។ ការស្នើសុំបកប្រែនេះគឺបានធ្វើរួចមកហើយដោយអង្គភាពមេធាវីនាំមុខ។ ខ្ញុំចង់ផ្តល់ការបំភ្លឺមួយចំនួនបន្ថែមក្រោយពីការសម្រាកនេះទៅ ពាក់ព័ន្ធនឹងកាលបរិច្ឆេទដែលយើងបានដាក់ពាក្យសំណើនោះ ព្រោះថាពេលនេះខ្ញុំអត់ទាន់បានចាំទេ ពីកាលបរិច្ឆេទនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ទោះជាយ៉ាងណាក៏ដោយលោកស្រីបានបញ្ជាក់ថា ឯកសារនោះ គឺបានស្នើសុំបកប្រែហើយមែនទេ ឯកសារពាក់ព័ន្ធទាំងអស់នេះ?

[១១:៥៨:១៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ចាស លោកចៅក្រម គឺថាយើងបានស្នើសុំបកប្រែហើយ ហើយឯកសារ គឺថាមាននៅក្នុងបញ្ជីរបស់យើង ដែលយើងបានដាក់កាលពីខែមេសា ខែកក្កដា និងខែតុលានោះ។ ហើយឯកសារដប់នេះគឺពាក់ព័ន្ធទៅនឹងសៀវភៅនិក្ខេបបទ ឬក៏អត្ថបទកាសែត យើងបានស្នើសុំការបកប្រែហើយ ក៏ប៉ុន្តែដោយសារតែឯកសារនេះមានចំនួនច្រើននោះ គឺថាយើងទទួលបានចម្លើយមិនបានសមស្របពីខាងផ្នែកបកប្រែ។ ប៉ុន្តែខ្ញុំមិនទាន់មានកាលបរិច្ឆេទច្បាស់លាស់ទេ ព្រោះពេលនេះខ្ញុំមិនអត់ទាន់បានចាំ អ៊ីចឹង

ខ្ញុំអាចបញ្ជាក់ជូនក្រោយពីសម្រាកចូលមកវិញ លោកចៅក្រម។

[១១:៥៩:០៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយ សាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធានសាថ្មី។ ដោយសារការអានកថាខណ្ឌពាក់ព័ន្ធនឹងប្រធានរចនាសម្ព័ន្ធរដ្ឋបាល និងការងារត្រូវបានអានចប់ហើយ។ លោក អៀង សារី ស្នើសុំការអនុញ្ញាតលះបង់សិទ្ធិក្នុងការចូលរួមក្នុងសវនាការដោយផ្ទាល់នៅក្នុងសវនាការនេះសម្រាប់រយៈពេលល្ងាចនេះ។ ប៉ុន្តែសូមចូលរួមសវនាការបន្តនៅបន្ទប់រង់ចាំខាងក្រោម ដោយសារមូលហេតុសុខភាព។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

[១១:៥៩:៥៧]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏មានសំណើសុំដូចក្រុមមុននេះដែរ គឺសុំទៅឲ្យកូនក្ដីរបស់យើងខ្ញុំទៅរង់តាមដានសវនាការនៅបន្ទប់បំពាក់ប្រព័ន្ធសោតទស្សន៍នៅខាងក្រោមនេះ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី និង នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ ដែលស្នើសុំទៅបន្តការតាមដានស្តាប់កិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍នៅបន្ទប់ខាងក្រោមបន្ទប់សវនាការនេះ ដោយលះបង់សិទ្ធិក្នុងការចូលរួមក្នុងការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយមានមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្តាប់នូវកិច្ចដំណើរការសវនាការបាន។

[១២:០០:៥២]

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទទាំងពីររូប គឺលោក អៀង សារី និង នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីរបស់គាត់ សុំទៅចូលរួមកិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍ ដោយលះបង់សិទ្ធិមិនចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងដំណើរការសវនាការនៅរសៀលនេះ។ ប៉ុន្តែអង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្ដីជនជាប់ចោទទាំងពីររូបប្រគល់មកឲ្យអង្គជំនុំជម្រះ នូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការដោយចុះហត្ថលេខា និងផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទផង។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរ-- ទៅកាន់បន្ទប់ខាងក្រោមដោយនៅរសៀលនេះគឺឲ្យនាំតែជនជាប់ចោទលោក ខៀវ សំផន មកកាន់បន្ទប់សវនាការទេ។ ដោយឡែកជនជាប់ចោទ អៀង សារី និង នួន ជា គឺទុកនៅខាងក្រោម ដើម្បីឲ្យគាត់បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទទាំងពីររូបអាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងរសៀលនេះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោក ឌុច ផារី!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន ដោយសារក្នុងសវនាការនៅក្នុងរសៀលនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញនៅមានវត្តមានរបស់លោកស្រី អង់តា ហ្គីសសេ ដែលជាមេធាវីនៅក្នុងក្រុមមេធាវីការពារក្តីរបស់លោក ខៀវ សំផន។ លោកស្រីមេធាវី អង់តា ហ្គីសសេ បានធ្វើសម្បថនៅសាលាឧទ្ធរណ៍រួចហើយ។

បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។

ឥឡូវនេះ ដោយមានការកត់សម្គាល់អំពីវត្តមានរបស់មេធាវីអន្តរជាតិការពារក្ដីឲ្យលោក ខៀវ សំផន ដែលទើបតែបានបំពេញកិច្ចដំណើរការនីតិ-- កិច្ចនីតិវិធីនូវសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ហើយមិនទាន់បានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះទេ ដោយអនុលោមតាមវិធាន២២(២) ចំណុច(ក) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមអញ្ជើញលោក គង់ សំអុន ដែលជាមេធាវីជាតិការពារក្ដីឲ្យលោក ខៀវ សំផន ឡើងធ្វើការស្នើសុំការទទួលស្គាល់មេធាវីអន្តរជាតិរូបនេះ ពី-- ដែលជាដៃគូរបស់លោកពីអង្គជំនុំជម្រះសាលាដំបូង។

សូមអញ្ជើញ!

[១៣:៣៣:៣០]

**លោក គង់ សំអុន៖**

បាទ សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ។ ខ្ញុំបាទក្នុងនាមក្រុមមេធាវីការពារលោក ខៀវ សំផន សុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាអនុញ្ញាតទទួលស្គាល់កញ្ញាមេធាវី អង់តា ហ្គីសសេ។ កញ្ញាជាមេធាវីដែលធ្លាប់មានបទពិសោធន៍ការពារនៅក្នុងតុលាការអន្តរជាតិរវ៉ាន់ដា ហើយជាសមាជិករបស់មេធាវីក្រុងប៉ារីស។ ហើយដែលដូចលោកក្រឡាបញ្ជីបានប្រកាសអម្បាញ់មិញថា កញ្ញាបានទទួលធ្វើសម្បថនៅសាលាឧទ្ធរណ៍រួចហើយ។ បាទ សូមអរគុណ។

[១៣:៣៤:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

សូមអញ្ជើញលោកស្រី អង់តា ហ្គីសសេ។

សូមអញ្ជើញក្រោកឈរ!

លោកស្រី អង់តា ហ្គីសសេ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកស្រីជាមេធាវីការពារក្ដីឲ្យលោក ខៀវ សំផន សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ។ អនុលោមតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវី

ជាតិការពារក្ដីឲ្យជនជាប់ចោទដែរ។ ហើយចំពោះឈ្មោះលោកស្រី មិនដឹងថា អានត្រូវដែរឬទេ? សូមលោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់ឈ្មោះរបស់លោកស្រីជាភាសាបារាំង តើឈ្មោះអ្វីដែរ?

[១៣:៣៤:៥៨]

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំ ឈ្មោះខ្ញុំ គឺ អង់តា ហ្គីសសេ។ ខ្ញុំសូមអរគុណដល់អង្គជំនុំជម្រះដែលបានទទួលស្គាល់ខ្ញុំ នៅក្នុងដំណើរការនីតិវិធីនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអង្គុយចុះ!

ជាកិច្ចបន្តអង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅភាគីនានានៃរឿងក្ដី ដើម្បីបង្ហាញពីការជំទាស់របស់ខ្លួន ដោយការទាញហេតុផលដោយផ្ទាល់មាត់ទៅលើឯកសារទាំងឡាយដែលភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលឯកសារទាំងនោះពាក់ព័ន្ធនឹងសវនាការនៅដំណាក់កាលដំបូង សំណុំរឿង០០២/០១ រួមមានឯកសារ E109/1.1, E109/2.1, E109/4, E109/6.2 ដែលពុំទាន់បានលើកយកមកពិភាក្សានៅក្នុងសវនាការកន្លងមក។ អង្គជំនុំជម្រះសូមបញ្ជាក់ថា សវនាការទាញហេតុផលផ្ទាល់មាត់ទាំងនេះ នឹងធ្វើពាក់ព័ន្ធទៅនឹងប្រភេទឯកសារដែលនៅសេសសល់ ដែលជាឯកសារមាននៅក្នុងសំណុំរឿងដូចមានបញ្ជាក់នៅក្នុងកថាខណ្ឌ៣ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២ខែមីនា ឆ្នាំ២០១២ ឯកសារ E172/5។

[១៣:៣៦:៣៩]

ហើយជាដំបូងនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីរបស់លោក នួន ជា ដើម្បីលើកឡើងនូវការជំទាស់របស់ខ្លួនទៅនឹងបណ្ដាឯកសារដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌ៣ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១២ គឺឯកសារ E172/5។ ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា ក្រុមមេធាវីការពារក្ដីលោក នួន ជា មានពេលវេលាកន្លះថ្ងៃ គឺពេញមួយរសៀលនេះនៅក្នុងការលើកឡើងនូវការសេចក្ដីជំទាស់របស់ខ្លួន។ សូមអញ្ជើញលោកមេធាវី។

[១៣:៣៧:៣១]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

ខ្ញុំមេធាវីការពារលោក នួន ជា ខ្ញុំសូម-- ខ្ញុំបាន តាំងពីចាប់ផ្ដើមតវ៉ាពីរឿងឯកសារដែលមានលើកឡើងរួចមកហើយនោះ។ ខ្ញុំនិងសហមេធាវីដៃគូរបស់ខ្ញុំបានតវ៉ាយ៉ាងច្រើន ហើយបានទាត់ចោលយ៉ាងច្រើន ចំពោះឯកសារទាំងប៉ុន្មាននោះ។ មិន--

[១៣:៣៨:១០]

មិនតែប៉ុណ្ណោះមេធាវីការពារក្រុមផ្សេងទៀតក៏បានទាត់ចោលនឹងឯកសារដែលលើកឡើងដោយព្រះរាជអាជ្ញាដែរ។ អំពីឯកសារថតចម្លង និងឯកសារស្កេន មិនអាចនិយាយបានពីយថាភាពរបស់ឯកសារ គឺគ្មានប្រពភច្បាស់លាស់ ក្រៅតែពីការ១ ចារលើឯកសារថតចម្លងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាថា មានប្រភពមកពីទួលស្លែងនោះ មិនគ្រប់គ្រាន់ទេ។ យើងខ្ញុំនៅតែទទូចហើយទទូចទៀត ធ្វើយ៉ាងណា ធ្វើយ៉ាងម្ដេចឲ្យយើងខ្ញុំទទួលបានការកំណត់មួយថា ឯកសារទាំងអស់នេះជាឯកសារពិតប្រាកដរបស់កម្ពុជាប្រជាធិបតេយ្យ។ ចាំបាច់ត្រូវតែផ្ទៀងផ្ទាត់ជាមួយនឹងឯកសារដើម ដើម្បីឲ្យយល់ច្បាស់ពីយថាភាពរបស់ឯកសារទាំងនោះ។ ចំពោះឯកសារ A7 ឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា មានតែប្រភពមកពី បណ្ណសារដ្ឋានជាតិដូចគ្នាដែរ គឺចាំបាច់ត្រូវតែរកឯកសារច្បាប់ដើមមកផ្ទៀងផ្ទាត់ ដើម្បីនឹងសម្រេចថា ជាឯកសារត្រឹមត្រូវដែលមានយថាភាព។

ស្នើដល់អង្គជំនុំជម្រះមេត្តាកោះហៅអ្នកគ្រប់គ្រងឯកសារនៅបណ្ណសារដ្ឋានជាតិ ដើម្បីផ្ទៀងផ្ទាត់ឯកសារថតចម្លងទាំងនេះជាមួយច្បាប់ដើម។

[១៣:៤០:០៦]

ចំពោះ A8 គុណភាពអន់នៃឯកសារថតចម្លង មើលមិនដាច់ ចាំបាច់ត្រូវតែយកឯកសារដើមមកផ្ទៀងផ្ទាត់។ ចំពោះ A10 ចំពោះរឿង ឌុច បាននិយាយហើយថា ចម្លើយសារភាពបានយក-- បានមកដោយបង្ខំ មានន័យថា ដោយវាយធ្វើបាបគ្រប់បែបយ៉ាងដែលខ្លួនអាចធ្វើបាន។ ដូចនេះ ខ្លឹមសារនៃការសួរចម្លើយរបស់វាមិនបានឆ្លុះបញ្ចាំងពីចម្លើយពិតនោះទេ ហើយក៏គ្មានប្រយោជន៍អ្វីដើម្បីជួយដល់ការស្វែងរកការពិត និងយុត្តិធម៌នៅទីនេះទាល់តែសោះ។

ជនជាប់ចោទ ឌុច ឆ្លើយនៅពេលសវនាការ ក្នុងករណី០០១ នោះ គួរឲ្យឆ្ងល់ណាស់ ថា ឌុច មានមុខងាររបស់ខ្លួនជាប្រធានស-២១ សោះ គឺមុខងារ និងឋានៈតូចតាចណាស់ គឺក្នុងក្របខ័ណ្ឌតែមន្ទីរ-- ប្រធានមន្ទីរស-២១ តែប៉ុណ្ណោះ។ ហេតុអ្វីបានជា ឌុច ដឹងដល់រឿងគណៈអចិន្ត្រៃយ៍? ហេតុអ្វីបានជា ឌុច ដឹងដល់រឿងមជ្ឈិមបក្ស រឿងសម្ងាត់ធំៗរបស់បក្សទាំងមូលហាក់ដូចជាខ្លួនហ្នឹងមានឋានៈ

ស្មើនឹង ប៉ុល ពត ដែរ? ហេតុនេះ សូមក្រុមប្រឹក្សាអង្គជំនុំជម្រះបដិសេធចម្លើយរបស់ ឌុច នៅពេលសវនាការករណី០០១ ចោលទាំងមូល។

[១៣:៤១:៤៧]

ចំពោះ A14 នៅក្នុងឯកសារលេខ D232/108 ជារបាយការណ៍ដែលបានតាក់តែងឡើង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដូចដែលលោក នួន ជា បានបញ្ជាក់រួចមកហើយថា ការិយាល័យមួយនេះមានភាពលម្អៀងក្នុងការស៊ើបអង្កេត ដែលគាំទ្រដល់ការិយាល័យសហព្រះរាជអាជ្ញា (សូមទោស) ដែលគាំទ្រដោយការិយាល័យសហព្រះរាជអាជ្ញា។

នៅក្នុងរបាយការណ៍របស់ខ្លួន ឯកសារ D369/38 បង្ហាញឲ្យឃើញឲ្យកាន់តែច្បាស់ថែមទៀតថា ការិយាល័យសហចៅក្រមស៊ើបអង្កេតព្យាយាមធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញាក្នុងការបន្ទុកមកលើរូបក្ដីលោក នួន ជា។ លោក លោកស្រីចៅក្រមជាទីគោរព ដើម្បីតាក់តែងរបាយការណ៍ ស្ដីពីកំណត់អត្តសញ្ញាណទីកន្លែង អ្នកស៊ើបអង្កេតបានយោងតែទៅលើបុគ្គលមួយរូប គឺលោក តូច វណ្ណារិទ្ធ ដែលកំពុងបម្រើការនៅការិយាល័យសហព្រះរាជអាជ្ញា។ លោក តូច វណ្ណារិទ្ធ បានចូលបម្រើការងារក្នុងការិយាល័យសហព្រះរាជអាជ្ញា តាំងពីការិយាល័យនេះបើកទ្វារស៊ើបអង្កេតមកម្ល៉េះ។ ដូចនេះ វាគ្មានអ្វីដែលគួរឲ្យសង្ស័យទេ ថាគាត់មានមនោគមន៍វិជ្ជាបែបសហព្រះរាជអាជ្ញា ត្រូវតែចោទប្រកាន់ជនសង្ស័យតែប៉ុណ្ណោះ។ បទពិសោធន៍យ៉ាងយូររបស់គាត់នៅការិយាល័យសហព្រះរាជអាជ្ញាជាមួយគាត់យ៉ាងពិតប្រាកដក្នុងការគូរបង្ហាញផែនទីនេះ ហើយវាពិតជាមិនចេញមកពីបទពិសោធន៍របស់ខ្លួននៅក្នុងរបបខ្មែរក្រហមនោះទេ។

[១៣:៤៤:០២]

**ប្រធានអង្គជំនុំ៖**

មានការជំទាស់ពី-- សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកចៅក្រម ជាបឋម វា-- ការលើកឡើងជំទាស់នេះ មិនមែនធ្វើឡើងដោយត្រឹមត្រូវនោះទេ។ មិនស្ថិតនៅក្នុងមូលដ្ឋានដែលមានការជំទាស់ទៅលើឯកសារនោះទេ។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ហើយថា បទដ្ឋានបឋមនៃការទទួលយកឯកសារនោះ គឺវាពាក់ព័ន្ធទៅនឹង-- វាត្រូវពិចារណាទៅលើភាពពាក់ព័ន្ធយថាភាព និងភាពទុកចិត្តបាន។ បញ្ហាការជំទាស់ ដែលលើកឡើងដោយមេធាវី

ការពារក្ដីនេះ គឺមិនពាក់ព័ន្ធនោះទេ វាពាក់ព័ន្ធនៅក្នុងដំណាក់កាលដែលអង្គជំនុំជម្រះនឹងសម្រេចទៅលើទម្ងន់នៃឯកសារនាពេលចុងក្រោយ។

[១៣:៤៤:៥៩]

ដូច្នេះហើយនៅពេលនេះ មេធាវីការពារក្ដីពិតជាមិនត្រឹមត្រូវនោះទេ ក្នុងការលើកឡើងទៅលើឈ្មោះបុគ្គលិក ហើយវាមិនត្រឹមត្រូវនោះទេក្នុងការលើក នៅក្នុងវេទិកាអង្គសវនាការនាពេលនេះ ដែលជាសារធារណៈ។ សូមអរគុណ។

[១៣:៤៥:២០]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅសហព្រះរាជអាជ្ញាអន្តរជាតិថា ខ្ញុំលើកឈ្មោះនេះឡើងដោយសារ មេធាវី នួន ជា មិនៗទទួលស្គាល់ ហើយមិនទទួលយកឯកសារ ដែលមន្ត្រីរបស់ព្រះរាជអាជ្ញា រៀបចំឯកសារនេះយកមកដាក់សវនាការ។ អានេះការបញ្ជាក់តែប៉ុណ្ណឹងទេ។

ខ្ញុំសូមបន្តទៅទៀត បើសិនលោកប្រធានអនុញ្ញាត។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៦:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តនូវការជំទាស់របស់លោកបន្តទៀត!

**លោក សុន អរុណ៖**

លោក តូច វណ្ណារិទ្ធ បានចូលបម្រើការងារនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា តាំងពីការិយាល័យនេះ បើកទ្វារស៊ើបអង្កេតមកម្ល៉េះ។ ដូចនេះ វាគ្មានអ្វីគួរឲ្យសង្ស័យទេ ថាគាត់មានមនោ-គមន៍វិជ្ជាបែបសហព្រះរាជអាជ្ញា ត្រូវតែចោទប្រកាន់ជនសង្ស័យតែប៉ុណ្ណោះ។ បទពិសោធន៍យ៉ាងយូររបស់គាត់នៅការិយាល័យសហព្រះរាជអាជ្ញាពិតជា ជួយគាត់យ៉ាងពិតប្រាកដក្នុងការគូរបង្ហាញផែនទីនេះ ហើយវាពិតជាមិនចេញមកពីបទពិសោធន៍របស់ខ្លួន នៅក្នុងរបបខ្មែរក្រហមនោះទេ។ គាត់កើតនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៦៥ តាមឯកសារលេខ D369/18 បើយើងគិតមកដល់ឆ្នាំ១៩៧៥ គាត់ទើបបានតែអាយុ១០ឆ្នាំប៉ុណ្ណោះ តើនៅក្នុងវ័យជាកុមារដូចនេះ តើគាត់មានសមត្ថភាពអ្វីដែលចងចាំបានយ៉ាងច្រើនដូចនេះ? នេះជាចម្លើយដែលក្លែងក្លាយ វាមិនបានឆ្លុះបញ្ចាំងពីការពិតនោះទេ។ អាស្រ័យ

ហេតុនេះ សូមក្រុមប្រឹក្សា នៃអង្គចៅក្រមមេត្តាបដិសេធចោលឯកសារថតចម្លង និងឯកសារស្កេនទាំងនេះជាចាំបាច់។

[១៣:៤៨:៣០]

ឯកសារចោទប្រកាន់ទាំងនេះ សុទ្ធតែជាការចោទប្រកាន់ដោយការស៊ើបអង្កេតដោយព្រះរាជ-អាជ្ញា និងចៅក្រមស៊ើបអង្កេតក្នុងបរិបទវិមតិសង្ស័យ មិនច្បាស់លាស់ដែលមិនអាចយកមកធ្វើជាឯកសារយថាភូតបានទាល់តែសោះ។ ដូចខ្ញុំបានរៀបរាប់ជូនអង្គសវនាការខាងលើនេះ សូមក្រុមប្រឹក្សាបដិសេធនូវឯកសារមិនមានយថាភាព ដែលលើកឡើងដោយសហព្រះរាជអាជ្ញានៅពេលកន្លងមកហើយនោះ និងពេលក្រោយៗទៀត។ បន្ទាប់ពីនេះទៅទៀត ខ្ញុំសូមឲ្យមេធាវីអន្តរជាតិ នៃក្រុម នៃអ្នកការពារលោក នួន ជា បន្តពីខ្ញុំ ដោយអនុគ្រោះ សូមអរគុណ។

[១៣:៤៩:២៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកមេធាវី សុន អរុណ។ សូមគោរពលោក លោកស្រីចៅក្រមជាទីគោរព។

ខ្ញុំចាប់ផ្តើមដោយលើកឡើងថា ខ្ញុំបានជម្រាបទៅដល់អ្នកបកប្រែហើយថា ខ្ញុំនឹងនិយាយដោយយឺតៗ ហើយខ្ញុំមិនប្រើពេលវេលាទាំងអស់នោះទេ ហើយយើងខ្ញុំនឹងធ្វើការ-- ធ្វើតុល្យភាពរវាងអ្វីដែលយើងខ្ញុំលើកឡើង នឹងមេធាវីសហសេវិក។ ខ្ញុំសូមលើកឡើងជាសេចក្តីចាប់ផ្តើម ខ្ញុំសូមយោងទៅលើសារណាទាំងឡាយ ដែលយើងបានដាក់យោងពាក់ព័ន្ធទៅនឹងឯកសារ។ តាមអ្វីដែលយើងលើកឡើងយើងខ្ញុំសូមបញ្ជាក់ថា ឯកសារទាំងអស់នោះ មិនបានបង្ហាញអំពីភាពជាក់លាក់នៃតួនាទីរបស់ជនជាប់ចោទនោះទេ។ ដូច្នេះហើយយើងត្រូវតែយកអ្នកនិពន្ធឯកសារនេះមកក្នុងតុលាការនេះ។ យើងខ្ញុំបានបញ្ជាក់ជាច្រើនលើកច្រើនសារួចមកហើយ។ នៅក្នុងថ្ងៃនេះ ខ្ញុំនឹងនិយាយអំពីបញ្ហាភាពពាក់ព័ន្ធទៅនឹងឯកសារ ហើយខ្ញុំនឹងនិយាយដោយយឺតៗ។

[១៣:៥០:៥៦]

បញ្ហាពាក់ព័ន្ធនេះវាជាបញ្ហាទូទៅ ហើយខ្ញុំនឹងអាននូវអ្វីដែលអង្គជំនុំជម្រះបានចេញឯកសារកាលពីឆ្នាំមុន។ ឯកសារ E141 ទំព័រទីពីរ ខ្ញុំសូមដកស្រង់ដូចតទៅ "ពាក់ព័ន្ធទៅនឹងការដេញដោលទៅ

លើគោលនយោបាយ គ្មានអ្វីក្រៅពីការជម្លៀសដោយបង្ខំយកមកដេញដោលនោះទេ។ ការយោងទៅលើវគ្គដំបូងនេះ គឺយើងនិយាយអំពីការដែលបង្កើតឡើង។ ដូច្នេះហើយការបង្ហាញជាទូទៅពាក់ព័ន្ធទៅនឹងគោលនយោបាយចំនួនប្រាំ។ គោលនយោបាយទាំងប្រាំនោះ គឺមានចែងនៅក្នុងកថាខណ្ឌ១៥៧ នៃដីកាដំណោះស្រាយ។ បញ្ហាគោលនយោបាយទាំងអស់នោះ គឺត្រូវយកមកដេញដោលនៅក្នុងវគ្គសវនាការហើយកំណត់ត្រឹមតែការជម្លៀស ផ្លាស់ទីលំនៅប្រជាជនវគ្គដំណាក់កាលទីមួយ និងទីពីរតែប៉ុណ្ណោះ។

[១៣:៥២:០១]

ដូច្នេះហើយ មិនមានការដេញដោលទៅលើការអនុវត្តគោលនយោបាយ ក្រៅតែពីការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរតែប៉ុណ្ណោះ។" ខ្ញុំដកស្រង់ចំណុចនេះដោយសារតែយើងត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ទៅលើការដេញដោលទៅលើឯកសារ និងបទដ្ឋានទាំងឡាយដែលយើងត្រូវយកមកវិភាគនៅក្នុងថ្ងៃនេះ។ យោងទៅលើចំណុចទាំងអស់នេះ យើងខ្ញុំសូមលើកឡើងសាជាថ្មីនូវអ្វីដែលយើងបានលើកឡើងរួចមកហើយ ក្រោយពីការបំបែកកិច្ចនីតិវិធី ការគំរាមកំហែងនៅក្នុងដំណាក់កាលដំបូងនេះ គឺវាពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនពីខាងត្បូងទៅភូមិភាគបូព៌ា ទៅភូមិភាគឧត្តរ។ ដូច្នេះហើយទាំងអស់នេះហើយវាពាក់ព័ន្ធទៅនឹងបញ្ហាឯកសារ ដូចដែលលោក នួន ជា បានបញ្ជាក់ហើយ គាត់បានបញ្ជាក់យ៉ាងច្បាស់ គាត់នៅតែបន្តបញ្ជាក់យ៉ាងច្បាស់ថា សហព្រះរាជអាជ្ញាមិនបានបង្ហាញអំពីសកម្មភាពរបស់លោក នួន ជា ពាក់ព័ន្ធទៅនឹងចំណុចទាំងពីរ ជាពិសេសពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជននោះទេ។

[១៣:៥៣:២២]

ហើយការលើកឡើងចោទប្រកាន់នោះ គឺមិនត្រឹមត្រូវតាមច្បាប់អន្តរជាតិនោះឡើយ។ ដូច្នេះហើយអង្គជំនុំជម្រះត្រូវតែអនុវត្តវិធីសាស្ត្រឱ្យបានត្រឹមត្រូវ ធ្វើការកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះហើយធ្វើការកម្រិតទៅលើចំនួនឯកសារ ដែលបានបង្កើតឡើងដោយវាយតម្លៃថាវាពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១។

នៅពេលនេះអង្គជំនុំជម្រះបានជូនដំណឹងរួចមកហើយ គឺយើងត្រូវពិភាក្សាទៅលើតម្លៃនៃឯកសារដែលភាគីទាំងអស់ត្រូវតែយកមកបង្ហាញ ហើយត្រូវតែបំពេញលក្ខខណ្ឌឱ្យបានត្រឹមត្រូវ ហើយដោយគោរពទៅតាមកិច្ចបំបែកនីតិវិធី។ នៅពេលនេះ ខ្ញុំសូមលើកឡើងទៅលើឯកសារជាក់លាក់នីមួយៗ ហើយប្រសិនបើខ្ញុំអាចនោះ គឺខ្ញុំសូមលើកឡើងសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

ខ្ញុំមិននិយាយអំពីបញ្ហាបកប្រែនោះទេ។ យើងខ្ញុំបានបញ្ជាក់ជូនអង្គជំនុំជម្រះរួចមកហើយតាមរយៈអ៊ីម៉ែលរបស់យើងកាលពីសប្ដាហ៍មុន។ យើងខ្ញុំមិនបានជំទាស់ទៅនឹងការលើកឡើងទាំងអស់នោះទេ ក៏ប៉ុន្តែយើងខ្ញុំសូមរក្សាសិទ្ធិដាក់សេចក្ដីសន្និដ្ឋានបន្ថែម ប្រសិនបើចាំបាច់នៅពេលដែលយើងពិនិត្យចុងក្រោយទៅលើការបកប្រែ។ យើងដឹងអំពីបទពិសោធន៍ និងអំពីការលំបាកចំពោះការបកប្រែ។ ខ្ញុំសូមលើកឡើងចំពោះខ្លឹមសារនៃឯកសារ ខ្ញុំសូមចាប់ផ្ដើមពីសេចក្ដីសន្និដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយខ្ញុំលើកអំពីបញ្ហាពាក់ព័ន្ធនៃឯកសារ។

[១៤:៥៥:១៥]

ឧបសម្ព័ន្ធ៧(ក) ដែលបានចែកជូនកាលពីសប្ដាហ៍មុន គឺឯកសារ បញ្ជីឯកសារចំនួន១០ ដែលយើងយកមកដេញដោលនៅក្នុងថ្ងៃនេះ។ ជាថ្មីម្ដងទៀត ខ្ញុំលើកឡើងឯកសារនេះដំបូង ដោយសារតែវាជាឯកសារចុងក្រោយនៅក្នុងបញ្ជីនុំង!។ ដូច្នេះខ្ញុំសូមលើកឡើងថា ឯកសារទាំងអស់នេះប្រាំបួនក្នុងចំណោមដប់នោះ គឺមិនពាក់ព័ន្ធនៅក្នុងសំណុំរឿង០០២/០១នោះទេ។ ដូច្នេះហើយ ឯកសារចំនួនប្រាំបួនក្នុងចំណោមដប់នោះ វានិយាយអំពីការអនុវត្តគោលនយោបាយ គឺមិននិយាយអំពីការផ្លាស់ទីលំនៅប្រជាជននោះឡើយ។ ដូច្នេះក្រោយពីយើងមើលទៅលើឧបសម្ព័ន្ធ៧(ក) នេះរួចមក វាបានបញ្ជាក់ថាយោងតាមលិខិតថ្ងៃទី៨ ខែមីនា របស់សហមេធាវីនាំមុខ គាត់បានលើកឡើង ខ្ញុំសូមអាន "ឯកសារទាំងអស់នេះ គឺវាមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ នោះទេ ដូច្នេះហើយវាមិនពាក់ព័ន្ធនោះឡើយ"។ ឯកសារចុងក្រោយ គឺវាពាក់ព័ន្ធទៅនឹងប្រវត្តិនៃបក្សកុម្មុយនីស្ដកម្ពុជា ដូចដែលយើងបានលើកឡើងកាលពីលើកមុន ហើយវានៅតែបើកឲ្យយើងធ្វើការជំទាស់នៅឡើយចំពោះឯកសារចុងក្រោយនេះ។

ខ្ញុំហាក់ដូចជាមានការភ័ន្តច្រឡំ ខ្ញុំមានការច្រឡំ ចំពោះការបញ្ចូលឯកសារនៅក្នុងបញ្ជីនេះ ហើយខ្ញុំដឹងថា សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គាត់នឹងបញ្ជាក់អំពីបញ្ហានេះ។

[១៣:៥៧:០៣]

ខ្ញុំសូមលើកឡើងចំពោះឯកសារ ក.ស.ព សហព្រះរាជអាជ្ញា ដែលខ្ញុំសូមលើកឡើងអំពីភាពពាក់ព័ន្ធទៅនឹងឯកសារទាំងអស់នោះ។ នៅក្នុងថ្ងៃនេះ ខ្ញុំសូមយោងទៅលើ E164/4 ដែលមានសរសេរយោងនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះ។ ជាពិសេសខ្ញុំសូមបញ្ជាក់សេចក្ដីសន្និដ្ឋានដែលបានលើកឡើងជាទូទៅ ដែលក្នុងនោះនិយាយរៀបរាប់ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ក្រោយពីយើងមើល

ទៅលើសេចក្តីសន្និដ្ឋានសារណាទាំងអស់នោះ។ ឯកសារទាំងអស់នោះ ភាគច្រើនគឺវាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ នេះផងដែរ។ ឯកសារមួយចំនួន គឺវាមិនពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធប្រព័ន្ធទំនាក់ទំនងនោះឡើយ។

ដូច្នេះហើយ ឯកសារទាំងអស់នោះ គឺវាពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយតែប៉ុណ្ណោះ។ វាមិនពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជន ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនោះឡើយ។

[១៣:៥៨:១៩]

ដូច្នេះហើយ អង្គជំនុំជម្រះត្រូវតែព្យាយាមដកឯកសារទាំងអស់នេះចេញ ដើម្បីឱ្យយើងគ្រប់គ្រងសំណុំ *ដូស្សេ* ឯកសារបាននៅក្នុងដំណាក់កាលចុងក្រោយ។ ហើយដើម្បីឱ្យអង្គជំនុំជម្រះអាចរៀបចំសវនាការនេះឱ្យបានត្រឹមត្រូវ ហើយអាចបញ្ចូលឯកសារឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ដើម្បីជៀសវាងត្រូវភាពច្រឡូកច្រឡំពិនិត្យមើលឯកសារនីមួយៗនៅក្នុងបញ្ជីទាំងអស់នោះ ខ្ញុំសូមលើកឡើងជាទូទៅថា ប្រហែលជានៅថ្ងៃស្អែកព្រឹក ខ្ញុំនឹងចែកជូនភាគីជាលាយលក្ខណ៍អក្សរទៅនឹង ចំពោះឯកសារទាំងឡាយណាដែលយើងគិតថា វាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ ហើយភាគីអាចធ្វើការឆ្លើយតបនៅចុងសប្តាហ៍នេះបាន។

[១៣:៥៩:១៩]

នេះគឺជាចំណុចទូទៅដែលខ្ញុំសូមលើកឡើង។ ខ្ញុំសូមចាប់ផ្តើមទៅលើឯកសារ A6 ប្រវត្តិរូបកម្ពុជាប្រជាធិបតេយ្យ។ ជំហររបស់យើងខ្ញុំ សូមបញ្ជាក់ថា ប្រវត្តិរូបទាំងអស់នេះត្រូវចាត់ទុកថា វាជាចម្លើយសារភាពដែលបានធ្វើឡើងក្រោមការគំរាមការធ្វើទារុណកម្ម ការធ្វើទារុណកម្ម ហើយវាធ្វើឡើងដោយមានការបង្ខំ។ អនុលោមតាមវិធាន២១ យើងមិនអាចទទួលយកបាននោះទេ។ ដូច្នេះហើយជាបឋម ភស្តុតាងដែលទទួលបានចម្លើយសារភាព ភស្តុតាងដែលទទួលបានតាមការធ្វើទារុណកម្ម គឺយើងមិនអាចទទួលយកបាននោះទេ។ ដូច្នេះខ្ញុំសូមលើកឡើងនូវអ្វីដែលបានលើកឡើងដោយលោកប្រធាន និងលោកស្រីចៅក្រម ខាតវ៉ាយថ៍ នៅក្នុងសំណុំរឿង០០១ ទំព័រទី០៦ នៃប្រតិចារឹក ថ្ងៃទី២០ ខែ០៥ ឆ្នាំ២០០៩។ ភាគីត្រូវបានរំឭកអំពីមាត្រាដែលមាននៅក្នុងអនុសញ្ញាស្តីអំពីទារុណកម្ម ភាគីត្រូវគិតអំពីចម្លើយសារភាពដែលទទួលបានក្រោមទារុណកម្ម គឺមិនអាចទទួលយកបានចំពោះបុគ្គលដែលត្រូវបានគេចោទប្រកាន់នោះឡើយ។

[១៤:០០:៤៨]

ដូច្នេះហើយនៅថ្ងៃនោះ ក្រោយពីរបីថ្ងៃ ចៅក្រម ខាតវ៉ាយថ៍ បានលើកឡើង។ ខ្ញុំលើកឡើងចេញពីសំណុំរឿង០០១ ប្រតិចារឹកជំនុំជម្រះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ត្រង់ទំព័រ០៩។ ចៅក្រម ខាតវ៉ាយថ៍ លើកឡើងថា អង្គជំនុំជម្រះសូមបញ្ជាក់អំពីសារៈសំខាន់នៃអង្គហេតុដែលត្រូវគោរពតាមអនុញ្ញាស្តីអំពីការប្រឆាំងទារុណកម្ម មាត្រា១៥ ហើយក៏មានឆ្លុះបញ្ចាំងនៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាននៅក្នុងវិធាន២១(៣) ផងដែរនៃក្នុងវិធានផ្ទៃក្នុង។ ការធ្វើទារុណកម្ម ការគំរាមកំហែងដែលធ្វើឡើងចំពោះអ្នកត្រូវបានគេសម្ភាស មិនអាចយកចម្លើយមកប្រើប្រាស់នោះបានឡើយ។ ចម្លើយសារភាពដែលបានធ្វើឡើងក្រោមការទារុណកម្មមិនអាចទទួលយកបានឡើយ។ ក៏ប៉ុន្តែ ខ្លឹមសារនៃចម្លើយសារភាពនោះ គឺមិនអាចទទួលយកផងដែរ។

[១៤:០២:០០]

ប្រសិនបើចៅក្រមចង់យោងទៅលើ-- ភាគីណាមួយចង់យោងទៅលើខ្លឹមសារនៃចម្លើយសារភាពត្រូវ-- ភាគីទាំងអស់ត្រូវតែបញ្ជាក់ថា ចម្លើយខ្លឹមសារទាំងអស់នោះមិនត្រូវបានធ្វើឡើងក្នុងពេលធ្វើទារុណកម្មនោះឡើយ។

ដូច្នេះ បន្ថែមទៅលើលោក សុន អរុណ គាត់បានលើកឡើង នៅពេលអង្គជំនុំជម្រះចង់ប្រើឯកសារទាំងអស់នេះជាឯកសារបន្ទាប់បន្សំ ជាពិសេសចំពោះឯកសារប្រវត្តិរូប អង្គជំនុំជម្រះត្រូវតែមានការប្រុងប្រយ័ត្ន ត្រូវគោរពទៅលើវិធីសាស្ត្រនេះ។ ហើយត្រូវតែពិចារណាថា បុគ្គលដែលគាត់ជាអ្នករៀបចំចម្លើយសារភាពនេះ គួរតែមកចូលរួមក្នុងសវនាការ ដើម្បីបញ្ជាក់ឲ្យបានត្រឹមត្រូវ ថាតើឯកសារទាំងអស់នោះមានការធ្វើទារុណកម្មដែរឬទេ?

[១៤:០២:៥៤]

ឯកសារកម្ពុជាប្រជាធិបតេយ្យ គឺវាមិនមានភាពពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធប្រព័ន្ធទំនាក់ទំនងឡើយ។ ឯកសារប្រភេទនេះ គឺយើងមិនអាចទទួលយកបាន និងមិនពាក់ព័ន្ធ។

ប្រភេទទីប្រាំបី កំណត់ហេតុនៅក្នុងស្រុក យើងគិតថា វាជាការធ្វើបាបទៅលើបុគ្គល និងសហករណ៍ជាក់លាក់។ ដូច្នេះវាពាក់ព័ន្ធទៅនឹងការអនុវត្តគោនយោបាយ ហេតុដូច្នេះមិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ នោះឡើយ។ A9 កំណត់ហេតុអ្នកទោសស-២១ វាមិនពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធប្រព័ន្ធទំនាក់ទំនងនោះទេ។ ឯកសារទាំងអស់នោះ គឺវាពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយ ដូច្នេះមិនពាក់ព័ន្ធទៅនឹងការជំនុំជម្រះនេះឡើយ។

[១៤:០៣:៥៧]

ខ្ញុំសូមចូលទៅដល់ A10 គឺចម្លើយសារភាពពីស-២១ ដែលជាឯកសារជាប់ទាក់ទងទៅនឹងឯកសារ E9/31។ ប្រតិចារឹកនៃសំណុំរឿង០០២/០១ ដូចដែលលោក សុន អរុណ គាត់បានលើកឡើងរួចមកហើយ ដូច្នេះមិនលើកឡើងតទៅទៀតទេ ដែលថាឯកសារប្រហែលជា៣០ ពាក់ព័ន្ធនៅក្នុងសវនាការចំណុចនេះ ហើយ A14 គឺវាពាក់ព័ន្ធទៅនឹងរបាយការណ៍កំណត់ទីតាំងសម្លាប់មនុស្ស ហើយ A15 ទាក់ទងទៅនឹងផែនទី ក៏ដូចជារូបថតផ្សេងៗ ហើយ A16 នោះ គឺជាឯកសារពាក់ព័ន្ធទៅនឹងការថតសំឡេង និងការថតជាវីដេអូ។ ហើយឯកសារទាំងអស់នេះ គឺមានការពាក់ព័ន្ធនោះទេ ជាពិសេសទាក់ទងទៅនឹងប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា។

[១៤:០៥:០០]

ដូច្នេះ ដោយយើងខ្ញុំសុំស្នើថា យើងនឹងធ្វើការជំទាស់ទៅនឹងឯកសារទាំងអស់នេះ ការប្រើប្រាស់នូវកំណត់ត្រា ក៏ដូចជាខ្សែអាត់ថតសំឡេង និងវីដេអូនេះផង។ នេះដោយសារថាខ្សែអាត់ថតសំឡេងក៏ដូចវីដេអូនេះ អាចនឹងធ្វើការ *អេឌីត* គឺកែប្រែនៅខាងក្រៅ។ ដូច្នេះ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាពិចារណាមុននឹងពិនិត្យទៅលើឯកសារទាំងអស់នេះ ហើយ A17 និងA18 គឺទាក់ទងទៅនឹងឯកសារទំនាក់ទំនងផ្សព្វផ្សាយជាអន្តរជាតិ គឺរបាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ។ យើងខ្ញុំជាមេធាវីការពារក្តី យើងយល់ឃើញថា យើងនឹងមិនជំទាស់ទៅនឹងឯកសារទាំងនេះទេ គឺថាយើងមិនចង់ យើងខ្ញុំមិនស្នើឲ្យមានបទដ្ឋានស្តង់ដារ ក្នុងការទទួលយកនូវឯកសារទាំងអស់នេះនោះទេ។

ហើយទាក់ទងទៅនឹងរបាយការណ៍នៃស្តីអំពីការផ្ទេរសិទ្ធិក្នុងការស៊ើបសួរ ទាក់ទងទៅនឹងចំណុចទាំងអស់នេះ យើងខ្ញុំបានយោងទៅនឹងការជំទាស់មុនៗ គឺការជំទាស់បឋម ដែលយើងបានលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហានេះផងដែរ។ ហើយនេះ គឺជាចុងបញ្ចប់នៃឯកសារដែលលើកឡើងដោយការិយាល័យ ដោយសហព្រះរាជអាជ្ញា។ ហើយនេះ យើងខ្ញុំសូមចូលទៅដល់សៀវភៅរបស់លោក ម៉ៃខល វីកឃើរី (Michael Vickery) ឆ្នាំ៧៥, ៧៦។ គឺឯកសារ D222/1/7 ដូចខ្ញុំបានបញ្ជាក់ពីមុនដូចខាងដើមហើយ គឺថាយើងខ្ញុំបានស្នើសុំឲ្យកោះហៅលោក វីកឃើរី ដើម្បីមកធ្វើការផ្តល់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះ។

[១៤:០៧:១១]

មិនទាន់ចុងក្រោយបង្អស់នៅឡើយទេ ឥឡូវនេះ ខ្ញុំកំពុងពិនិត្យមើលឯកសារពាក់ព័ន្ធទៅនឹង

ឧបសម្ព័ន្ធ ជាប់ពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន គឺក៏ដូចជាឯកសាររបស់ អៀង សារី ផងដែរ។ ចំពោះឯកសារពាក់ព័ន្ធទៅនឹងក្រុមរបស់ អៀង សារី ខ្ញុំមិនមានការជំទាស់ជាទូទៅអ្វីនោះទេ។ ក្នុងបញ្ជីដែលខ្ញុំលើកឡើងនេះ គឺមានឯកសារចំនួនបួន។ ខ្ញុំសូមអានឯកសារទាំងបួននេះ ទីមួយ D210/5 និង E109/1.01 ហើយក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងការសម្ភាសន៍លោក អ៊ុក ប៊ុនឈឿន ក្នុងឆ្នាំ ១៩៧៩ ដែលគាត់ជា-- ហើយក៏ដូចជាការសម្ភាសទៅលើសមាជិកព្រឹទ្ធសភា ដែលបដិសេធមិនចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ។ ឯកសារ គឺ RI19.58 ឯកសារពាក់ព័ន្ធទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ផងដែរ។ ឯឯកសារទីបីនេះ គឺ IS21.74 គឺជាសារទូរលេខដែលផ្ញើពីមក មាស មុត គឺដែលមានលេខ E870 សុំកែប្រែ គឺE-- បាទ របស់មន្ទីរ៨៧០ ហើយមានឯកសារ IS19.51 គឺកិច្ចសម្ភាសន៍ជាមួយនឹងលោក ហោ ណាំហុង ដែលសព្វថ្ងៃជារដ្ឋមន្ត្រីក្រសួងបរទេស ដែលបានបដិសេធមិនចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ។

[១៤:០៩:០៣]

ទាក់ទងទៅនឹងឯកសារទាំងបួននេះ ខ្ញុំយល់ឃើញថាដោយសារតែមានការជ្រៀតជ្រែកខាងផ្នែកនយោបាយ នោះវាចំណុចមួយដ៏សំខាន់ និងចំណុចមួយដែលពាក់ព័ន្ធយ៉ាងខ្លាំងបំផុត មកដល់សំណុំរឿងនេះ នៅចំពោះមុខអង្គជំនុំជម្រះ។ ហើយយើងខ្ញុំបានទទួលព័ត៌មានថានឹងពិភាក្សាទៅលើឯកសារថ្មីៗជាបន្តបន្ទាប់ តើ-- ហើយជាពិសេសគឺឯកសារ E1.71/2/5។ យើងខ្ញុំសួរថាតើ ឯកសារទាំងអស់នេះ យើងខ្ញុំអាចនឹងធ្វើការទៅលើខ្លឹមសារ ហើយនិងធ្វើការស្នើសុំបានដោយរបៀបណាដែរ? នេះខ្ញុំមិននិយាយពាក់ព័ន្ធឯកសារនៅថ្ងៃនេះទេ គឺឯកសារថ្មីដែលត្រូវពិភាក្សានៅថ្ងៃបន្តបន្ទាប់។

[១៤:០៩:៥៨]

យើងខ្ញុំសូមស្នើថា តើយើងនឹងអាចមានការពិភាក្សាទៅលើតម្លៃនៃភស្តុតាងនៃឯកសារនោះបាននៅពេលណាដែរ?

ហើយចំណុចចុងក្រោយសម្រាប់យើងខ្ញុំនៅរសៀលនេះគឺ នៅដំណាក់កាលចុងក្រោយនិយាយអំពីការវាយតម្លៃរបស់ ហ៊ុន សែន ទាក់ទងទៅនឹងឯកសារ E176 គឺមានការស្នើសុំឱ្យចាត់វិធានការប្រឆាំងទៅនឹងនាយករដ្ឋមន្ត្រីនៅពេលថ្មីៗ គឺគាត់បានធ្វើការចោទប្រកាន់មកលើកូនក្តីខ្ញុំថា ជាមនុស្សច្រងេងច្រងាង។ ហើយនៅឯកសារ E176 នេះគឺសូមឱ្យមានការពិចារណាទៅលើឯកសារនេះ ព្រោះ

យើងយល់ឃើញថា វាគឺជាការគំរាមកំហែងមួយ។ ខ្ញុំគិតឃើញថា ឥរិយាបថបែបនេះ ត្រូវតែមានការធ្វើការតម្រូវឲ្យមានការធ្វើការកែតម្រូវ ដោយយោងទៅលើវិធាន៧៥ ទាក់ទងទៅនឹងព័ត៌មានថ្មីៗដែលលេចឡើងទាក់ទងទៅនឹងសំណុំរឿងនេះ។

នេះគឺជាអ្វីដែលខ្ញុំត្រូវលើកឡើងជូនអង្គជំនុំជម្រះនារសៀលនេះ គឺសូមបញ្ចប់តែប៉ុណ្ណេះ ហើយសូមអរគុណអង្គជំនុំជម្រះ។

[១៤:១១:២៥]

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយក្រុមមេធាវីការពារក្ដីលោក នួន ជា តើមានអីទៀតទេ?

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំចប់ហើយលោកប្រធានមិនមានអ្វីទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ចុះលោក ក្រុមមេធាវីការពារក្ដីលោក អៀង សារី?

សូមអញ្ជើញបាទ!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ក៏ដូចសហការី ក៏ដូចជាអស់លោក លោកស្រីទាំងក្នុងនិងក្រៅបន្ទប់សវនាការ។ យើងខ្ញុំមានការកត់សម្គាល់ខ្លះៗទាក់ទងទៅនឹងប្រភេទឯកសារផ្សេងៗដែលបានៗដែលបានស្នើ-- ដែលបានដាក់ជូនអង្គជំនុំជម្រះដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនិងសហព្រះរាជអាជ្ញា។

កំណត់សម្គាល់ទូទៅរបស់យើងខ្ញុំ លោកប្រធានគឺដូច្នេះយើងនឹងចូលទៅក្នុងប្រភេទនីមួយៗ។ ក្រោយនេះគឺថាយើងមិនអាចចូលទៅលើប្រភេទឯកសារនីមួយៗដែលយើងត្រូវជំទាស់បានទេ។ ដូច្នេះខ្ញុំសូមលើកទៅតាមប្រធានបទរបស់ឯកសារនេះទៅចុះ ហើយខ្ញុំសូមលើកឧទាហរណ៍ដើម្បីឲ្យយល់ថាតើខ្ញុំនិយាយអំពីអ្វី?

[១៤:១២:៥៩]

គោលជំហរជាមូលដ្ឋានរបស់យើងខ្ញុំនោះគឺថា សហព្រះរាជអាជ្ញាកំពុងតែគ្របដណ្ដប់ទៅលើសំណុំរឿងនេះដោយមិនបង្ហាញនូវភស្តុតាងអីទេ ដោយគ្រាន់តែស្នើសុំឲ្យទទួលយកនូវឯកសារតែ

ប៉ុណ្ណោះ។ ឯកសារដែលបានមក គឺជាឯកសារមួយចំនួនធំដែលបានទទួលមក ហើយតាមការពិតយើងខ្ញុំចង់និយាយថា វាហាក់បីដូចជាញឹកញាប់ណាស់ដែលថា តាមពិតគេត្រូវ-- សូម្បីតែអ្នកមានជំនាញខាងផ្នែកក្រមវិជ្ជាជីវៈក៏ដោយ ក៏គេត្រូវធ្វើការសាកសួរដែរ។ ឧទាហរណ៍ បើសិនណាយើងធ្វើដាក់ជូននូវប្រវត្តិរូបណាមួយដោយមាននូវ-- ហើយភ្ជាប់មកសេចក្តីថ្លែងការណ៍ ៗរបស់សាក្សីមិនមែនជាប្រវត្តិរូបទេ។ ហើយយើងបែរជាត្រូវបង្ហាញនូវរបាយការណ៍ស្តីអំពីការផ្ទេរសិទ្ធិស៊ើបសួរជាដើម។ល។ នេះជាការបញ្ជាក់ច្បាស់ហើយ ជំហររបស់យើងខ្ញុំគឺថា ដូចដែលក្រុម នួន ជា បានលើកឡើងរួចមកហើយថា ឯកសារទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងអំពើរបស់ជនជាប់ចោទមិនអាចទទួលយកបាន មិនត្រូវទទួលយកបានដោយមិនមានការសួរយកសក្ខីកម្ម ឬក៏សួរតទល់ជាមួយនឹងសាក្សីនោះទេ។

[១៤:១៤:៣១]

នៅក្នុងឱកាសជាច្រើន ជាពិសេសឱកាសនេះតែម្តង គឺសហព្រះរាជអាជ្ញាបានលើកឡើងអំពីយុត្តិសាស្ត្ររបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ។ វាជាការពិត វាជាយុត្តិសាស្ត្ររបស់ អាយ.ស៊ី.ធី.វ៉ាយ។ យើងធ្លាប់ធ្វើការនៅទីនោះដូចគ្នា គឺថាសេចក្តីថ្លែងការណ៍ទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសកម្មភាពរបស់ជនជាប់ចោទគឺមិនអាចទទួលយកបានទេ បើ-- លើកលែងតែសាក្សីដែលបំភ្លឺនោះ ត្រូវបានចូលខ្លួនមកតុលាការ ដើម្បីបំភ្លឺជូនទៅតុលាការ។

ឥឡូវនេះ យើងខ្ញុំសូមចូលទៅប្រភេទឯកសារមួយចំនួនទៀត ដែលខ្ញុំសូមចាប់ផ្តើមជាមួយនឹងប្រវត្តិរូបតែម្តង។ ប្រហែលជាមានការលើកឡើងដដែលៗ តាមដែលខ្ញុំស្តាប់តាមរយៈក្រុម នួន ជា មក។ ខ្ញុំសូមធ្វើការកែប្រែ បើសិនជាខ្ញុំអាចធ្វើទៅបាន។ អ្វីដែលខ្ញុំរៀបចំ ដើម្បីដាក់ជូនអង្គជំនុំជម្រះនេះ គឺយើងខ្ញុំមិនចង់ឲ្យមានការលើកឡើងដដែលៗនូវអ្វីដែលបានលើកឡើងរួចមកហើយ។ ដើម្បីកុំឲ្យមានការយល់ច្រឡំគ្នា គឺថាយើងខ្ញុំបានប្រកាន់យកជំហរនេះជាយូរណាស់មកហើយ។ យើងខ្ញុំយល់ថា អ្វីដែលក្រុម នួន ជា លើកឡើងទៅតាមអង្គហេតុ និងទៅតាមផ្លូវច្បាប់នោះ គឺថាជាការត្រឹមត្រូវ។ ហើយយើងខ្ញុំសម្រេចយក-- សម្រេចទទួលយកនូវជំហរនេះ។

ប្រវត្តិរូប យើងខ្ញុំសូមស្នើថា ប្រវត្តិរូបបន្ថែមទៅលើចម្លើយសារភាពដែលបានដោយការធ្វើទារុណកម្មនោះ ជាសេចក្តីថ្លែងការណ៍ ដែលជាចម្លើយមួយដែលទទួលបានពីអ្នកដែលមិនបានធ្វើសម្បថទេ ដូច្នេះយើងមិនអាចធ្វើការសួរតទល់ដេញដោលបាន។ ដូច្នេះយើងខ្ញុំសូមស្នើថា ប្រវត្តិរូបទាំងអស់នេះមិនអាចទទួលយកបាននោះទេ។ មានឯកសារប្រវត្តិរូបជាច្រើនទៀត E366-- D366/7.1.38 ឬ

ឯកសារ D366/7.1.42 គឺថាមានចម្លើយសារភាពពាក់ព័ន្ធទាំងប្រវត្តិរបស់អ្នកទោស ដែលបានមកដោយការធ្វើទារុណកម្ម នោះគឺថាមិនអាចទទួលយកបានទេ។ ប្រវត្តិរូបទាំងអស់នេះផ្ទាល់ បញ្ជាក់ឲ្យឃើញថា បានមកពីអ្នកទោស មិនមែនជាប្រវត្តិរូបដែលសរសេរឡើងដោយអ្នកណាដែលបានដាក់ពាក្យទៅធ្វើការ។ ឧទាហរណ៍ថាជា *ស៊ីវី* ជាប្រវត្តិការងារដែលត្រូវដាក់សុំការងារនោះទេ។

[១៤:១៧:៣១]

ដូច្នេះនៅក្នុងពេលនោះ គឺថាយើងមិនអាចមើលឲ្យបានច្បាស់លាស់ ដឹងច្បាស់លាស់ថា តើវាមានចំណុចសំខាន់កន្លែងណា ដែលយើងអាចពិនិត្យមើលបាននោះ។ ហើយប្រវត្តិរូបខ្លះ គឺពាក់ព័ន្ធទៅនឹង១សំណុំរឿង០០២/០១ នេះ នៅពេលនោះ គឺថាជនត្រូវចោទ អៀង ធីរិទ្ធ នោះ គឺថាត្រូវស្ថិតនៅក្នុងសំណុំរឿងនេះរួចហើយ គឺឯកសារ E366/7.1.402 សូមកែប្រែ .1.40 ហើយប្រហែលនេះ ពេលវេលាដល់ ដែលគេហៅថាយើងត្រូវបណ្ដុះបណ្ដាល ដាំកូនឈើហើយ គឺថាឯកសារទាំងឡាយណាពាក់ព័ន្ធទៅនឹង អៀង-- ឯកសារទាំងនេះ ពាក់ព័ន្ធទៅនឹង អៀង ធីរិទ្ធ ហើយដោយគាត់មិនមានឈ្មោះនៅក្នុងសំណុំរឿងនេះទេ។ ដូច្នេះឯកសារទាំងអស់នេះ គឺអាចទទួលបាន ប៉ុន្តែបើទទួលយក គឺវាអាចប៉ះពាល់ទៅដល់សិទ្ធិរបស់ជនជាប់ចោទដទៃទៀត។

[១៤:១៨:៣៦]

ដូច្នេះជំហររបស់យើងខ្ញុំនោះ គឺបើយើងយកឯកសារនោះមកពិភាក្សា ហាក់បីដូចជាយើងខ្ញុំកំពុងតែធ្វើជាមួយមេធាវីការពារក្ដីឲ្យរូបគាត់។ ដូច្នេះ វាអាចមានភស្តុតាងខ្លះ ដែលអាចនឹងត្រូវយកមកដោះស្រាយ ខ្លះដែលត្រូវច្រានចេញពីសំណុំរឿងដោយមិនយកមកពិភាក្សា ដោយសារថា បើធ្វើនេះនោះ វាមិនដឹងថាតើវានឹងមានភាពយុត្តិធម៌ និងត្រឹមត្រូវសម្រាប់ជនជាប់ចោទដទៃទៀត ឬក៏អត់នោះទេ។ យ៉ាងហោចណាស់ក៏វាពាក់ព័ន្ធទៅដំណាក់កាលនៃសំណុំរឿង០០២/០១ នេះផងដែរ។

ឯកសារមួយចំនួនទៀត វាមានចាត់ទុកជាឯកសារប្រវត្តិរូបដែរ នៅភាសាអង់គ្លេសមានលេខដោយយើងដាក់ចំណាត់ថ្នាក់លេខដូចគ្នានៅលើសំណុំរឿង ហាក់បីដូចជាប្រវត្តិរូប ហើយឯកសារខ្លះទៀតជាឯកសារ ហាក់ដូចជាមកពីកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏ជាសេចក្ដីសង្ខេប ឬក៏ជាប្រវត្តិរូប រូបថត ដែលបានទទួលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឧទាហរណ៍ ឯកសារទាំងនេះមាន IS19.46, IS19.157, IS3.5។ យើងខ្ញុំសូមស្នើថា ឯកសារទាំងអស់នេះមិនមែនជាប្រវត្តិរូបទេ ហើយដូច្នេះមិនត្រូវយកមកចាត់ថ្នាក់ជាឯកសារប្រវត្តិរូបនោះទេ មិនគួរមានចេតនាអាច

លួចយកដាក់ឯកសារនេះចូលក្នុងចំណាត់ប្រភេទប្រវត្តិរូបនោះទេ។

[១៤:២០:៣៣]

ឧទាហរណ៍បើសិនណាជាយើងមើលទៅលើឯកសារមួយច្បាប់ គឺឯកសារ 19.46 ឯកសារនេះហាក់ដូចជាឯកសារចុះថ្ងៃទី១០ ខែតុលា ២០០៣ ជាការសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ តើវាអាចជាប្រវត្តិរូបធ្វើម៉េចនឹងកើត? នៅពេលដែលមានគ្រាន់តែមានសំណួរ និងចម្លើយសួរឆ្លើយៗតែប៉ុណ្ណោះ។ ដូច្នេះប្រហែលជាឯកសារនេះមិនត្រូវយកមកពិនិត្យមើលទេ ហើយភ្ជាប់ជាមួយនឹងឯកសារនេះក៏មានប្រវត្តិរូបដែរ ប្រហែលជាក៏មិនពាក់ព័ន្ធនោះដែរ ប៉ុន្តែក្នុងទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថា វាអាស្រ័យទៅលើសហព្រះរាជអាជ្ញា ដែលត្រូវបង្ហាញឲ្យឃើញថា ហេតុអ្វីបានជាឯកសារប្រវត្តិរូបនីមួយៗ មានសារៈសំខាន់ចាំបាច់ ដើម្បីយកមកចោទសួរ ដើម្បីឲ្យមេធាវីការពារក្តីឆ្លើយថា ត្រូវទទួលឬមិនទទួលនោះ? វាអាចមានមធ្យោបាយមួយទៀត ដែលសហព្រះរាជអាជ្ញា ត្រូវពិចារណាខ្លួនឯងថាត្រូវដាក់ ឬមិនត្រូវដាក់។ ដូច្នេះបើធ្វើបែបនេះវាជាការកំណត់ចរិតលក្ខណៈ នៃឯកសារមិនត្រឹមត្រូវនោះទេ។

[១៤:២១:៥០]

ប្រហែលជាគួរណាស់តែមានការពន្យល់ពីសហព្រះរាជអាជ្ញាទៅវិញ ថាឯកសារដែលមិនមែនជាប្រវត្តិរូបទៅជាចាត់ចំណាត់ថ្នាក់ថា ជាប្រភេទនៃឯកសារប្រវត្តិរូបទៅវិញនោះ។ មានឯកសារមួយ D366/7.1831 គឺពាក់ព័ន្ធទៅនឹង TCW-724 ដែលត្រូវបកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារនេះមិនគួរទទួលយកនោះទេ។ ល្គឹកណា ឬក៏រហូតទាល់ដែលសាក្សីរូបនេះ បានចូលខ្លួនមកបំភ្លឺជូនតុលាការ។ បើឯកសារនេះជាប់ទាក់ទងទៅនឹងសាក្សី ដែលត្រូវបានកំណត់ឲ្យចូលខ្លួនមកហើយនោះ គឺឯកសារទាំងអស់នេះ គឺមិនទាន់ទទួលយកនៅពេលនេះនៅឡើយទេ រង់ចាំរហូតដល់ពេលសាក្សីរូបនេះចូលមកបង្ហាញខ្លួនដើម្បីបំភ្លឺទៅលើឯកសារនេះសិន។

នៅចំណុចខ្លះ ខ្ញុំដឹងថា សាក្សីរូបនេះមិនអាចចូលមកបាន មិនមានលទ្ធភាពចូលមកបានទេ។ ដូច្នេះមិនមានអ្វីដែលត្រូវរារាំងដល់សហព្រះរាជអាជ្ញា ដើម្បីធ្វើការស្នើសុំបន្ថែមទៀតថា ហេតុអ្វីឯកសារនេះដែលទាក់ទងទៅនឹងសាក្សីសំខាន់ៗបែបនេះ មិនអាចចូលខ្លួនមកបាននេះ មិនគួរទទួលយកនោះ ពីព្រោះថាវាជាការរារាំងទៅដល់ដំណើរការនៃការស្វែងរកយុត្តិធម៌។ ឯកសារទាំងឡាយណាដែលទាក់ទងទៅនឹងឯកសារដែលត្រូវបានអង្គជំនុំជម្រះ កំណត់កោះហៅឲ្យចូលខ្លួនមកហើយនោះ នោះមិន

ត្រូវទទួលយកឯកសារនេះ នៅពេលនេះនៅឡើយសិនទេ រហូតទាល់តែឯកសារទាំងអស់ អ្នកទាំងអស់នោះ ចូលខ្លួនមកបំភ្លឺជូនអង្គជំនុំជម្រះ។

[១៤:២៣:៣៧]

បើសិនសាក្សីចូលខ្លួនមកទាំងនេះ ហើយផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ នោះភស្តុតាងសំខាន់បំផុត គឺចេញមកពីមាត់របស់សាក្សីផ្ទាល់តែម្តង មិនមែនចេញពីឯកសារដែលបានដាក់ជូននេះទេ។ ដូច្នេះដើម្បីជាមូលហេតុនៃការពន្យល់ការគាំទ្រ ការពន្យល់របស់សាក្សីនោះ ប៉ុន្តែសេចក្តីថ្លែងណាមួយរបស់សាក្សី គឺមិនត្រូវទទួលយក ហើយកំណត់ភ្លាមៗទទួលភ្លាមៗទេ លុះណាតែមានការចោទសួរដេញដោលទៅលើសាក្សីរូបនោះជាមុនសិន ឬក៏ឯកសារនេះ គឺត្រូវបានយកមកប្រើប្រាស់ដើម្បី គេហៅបើថាបណ្តុះការចងចាំរបស់សាក្សីឡើងវិញនោះ បើថាមិនមានការសាកសួរតទល់ ទៅលើសាក្សីរូបនោះទេ គឺថា មិនត្រូវប្រើប្រាស់ទេ។ ឧទាហរណ៍ ការប្រើប្រាស់សេចក្តីចម្លើយសាក្សី ហើយយកចម្លើយសាក្សីនេះយកមកអះអាងថា វាពិតដោយមិនទាន់សួរនោះ។ ដូច្នេះក្នុងពេលនេះ យើងខ្ញុំសូមលើកឡើងថា ឯកសារទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសាក្សីដែលត្រៀមនឹងកោះអញ្ជើញឲ្យចូលខ្លួនមកតុលាការហើយ នោះឯកសារទាំងអស់នោះ គួរត្រូវពិចារណា នៅពេលសាក្សីទាំងនេះមកផ្តល់សក្ខីកម្មសិន បើមិននេះទេ វាជាការរំខាន វាជាការរារាំងទៅដល់ដំណើរការយុត្តិធម៌។

[១៤:២៥:០១]

លោកប្រធានជាទីគោរព! នេះជានីតិវិធីដែលជាទូទៅត្រូវបានយកទៅអនុវត្តនៅតុលាការមិនអចិន្ត្រៃយ៍ដទៃៗទៀត។ ហេតុដូច្នេះនេះគឺជាអ្វីដែលគេបានយកមកអនុវត្តជាទូទៅ ខ្ញុំមិនបានស្នើសុំថាអ្វីដែលវាពិសេស ដែលវាឆ្គាំឆ្គងរួចហើយត្រូវយកមកអនុវត្តនៅទីនេះ ឬក៏ឲ្យលើសពីវិសាលភាពនៃដំណើរការនីតិវិធីនៅ អ.វ.ត.ក នេះទេ។ ឯកសារខ្លះទៀត ឧទាហរណ៍ ឯកសារខ្លះទៀតមិនទាន់បានបកប្រែនៅឡើយទេ។ D2.15.6 តាមយោបល់របស់ខ្ញុំ ឯកសារនេះមិនទាន់បានបកប្រែនៅឡើយទេ។ ឯកសារនេះមិនអាចរកបានជាភាសាអង់គ្លេសទេ។ ហេតុដូច្នេះយើងខ្ញុំសូមស្នើថា មិនត្រូវទទួលយកឯកសារនេះទេ លុះណាតែឯកសារនេះបានរួចរាល់ បកប្រែរួចរាល់សិន។

[១៤:២៦:១៤]

បើសិនណាជាវាអាចលើសលុបពេកនោះ គឺថាសហព្រះរាជអាជ្ញាត្រូវពិនិត្យមើលឯកសារទាំងអស់នេះតែម្តង មិនត្រូវគ្រាន់តែស្មានៗនោះទេ គឺត្រូវពិនិត្យមើលឲ្យបានច្បាស់លាស់នូវឯកសារនីមួយៗ

ដែលខ្លួនភ្ជាប់ជាឧបសម្ព័ន្ធនេះថា វាជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១នេះ។ ហេតុដូច្នេះយើងខ្ញុំមេធាវីការពារក្ដីរង់ចាំការពន្យល់ពីខាងសហព្រះរាជអាជ្ញា។

ឥឡូវនេះយើងខ្ញុំសូមបន្តចូលទៅឯកសារពាក់ព័ន្ធទៅនឹងកំណត់ត្រាមួយចំនួន ឯកសារពាក់ព័ន្ធទៅនឹងបញ្ជីពាណិជ្ជកម្ម យើងខ្ញុំមិនចំណាយពេលច្រើនទេ ទុកជូនឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះដើម្បីពិចារណាទៅលើឯកសារទាំងពីរនេះ ថាតើត្រូវទទួលយក ឬក៏យ៉ាណានោះ? ឬថាតើវាពាក់ព័ន្ធឬក៏អត់នោះ?

[១៤:២៧:១៦]

ដូច្នេះយើងខ្ញុំទុកផ្ដល់ឆន្ទានុសិទ្ធិជូនអង្គជំនុំជម្រះសម្រេចទៅលើឯកសារ ទៅលើឯកសារនេះ។ ដូច្នេះជំហររបស់យើង គឺថាយើងខ្ញុំទុកជូននូវឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះពិចារណាទៅលើឯកសារទាំងនេះ។

សូមអធ្យាស្រ័យ ឯកសារបន្ទាប់ទៀតលោកប្រធាន គឺពាក់ព័ន្ធទៅនឹងឯកសារកំណត់ត្រានៅស្រុកត្រាំកក់។ ប្រហែលជាខ្ញុំលើកឡើងនូវការកត់សម្គាល់មានឯកសារភស្ដុតាងសំខាន់ៗមួយចំនួននៅក្នុងឯកសារទាំងនេះ។ ដោយសារឯកសារទាំងនេះ ឯកសារដើមគឺបាត់ហើយ ដោយសារថាបាត់ដោយសារតែសាស្ត្រាចារ្យ ប៉ែន យៀវនិន ជាអ្នកធ្វើឱ្យបាត់ប្រហែលជាមិនត្រូវស្ដីបន្ទោសគាត់ទេ ប៉ុន្តែគាត់បានយកឯកសារដើមទៅជាមួយគាត់ ហើយក្រោយគាត់ក៏ត្រូវប្រគល់ឯកសារទាំងនេះមកឱ្យក្រសួងមហាផ្ទៃវិញ។ ប៉ុន្តែមិនមានការកត់ត្រាណាមួយថា គាត់បានប្រគល់មកវិញទេ។

[១៤:២៨:៣៩]

មានឯកសារខ្លះទៀត គឺការសម្ភាសដែលធ្វើឡើងជាមួយលោក ជេ និយាយអំពីឯកសាររបស់គាត់ និងអ្វីដែលគាត់បានដឹងអំពីការសម្ភាសរបស់លោក ប៉ែន យៀវនិន ការឆ្លើយឆ្លងគ្នារវាងសាស្ត្រាចារ្យ ប៉ែន យៀវនិន និងសហចៅក្រមស៊ើបអង្កេតដែលគាត់បង្ហាញអំពីជំហររបស់គាត់ថាគាត់នឹងប្រគល់ឯកសារដើម។ ហើយប្រមាណប្រហែលជាដប់ឆ្នាំក្រោយមកទៀតនេះ គាត់បានដឹងថាឯកសារដើមបាត់អស់ទៅហើយ។ គាត់បានបញ្ជាក់ថា គាត់បានធ្វើការថតចម្លងឯកសារទាំងអស់នេះហើយ។ តែទោះជាយ៉ាងណាក៏ដោយយើងខ្ញុំក៏នៅស្នើសុំទុកឱ្យអង្គជំនុំជម្រះប្រើប្រាស់ឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់ខ្លួនដើម្បីពិចារណាទៅលើឯកសារនេះ ថាតើត្រូវ-- បើពិនិត្យទទួលយកភស្ដុតាងនេះគឺតែកោះហៅលោក យុ ឆាំង មកម្ដងទៀតដើម្បីឱ្យគាត់បំភ្លឺថាតើឯកសារដើមហ្នឹងវាយ៉ាងម៉េច? អ្វីបានកើត

ឡើងទៅដល់ឯកសារដើមហ្នឹង?

[១៤:២៩:៥១]

ដោយសារថា វាជារឿងមួយដែលសំខាន់ ឬក៏លោក ប៉ែន យៀរនិន នេះ សាស្ត្រាចារ្យ ប៉ែន យៀរនិន ត្រូវចូលខ្លួនមកតុលាការដើម្បីបំភ្លឺជូនតុលាការក្នុងនាមសាក្សីទៅលើឯកសារទាំងអស់នេះ។

ពាក់ព័ន្ធទៅនឹងឯកសារទាំងអស់នេះ យើងខ្ញុំសូមលើកឡើងថា ឯកសារមិនទាំងអស់នោះទេ មិនទំនងឯកសារទាំងអស់នេះស្ទើរតែមិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១។ ជាពិសេសប្រសិនបើ យើងកថាខណ្ឌដែលបានដកស្រង់។ ឧទាហរណ៍ D15.3 ថាវាជាឯកសារពាក់ព័ន្ធទៅនឹងការធ្វើបាប ទៅលើក្រុមគោលដៅ កថាខណ្ឌ២០៥ ទៅដល់២១៥នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សហករណ៍ ត្រាំកក់ កថាខណ្ឌ៣០២ ទៅដល់៣២២។ ហើយបទល្មើសលើជនជាតិចាម មន្ទីរសន្តិសុខ កថាខណ្ឌ ៤៨៩ ទៅដល់៥១៥។ យើងខ្ញុំយល់ឃើញថា លើកលែងតែខ្ញុំយល់ខុស យើងខ្ញុំយល់ឃើញថា កថាខណ្ឌទាំងអស់នេះ ត្រូវបានចាត់ទុកថាស្ថិតនៅក្នុងសំណុំរឿង០០២/០១។ ខ្ញុំយល់អំពីការព្យាយាម លើកឡើងរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងបរិបទ ហើយនិងទីកន្លែង ដែលវាអាចជាប់ទាក់ទង ទៅនឹងសំណុំរឿង០០២/០១ ក៏ប៉ុន្តែបើសិនជាយើងចាត់ទុកថាអ៊ីចឹងចុះ ប៉ុន្តែនៅពេលដែលយើងមើល ឯកសារទាំងអស់នោះ នៅពេលដែលសហព្រះរាជអាជ្ញាលើកឡើងតាមឯកសារទាំងអស់នេះ យើង យល់ឃើញថា វាហាក់ដូចជាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១។

[១៤:៣២:០១]

ឧទាហរណ៍ ការធ្វើប្រតិកម្មទៅលើក្រុមគោលដៅដែល--បើសិនជាមិនត្រូវយកមកពិភាក្សានៅ ក្នុងសវនាការនេះទេ។ ហេតុអ្វីចាំបាច់យកឯកសារទាំងអស់នេះ យកមកដាក់បញ្ចូលធ្វើអី។ ជំហររបស់ សហព្រះរាជអាជ្ញា ហាក់ដូចជាយល់ឃើញថា ពួកគាត់មានការសង្ស័យ។ ប្រសិនបើខ្ញុំបកស្រាយនូវអ្វី ដែលខ្ញុំមើលឃើញតាមសេចក្តីសន្និដ្ឋានរបស់ពួកគាត់ គឺពួកគាត់មានភាពសង្ស័យថាវាពាក់ព័ន្ធ។ ដូច្នេះ ហើយការធ្វើដូច្នេះ គឺការព្យាយាម ដើម្បីយកភស្តុតាងទាំងអស់ ដែលពួកគាត់គិតថាអាចជួយជ្រោម ជ្រែងទៅដល់ពួកគាត់នៅក្នុងរឿងក្តីទាំងអស់នេះ ទោះបីជារឿងក្តីនេះត្រូវបានបំបែកកិច្ចដំណើរការនីតិ វិធីក៏ដោយ។ ដូចដែលមេធាវីការពារក្តី នួន ជា បានលើកឡើង យើងខ្ញុំយល់ឃើញថា ហើយនិងលើក ឡើងថា ឯកសារទាំងឡាយដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ យើងអាចទទួលយកបាន។ ចំពោះរឿងក្តី ដំណាក់កាលក្រោយយើងត្រូវពិនិត្យមើលថាតើគួរទទួលយកបានដែរឬអត់? ហើយវាស្ថិតនៅក្នុងពេល

វេលាមួយសមស្រប ដែរឬទេ។

នៅពេលដែលយើងធ្វើដូច្នេះ គឺយើងត្រូវតែធ្វើការសង្ខេបទៅលើសក្ខីកម្ម និងឯកសារទាំងឡាយ ឲ្យមានស្ថិតនៅក្នុងលក្ខណៈមួយត្រឹមត្រូវ។ ហើយពេលនេះ យើងត្រូវតែមានការប្រុងប្រយ័ត្ន យើងត្រូវតែទទួលយកឯកសារទាំងឡាយណា ដែលពាក់ព័ន្ធតែប៉ុណ្ណោះ។

ឯកសារ D1115--

**អ្នកបកប្រែ៖**

បាទ សូមលោកប្រធាន អនុញ្ញាតឲ្យមេធាវីការពារក្ដីបញ្ជាក់លេខឯកសារឡើងវិញ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអំមិញ លេខERN ចុងក្រោយអំមិញ ឯកសារអំមិញខាងអ្នកបកប្រែ បកប្រែអត់ទាន់ទេ។ សូមលោកមេធាវីបញ្ជាក់សាឡើងវិញ។

[១៤:៣៤:១០]

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន។ ឯកសារទាំងពីរ គឺD1571.6 និងD157.35។ ឯកសារទាំងពីរនេះ វាជាសេចក្ដីសង្ខេបនៃចម្លើយសារភាព ដូច្នេះហើយវាមិនអាចទទួលយកបាន ដូចដែលហេតុផលដែលយើងបានលើកឡើងដោយផ្ទាល់មាត់ និងនៅក្នុងឯកសារសំណេរ ដែលវាជាឯកសារភស្តុតាងពាក់ព័ន្ធទៅនឹងទារុណកម្ម។ បញ្ហានេះ អង្គជំនុំជម្រះបានចេញដីកាបង្គាប់ និងសេចក្ដីសម្រេចរួចមកហើយ។ ឯកសារមួយទៀត គឺ D157.86 ឯកសារនេះ គឺមើលអត់យល់។ យើងខ្ញុំយល់ឃើញថា ឯកសារហ្នឹងមើលមិនយល់ មិនអាចបកប្រែទៅជាភាសាអង់គ្លេសផងដែរ។ ដោយសារឯកសារនេះ ជាភាសាខ្មែរ អ្នកបកប្រែគាត់មមើលអត់យល់។

ដូច្នេះ យើងខ្ញុំសូមបញ្ជាក់ជំហរថាឯកសារបែបនេះ មិនអាចយកមកបញ្ចូលនៅក្នុងសំណុំរឿងបានឡើយ។ ហើយប្រសិនបើខ្ញុំ លើកឡើងខុសនោះ សូមអភ័យទោស។ ក៏ប៉ុន្តែអ្វីដែលយើងយល់នោះ គឺថាយើងខ្ញុំត្រូវទៅមើលឯកសារនេះក្នុងរយៈពេលមួយខ្លះតែប៉ុណ្ណោះ។

[១៤:៣៥:៤២]

លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំសូមទទួលការណែនាំពីអង្គជំនុំជម្រះថានៅពេលរសៀលយើងឈប់សម្រាកនៅម៉ោងប៉ុន្មានដែរ ដោយសារតែខ្ញុំហាក់ដូចជាមានការយល់ច្រឡំទៅលើពេលវេលា

ថាតើពេលនេះជាពេលសម្រាក ឬក៏យ៉ាងណា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនលោកមេធាវី ដែលបានចាប់អារម្មណ៍ពីបញ្ហានេះ។ ហើយពេលវេលាសមល្មមនឹងសម្រាកហើយ។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៤:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីបន្តការបង្ហាញនូវសេចក្តីជំទាស់របស់ខ្លួន។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពអស់លោក លោកស្រីទាំងអស់។ ប្រភេទឯកសារបន្ទាប់ទៅទៀតនេះគឺឯកសារដែលបានចុះកំណត់ត្រាមកពីអ្នកទោសនៅស-២១។ យើងបានពិភាក្សាទៅលើឯកសារនេះទូលំទូលាយហើយ ប៉ុន្តែជំហររបស់យើងខ្ញុំ គឺថាអ្វីដែលពាក់ព័ន្ធទៅនឹងស-២១ ហើយដែលមានការមន្ទិលសង្ស័យហើយ បើសិនណាជា ឌុច ត្រូវចូលមកផ្តល់សក្ខីកម្ម ហើយលើកឯកសារនេះទៅសួរសាកសួរគាត់ ឬក៏ពិនិត្យពិភាក្សាសួរដេញដោលនៅចំពោះមុខគាត់។ ឯកសារមួយ គឺ D108/2.6.-- D108/26.135 ឯកសារនេះ មើលទៅគឺថាវាពាក់ព័ន្ធទៅនឹងអៀង ធីរិទ្ធ ហើយខ្ញុំសូមជំទាស់ទៅនឹងឯកសារនេះ កុំទទួលយកឯកសារនេះ ដោយសារថាមិនពាក់ព័ន្ធទៅនឹងរូបគាត់ទេ ដោយគាត់មិនមានឈ្មោះនៅក្នុងសំណុំរឿងកំពុងតែដំណើរការនីតិវិធីនេះទេ។

[១៥:០៥:៥៣]

ឯកសារមួយទៀតគឺចម្លើយសារភាពមកពីស-២១។ យើងខ្ញុំបានដាក់សំណើសុំជាលាយលក្ខណ៍អក្សរយ៉ាងទូលំទូលាយ។ ជំហររបស់យើងខ្ញុំមិនផ្លាស់ប្តូរក្រៅពីសំណើសុំនោះទេ ហើយក្រុម នួន ជា ក៏បានបញ្ជាក់ហើយថា ខ្លួនក៏នឹងត្រៀមខ្លួនដើម្បីជំទាស់ទៅនឹងឯកសារទាំងអស់នេះដែរ រក្សាជំហរដើម្បីជំទាស់ទៅនឹងឯកសារនេះ។ យើងខ្ញុំបានលើកឡើងនៅវសៀលនេះមកហើយ គឺជំហររបស់យើង គឺឯកសារចម្លើយសារភាពមកពីស-២១ គឺមិនត្រូវទទួលយកទេ។ បើចម្លើយសារភាពទាំងនោះ គឺទទួលមកបានផ្ទុយទៅនឹងច្បាប់អន្តរជាតិ។ ដូច្នេះ ឯកសារបែបនេះមិនត្រូវយកមកប្រើនៅចំពោះតុលាការនោះទេ។

[១៥:០៦:៤៦]

ប្រភេទឯកសារមួយទៀត គឺប្រតិចារឹកមកពីសំណុំរឿង០០១ កំណត់ហេតុជាលាយលក្ខណ៍អក្សរពេលជំនុំជម្រះនៃសំណុំរឿង០០១ ខ្ញុំសូមពន្យល់វែងឆ្ងាយបន្តិចទៅលើឯកសារប្រភេទនេះ។ ជំហររបស់ខ្ញុំ គឺថាសំណុំរឿង០០១ ឬប្រតិចារឹកនៃសំណុំរឿង០០១ មិនអាចទទួលយកទេ លើកលែងតែសាក្សីដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០១ ត្រូវបានកោះហៅដើម្បីមកផ្តល់សក្ខីកម្មទៅលើឯកសារនេះសាជាថ្មីឡើងវិញ។ មេធាវីការពារក្តីរបស់ ឌុច តាមដែលខ្ញុំដឹង គឺថាគាត់មិនបានជំទាស់តវ៉ាច្រើនទេទៅលើឯកសារទាំងអស់នេះ។ តាមផ្លូវច្បាប់ គឺថាវាមានយុត្តាធិការដែលអនុញ្ញាតឲ្យក្រុមមេធាវីនោះលើកឡើងនៅពេលធ្វើសេចក្តីសន្និដ្ឋានបិទនោះ។ ពួកគេមិនបានធ្វើការជំទាស់តវ៉ាទៅលើ ស្នើសុំឲ្យហៅសាក្សីទេ ដោយសារកូនក្តីរបស់ពួកគាត់បានផ្តល់ចម្លើយដែលបានគាំទ្រ ក៏ដូចជាស៊ីសង្វាក់ទៅនឹងការទទួលពីចម្លើយថា គាត់មានកំហុស គាត់ទទួលកំហុសរបស់គាត់ទាំងស្រុងតែម្តង។

[១៥:០៨:១០]

ដូច្នេះយុត្តិសាស្ត្រដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង០០១ នេះមេធាវីក្រុមនេះ គឺមិនមែនជាយុត្តិសាស្ត្រដែលបានប្រើប្រាស់សម្រាប់នៅក្នុងសំណុំរឿងនៅចំពោះមុខនេះទេ។ ការដែលខ្ញុំលើកឡើងនេះ គឺដោយខ្ញុំមិនចង់ឲ្យមេធាវីការពារ ឌុច ការប្រើការសាកសួរសាក្សី ដើម្បីលើកឡើង ឬក៏ថាហៅសាក្សីទាំងអស់នោះមកប្រឈមមុខនោះទេ។ ដូច្នេះ វាជារឿងមួយដែលផ្ទុយគ្នាស្រឡះ។ ដូច្នេះមិនត្រូវទទួលឯកសារប្រភេទនេះបានទេ។ បើឯកសារទាំងអស់នេះអាចចូលខ្លួនមកបាន នោះគេត្រូវតែចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ ដើម្បីផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ បើមិនអាចមកទេ នោះនឹងត្រូវធ្វើការ

វាយតម្លៃផ្សេងពីនេះ។ បើសិនណាជាសក្ខីកម្មនោះវាមិនពាក់ព័ន្ធទៅដល់ទង្វើ និងសកម្មភាពរបស់ជនជាប់ចោទទេ នោះអង្គជំនុំជម្រះត្រូវពិចារណាទៅលើចំណុចនេះ។

ដូច្នេះជំហររបស់យើងខ្ញុំ ប្រតិចារឹកពីសំណុំរឿង០០១ នេះ មិនអាចត្រូវយកមកប្រើប្រាស់នៅពេលនេះបានទេ។ យើងខ្ញុំដាក់សំណើសុំមួយចំនួន ការដែលយើងខ្ញុំប្រើពាក្យថា "យើងខ្ញុំ" បែបនេះ គឺខ្ញុំតំណាងឲ្យមេធាវីការពារក្ដីក្រុម អៀង សារី ទាំងមូលតែម្ដង។ ជាពិសេសនៅ អាយ.ស៊ី.ធី.វ៉ាយ និងតុលាការមួយចំនួនទៀត ហើយដោយសារមេធាវីមួយចំនួនមកពី អាយ.ស៊ី.ធី.វ៉ាយ គឺនៅក្នុងរឿងក្ដីតូចៗផង គឺថាគេព្យាយាមដាក់ចូលនូវឯកសារតូចតាចប៉ុនណាក៏ដោយ ព្យាយាមដាក់បញ្ចូលដោយ-- ដោយសារតែមេធាវីការពារក្ដី គឺថាមានការជំទាស់តវ៉ាថា តើឯកសារណាគួរត្រូវដាក់ ឬមិនត្រូវដាក់? ប៉ះពាល់ដល់កូនក្ដី ឬក៏អត់? ដូច្នេះ គេស្គាល់ប្រវត្តិសាវតារនៃឯកសារ ថាតើបើដាក់ទៅ វាត្រូវប្រឈមមុខនឹងការជំទាស់តវ៉ាណា?

[១៥:១០:១៧]

ដូច្នេះនៅពេលសំណុំរឿងក្រោយចូលមក អ្វីដែលគេធ្វើ គឺក្រុមមេធាវីការពារក្ដីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលទៅលើយុត្តាធិការនៃអង្គហេតុ។ អង្គហេតុដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះ និងផ្ដល់សក្ខីកម្ម ទៅតាមរយៈនៃការធ្វើប្រតិចារឹកនេះឯង។ អ៊ីចឹងតាមរយៈការអនុវត្តជាក់ស្ដែងនេះ ហើយខាងផ្នែកសហព្រះរាជអាជ្ញាវិញ គឺយើងទាក់ទងសហព្រះរាជអាជ្ញាយើងបានដាក់ឯកសារសំណើសុំមួយចំនួនផងដែរ។ ដូច្នេះ ជំហររបស់យើងខ្ញុំច្បាស់លាស់ហើយ គឺថាប្រតិចារឹកមិនត្រូវទទួលយកទេ លុះណាតែជនទណ្ឌិតរូបនេះចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះដើម្បីបំភ្លឺ។

[១៥:១១:១០]

ចំណុចមួយទៀត គឺនិយាយអំពីរបាយការណ៍ស្ដីអំពីការកំណត់អត្តសញ្ញាណទីកន្លែង។ ក្រុមមេធាវីការពារក្ដី នួន ជា បានលើកឡើងចំពោះរបាយការណ៍នេះហើយ ជាពិសេសទាក់ទងទៅនឹងឯកសារ D232/108 គឺ D232/108 និង ឯកសារ D369/38។

សំណូមពររបស់ក្រុមយើងខ្ញុំនោះ គឺរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងនេះ គឺសំអាងទៅលើការសម្ភាសសាក្សីដោយសហចៅក្រមស៊ើបអង្កេតនិងសាក្សីពាក់ព័ន្ធមួយចំនួនទៀត ហើយអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានរៀបចំរបាយការណ៍នេះ និងទទួលយកភស្តុតាង ហើយឯកសារ

នេះ គឺត្រូវតែប្រឈរមុខទៅនឹងការសួរតទល់ទៅនឹងសាក្សីទាំងនេះ។ វាមិនខុសអ្វីដែលពីចម្លើយសារភាពដែលខ្ញុំបានលើកឡើងពីដំបូងនោះទេ ចម្លើយដំបូងនោះទេ។ ប៉ុន្តែរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងនេះក៏មានភ្ជាប់មកជាមួយនូវសក្ខីកម្មដែលមិនអាចនឹងដឹងបានទេ លុះណាតែសាក្សីទាំងនោះត្រូវមកបញ្ជូលមក គឺឯកសារ D369/38 នេះឯង។ យើងខ្ញុំមិនមែនចង់សួរដេញដោលតែទីតាំងទេ ឬក៏កន្លែងធ្វើការមួយណា ថាតើអ្នកណាជាអ្នកគ្រប់គ្រងទៅនោះ?

[១៥:១៣:០៤]

ខ្ញុំមិនទាន់ចង់និយាយឲ្យចំៗឈ្មោះអ្នកធ្វើការនៅការិយាល័យចៅក្រមស៊ើបអង្កេត ដែលកំណត់អត្តសញ្ញាណនោះទេ។ អ្នកខ្លះ គឺគាត់ នៅក្នុងឆ្នាំ៧៥ ទើបតែមានអាយុប្រាំពីរឆ្នាំ ដប់ឆ្នាំ តែប៉ុណ្ណោះឯង។ ដូច្នេះ គាត់មិនអាចមានការចងចាំដោយឯករាជ្យទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងទាំងនោះទេ។ លើកលែងតែអ្នកផ្តល់ចម្លើយទាំងនេះ ចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះដើម្បីធ្វើការសាកសួរ ហើយថាតើខ្លួនធ្លាប់ធ្វើដំណើរពីក្រសួងមួយទៅក្រសួងមួយ? ចងចាំថា ខ្លួនធ្លាប់ធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ពីក្រសួងមួយទៅក្រសួងដោយរបៀបណានោះ? ហើយលើកលែងតែ សាក្សីបែបនេះ គឺថាអាចនឹងផ្តល់ចម្លើយទាក់ទងទៅនឹងអត្តសញ្ញាណទីកន្លែងនេះ។ បើមិនអាចបង្ហាញបែបនេះបានទេ ប្រាកដជាបុគ្គលរូបនេះ អាចសំអាងតែទៅលើឯកសារណាមួយតែប៉ុណ្ណោះ។ ហេតុដូច្នេះ យើងខ្ញុំសុំស្នើថាសាក្សីបែបនេះ គឺស្នើសុំឲ្យចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ ដើម្បីផ្តល់សក្ខីកម្មទៅលើការអះអាងនេះ។ បើមិនដូច្នេះទេ ចម្លើយនេះ មិនអាចគួរឲ្យជឿជាក់បានទេ។

[១៥:១៤:៣០]

ឯកសារទាក់ទងទៅនឹងផែនទី និងរូបថត គឺជាប្រធានបទមួយផ្សេងទៀត។ តាមធម្មតាផែនទី និងរូបថត គឺត្រូវតែមានសុក្រឹតភាព ត្រូវតែមានការបង្ហាញនូវសុក្រឹតភាព នៅពេលមានឧប្បត្តិហេតុទាំងអស់នោះកើតឡើង ទើបអាចទទួលយកបាន។ ដូច្នេះ បើយើងនិយាយអំពីអគារណាមួយ ការថតរូបអគារមួយស្ថិតនៅក្នុងទីតាំងជាក់លាក់ណាមួយនោះ វាមិនពាក់ព័ន្ធជាចាំបាច់នោះទេ។ គោលបំណងដែលដាក់រូបថតទាំងនេះ គឺគ្រាន់តែបង្ហាញថាទីតាំងនេះគឺជាទីតាំង ដែលស្ថិតនៅក្នុងទីកន្លែងជាក់លាក់ណាមួយដែលមានព្រឹត្តិការណ៍បែបនេះកើតឡើងបង្ហាញតែប៉ុណ្ណោះ។

យើងខ្ញុំបានឃើញរូបថតជាច្រើននៃអគារថ្មីៗ ដែលខ្ញុំសង្ស័យថា ហើយប្រហែលជាសហព្រះរាជអាជ្ញាអាចនឹងជម្រាបមកយើងខ្ញុំផង ថាតើគោលបំណងនៃការបង្ហាញអំពីអគារនេះមានរាងពៅ

យ៉ាងណា? ទីតាំងនោះស្ថិតនៅត្រង់ណា? ហើយហេតុអីបានជាបង្កើតអង្គហេតុបែបនេះឡើងនោះ?

[១៥:១៦:០១]

ឯកសារជាក់លាក់មួយ គឺឯកសារ D108/39/8 បាទសូមថាម្តងទៀត D108/39/8 មានចំណងជើងថា “ទីតាំងប្រព្រឹត្តអំពើសម្លាប់មនុស្សចន្លោះពី៧៥ ទៅឆ្នាំ១៩៧៩” ឯកសារដែលរៀបរៀងមកដោយ ស៊ូសាន អ៊ី.ឃុក (Susan E. Cook) និង មេតស៊ូ ផ្លេតឡេន (Matthew Fladeland) ដែលនិយាយឲ្យ-- នៃគម្រោងអំពីការសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ខ្ញុំសូមជំទាស់ទៅលើចរិតលក្ខណៈនៃឯកសារបែបនេះ។ ខ្ញុំសូមអាចផ្នែកខ្លះៗនៃឯកសារនេះ ដើម្បីបង្ហាញជូនដល់អង្គជំនុំជម្រះ ថាហេតុអីឯកសារនេះមិនអាចទទួលយកបាន? ដើម្បីបង្ហាញជូនអង្គជំនុំជម្រះថាសញ្ញាណឲ្យដឹងថាហេតុអីមិនទទួលយកបាន លើកលែងតែអ្នកនិពន្ធទាំងនេះ អ្នករៀបចំរបាយការណ៍ទាំងនេះ ចូលខ្លួនមកបង្ហាញនៅចំពោះមុខតុលាការ។

[១៥:១៧:២២]

ខ្ញុំសូមអាននូវបន្ទាត់ទីមួយ គឺអំពើប្រល័យពូជ-- កម្មវិធីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ស៊ី.ជី.ភី គឺជាគម្រោងចងក្រងអំពើប្រល័យពូជសាសន៍ ដោយមានការគាំទ្រពីសាកលវិទ្យាល័យយែល។ ដូច្នេះយើងឃើញថា ពួកគេបញ្ជាក់ហើយថា ពួកគេជាអ្នកណាវាជាឯកសារចងក្រងអំពីប្រល័យពូជសាសន៍ហើយក៏បានលើកឡើងហើយ ចាប់តាំងពីឆ្នាំ១៩៩៤ មក ស៊ី.ជី.ភី បានធ្វើការដើម្បីចងក្រងឯកសារអំពីឧក្រិដ្ឋកម្មសង្គ្រាម អំពីប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ចន្លោះពី៧៥ ដល់៧៩។

ការចងក្រងឯកសារនេះគឺដើម្បីគាំទ្រទៅដល់ការស៊ើបអង្កេត និងទៅដល់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលវាជាឯកសារពាក់ព័ន្ធទៅនឹងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការរំលោភសិទ្ធិមនុស្សនៅកម្ពុជា។ ហើយខាងក្រោមមកទៀត បាននិយាយថា ចំណុចសំខាន់មួយនៃការស៊ើបអង្កេតនេះ គឺការកំណត់ផែនទី ទីតាំងប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅទូទាំងកម្ពុជាតែម្តង។

[១៥:១៨:៤៩]

លោកប្រធាន លោក លោកស្រីចៅក្រម! កាលណានិយាយអំពើប្រល័យពូជសាសន៍ ខ្ញុំប្រើពាក្យច្បាប់ គឺសំដៅទៅលើពាក្យនយោបាយ ឬក៏ជាពាក្យពេចន៍សង្គម ឬក៏ពាក្យដែលប្រើដោយអ្នកសារព័ត៌មាន ឬអ្នកដែលនយោបាយ។

ការលើកដែលឡើងគឺខ្ញុំគិតទៅដល់បរិបថច្បាប់ ដោយសារតែយើងជាអ្នកច្បាប់។ ផែនទីនេះគឺបង្ហាញអំពីការចុះពិនិត្យទៅលើទីកន្លែងនៃទីតាំងសម្លាប់មនុស្ស ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាង៥០០កន្លែង។ ក្នុងចំណោមខេត្ត២២ នៃខេត្តក្រុងទាំង២៤ នៃប្រទេសកម្ពុជា។ ខ្ញុំមិនចង់លើកឡើងច្រើនតទៅទៀតទេ ក៏ប៉ុន្តែឯកសារនេះ បែបនេះមិនគួរណាទទួលយកទេ។ ប្រសិនណាត្រូវទទួលយកឯកសារបែបនេះ គឺអ្នកនិពន្ធឯកសារនេះ ស៊ូសាន អ៊ី.ឃុក យ៉ាងហោចណាស់អាស័យដ្ឋានរបស់គាត់នៅតាមហ្គោហ្គោលនោះគឺជា គាត់មិនមែន គាត់គឺជានរវិទូ គឺគាត់មិនមែនជាៗអ្នកច្បាប់នោះទេ គាត់ជាអ្នកថតរូបតែប៉ុណ្ណោះ។ ដូច្នេះ បើសិនណាជាគាត់ត្រូវចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ ថាតើគាត់បានទៅពិនិត្យមើលទីតាំងទាំងនេះនៅពេលណា? រកឃើញដោយរបៀបណា? ប៉ុន្តែត្រូវកំណត់ថា គាត់បានកំណត់ថា ទីតាំងទាំងអស់ហ្នឹងជាទីតាំងប្រព្រឹត្តអំពើប្រល័យពូជសាសន៍។ សំណួរនោះ គឺសួរថា ហេតុអ្វីបានជាឯកសារនេះមានការពាក់ព័ន្ធ? ខ្ញុំសូមទុកជូនអង្គជំនុំជម្រះពិចារណា ថាតើឯកសារបែបដូច្នេះពាក់ព័ន្ធឬក៏អត់?

[១៥:២០:៣៦]

ឯកសារមួយទៀត ជាឯកសារដែលគួរឲ្យគត់សម្គាល់ផងដែរ គឺឯកសារ D366/7.1.415។ វាជាសៀវភៅដែលមានរូបថត ដោយមានការធ្វើការបកស្រាយផង មិនមែនតែរូបថតទេ សៀវភៅនេះចងក្រងរូបថត ហើយថែមទាំងផ្តល់ការផ្តល់មតិយោបល់ផ្សេងផង។ ដូច្នេះ អ្វីដែលយើងខ្ញុំស្នើសុំចម្លើយទាំងឡាយណាដែលមិនបានធ្វើសម្បថ គឺមិនត្រូវណាទទួលយកនោះទេ។ ហើយយើងខ្ញុំក៏មិនមានឱកាសទាន់បានសួរអ្នកទាំងអស់នេះ ដែលបានធ្វើការជាផ្តល់ជាមតិយោបល់ ធ្វើជាបទអត្ថាធិប្បាយបែបនេះដែរ។ ដូច្នេះយើងខ្ញុំសូមជំទាស់ សូមស្នើដល់អង្គជំនុំជម្រះ ដើម្បី-- ឯកសារទាំងឡាយណាដែលជាឯកសារបែបធ្វើបទអត្ថាធិប្បាយទៅលើរូបថតមិនត្រូវទទួលយកនោះទេ លើកលែងតែមានការមកបង្ហាញសក្ខីកម្មស៊ីសង្វាក់គ្នា ដូចដែលខ្ញុំបានលើកឡើងជាច្រើនលើកច្រើនសាមកហើយ។

យើងខ្ញុំសូមអធ្យាស្រ័យ លោកប្រធាន ក៏ដូចអង្គជំនុំជម្រះសូម-- ក្រែងលោថាខ្ញុំមានការលើកឡើងម្តងហើយម្តងទៀតអំពីជំហរនៅខាងដើមនេះ។ ខ្ញុំសូមអធ្យាស្រ័យ ក្រែងលោធ្វើប៉ះពាល់ទៅដល់អារម្មណ៍របស់លោក លោកស្រីចៅក្រម ខ្ញុំដឹងថា យើងនឹងបញ្ចប់នៅរសៀលនេះហើយ មុននឹងថ្ងៃលិចទៅនោះ។

[១៥:២២:២៧]

ទាក់ទងទៅនឹងខ្សែអាត់សំឡេងនិងវីដេអូ ប្រភេទឯកសារមួយចំនួនទៀត។ ជំហររបស់ខ្ញុំ ខ្សែអាត់សំឡេងនិងវីដេអូ ឯកសារបែបនេះគឺមិនត្រូវទទួលយកមកទេ លុះត្រាតែបង្ហាញឲ្យឃើញនូវយថាភាព និងភាពគួរឲ្យជឿជាក់បាននៃឯកសារខ្សែអាត់សំឡេង និងវីដេអូបែបនេះ។

បើឯកសារទាំងអស់នេះ វាមានពាក់ព័ន្ធជាប់ រួមជាមួយនឹងចម្លើយរបស់សាក្សី យើងខ្ញុំសូមស្នើថាត្រូវតែមានឱកាសសួរតទល់ជាមួយនឹងសាក្សីដែលត្រូវបានគេសាកសួរនេះ ឬក៏សាក្សីទាំងឡាយណាដែលបានផ្តល់ចម្លើយផ្ទាល់មាត់នៅក្នុងខ្សែវីដេអូបែបនេះ។ ខ្ញុំយល់ឃើញថា ឯកសារប្រភេទនេះសំខាន់មែនទែន កាលណាបង្ហាញខ្សែវីដេអូ ហើយផ្តល់នូវព័ត៌មានណាមួយ គឺថាអាចគេបកស្រាយថា វាជាភស្តុតាងដែលពាក់ព័ន្ធទៅនឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទ។ ទង្វើបែបនេះ វាជាការរំលោភទៅដល់សិទ្ធិរបស់កូនក្តីរបស់យើងខ្ញុំ។ ដូច្នេះយើងខ្ញុំស្នើសុំឲ្យមានការសួរតទល់ទៅដល់សាក្សីបែបនេះ។

[១៥:២៣:៣៩]

ឧទាហរណ៍មួយ គឺឯកសារD323/110/1.149R ខ្ញុំសូមថាឡើងវិញ D232/110/1.1.49R។ មិនមានជាភាសាអង់គ្លេសទេ ឯកសារនេះគឺសូមស្នើឲ្យអង្គជំនុំជម្រះច្រានចោល លើកលែងតែមានការផ្តល់ជាឯកសារផ្លូវការផ្សេងទៀត។ ឯកសារពាក់ព័ន្ធទៅនឹងសាក្សី TCW-536 យើងខ្ញុំមិនសូមលើកឡើងនូវឈ្មោះរបស់សាក្សីរូបនេះទេ នេះជាឧទាហរណ៍មួយដែលខ្ញុំបានលើកឡើងតាំងពីខាងដើមនោះ។ ឧទាហរណ៍ថា អ្នកណាម្នាក់ស្ថិតនៅក្នុងបញ្ជីនៃសាក្សី មុននឹងទទួលយកឯកសារបែបនេះ គឺត្រូវតែកោះខ្លួនសាក្សីរូបនេះ កោះហៅសាក្សីរូបនេះឲ្យចូលខ្លួន ដើម្បីឲ្យបង្ហាញនូវចម្លើយ ក៏ដូចជាវីដេអូ បើអាចធ្វើទៅបាននោះគឺត្រឹមត្រូវ។ បើសាក្សីមិនចូលខ្លួនមកទេនោះ សហព្រះរាជអាជ្ញា ឬក៏ភាគីដែលបានស្នើសុំដាក់ឯកសារបែបនេះ គឺត្រូវដាក់សំណើសុំមួយផ្សេងទៀត ទាក់ទងទៅនឹងការស្នើសុំបែបនេះដោយមានការពន្យល់បន្ថែម។ នេះជាជំហររបស់យើងខ្ញុំ លោក លោកស្រីចៅក្រម។

[១៥:២៥:៣៧]

ប្រភេទឯកសារមួយទៀត គឺទំនាក់ទំនងអន្តរជាតិ។ ចំណុចនេះ ប្រហែលជាខ្ញុំនិយាយម្តងទៀតក៏ថាបាន។ ខ្ញុំបានលើកឡើងដូចជាពេលមុនលម្អិតមកហើយ ឯកសារនេះគឺមិនត្រូវទទួលយកទេ។ តែបើសិនណាទទួលយកឯកសារបែបនេះ គឺត្រូវតែបង្ហាញថាវាមានការស៊ីសង្វាក់គ្នាដោយឯករាជ្យ គឺឯកសារទាំងអស់នេះស៊ីសង្វាក់គ្នា។

ខ្ញុំសូមលើកឧទាហរណ៍មួយគឺ D2-2/1.5.1 គឺពាក់ព័ន្ធទៅនឹងប្រវត្តិរូប។ ជំហររបស់យើងខ្ញុំថា

ឯកសារបែបនេះជាការកំណត់ឈ្មោះវាមិនបានត្រឹមត្រូវទេ វាមិនមែនជាផ្នែកមួយនៃទំនាក់ទំនងអន្តរជាតិនោះទេ។ ឯកសារមួយប្រភេទទៀត គឺឯកសារD366/7.1.191 គឺវាជាឯកសារទាក់ទងទៅនឹងទំនាក់ទំនងអន្តរជាតិ តែតាមពិតគឺជាព្រះរាជក្រឹត្យលើកលែងទោសលោក អៀង សារី ទៅវិញទេ។ យើងមានឃើញឯកសារប្រភេទជាឯកសារទំនាក់ទំនងអន្តរជាតិមានចំនួនប្រាំបីឯកសារ។ ខ្ញុំមិនអាចមានពេលចូលលើកឡើងនូវឯកសារទាំងអស់នេះម្តងមួយៗបានទេ។ ដូច្នេះយើងខ្ញុំសូមស្នើថា ពាក់ព័ន្ធទៅនឹងឯកសារដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ គឺសហព្រះរាជអាជ្ញា គឺមិនត្រូវគ្រាន់តែផ្តល់បញ្ជីឯកសារ ហើយទុកឲ្យមេធាវីជាអ្នកឡើងជំទាស់ទៅលើឯកសារទាំងអស់នោះទេ។

[១៥:២៧:៤៣]

សហព្រះរាជអាជ្ញាខ្លួនឯងនោះ គឺដោយសារថាគាត់ជាភាគីនាំមុខនៅក្នុងការដាក់ឯកសារទាំងអស់នេះ ដើម្បីឲ្យពិនិត្យមើលទៅលើឯកសារនីមួយៗបង្ហាញថា ហេតុអ្វីបានជាឯកសារនីមួយៗមានការជាប់ពាក់ព័ន្ធ ហើយគួរឲ្យជឿជាក់បាន ហើយគួរទទួលយកបាននោះ គឺសហព្រះរាជអាជ្ញាជាអ្នកបង្ហាញទេ។

ទាក់ទងទៅនឹងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានអន្តរជាតិយើងបានពិភាក្សាគ្នាតាំងពីមុនមកម្ល៉េះ។ នេះគឺជាសំណើររបស់យើងខ្ញុំថា ប្រព័ន្ធសារព័ត៌មានបែបនេះ គឺមិនគួរទទួលយកនោះទេ។ ជាពិសេសទាក់ទងឯកសារ យើងមានឯកសារ *ប៊ីប៊ីស៊ី* ឯកសារមកពីកាសែតញូវយ៉កថែមស៍ *ឈីហ្កាហ្គោ* ឯកសារសារព័ត៌មានមួយចំនួន ដែលឯកសារ ឬក៏អត្ថបទសារព័ត៌មានទាំងអស់នេះ វាត្រឹមត្រូវ វាសុក្រឹត ដូច្នេះយើងស្នើសុំថាមិនត្រូវទទួលយកឯកសារទាំងអស់ទេ។ បើទទួលយកលុះណាតែឯកសារទាំងនេះពិនិត្យឃើញថា ពិតជាស៊ីសង្វាក់គ្នាពីប្រព័ន្ធសារព័ត៌មានពីមួយទៅមួយមែន។ ហើយប្រហែលជាឧទាហរណ៍ ឯកសារដែលមានចរិតលក្ខណៈស្រដៀងគ្នាមកពីស្ថានទូតបារាំង មកពីប្រទេសថៃ ឬក៏មកពីប្រទេសដទៃៗទៀត។ ពីព្រោះប្រហែលជាគេអាចស្តាប់ព័ត៌មាននៅក្នុងពេលតែមួយ ក្នុងពេលជាមួយគ្នា ហើយប្រហែលក្រែងលោ-- បើលុះណាតែឯកសារទាំងអស់នោះមកពីប្រភពដែលលើកឡើងគឺវាមានការស៊ីសង្វាក់គ្នា ប្រហាក់ប្រហែលគ្នា វាផ្តល់ទម្ងន់ណាមួយ។ យើងខ្ញុំសូមលើកថា បើសិនជាមិនដូច្នេះទេ អ្នកសារព័ត៌មានទាំងនោះ ត្រូវកោះហៅឲ្យចូលខ្លួនមកតុលាការ ថាតើគេបានឃើញអ្វី? គេបានរាយការណ៍ពីអ្វី? ហើយគេរាយការណ៍មានសុក្រឹតភាពដោយរបៀបណា? ដើម្បីអនុញ្ញាតឲ្យយើងខ្ញុំមានការសួរតទល់ជាមួយអ្នកសារព័ត៌មាន នោះបើ លើកលែងតែវាមានការស៊ីសង្វាក់គ្នាយ៉ាង

សុក្រឹតនោះ។

[១៥:៣០:០០]

ប្រភេទឯកសារមួយទៀត គឺពាក់ព័ន្ធទៅនឹងអត្ថបទស្រាវជ្រាវរបាយការណ៍វិភាគនិងសៀវភៅ។ ខ្ញុំគិតថា ជំហររបស់យើងខ្ញុំច្បាស់លាស់ហើយ សៀវភៅ របាយការណ៍វិភាគ មិនគួរទទួលយកនោះទេ លើកលែងតែអ្នកនិពន្ធចូលមកផ្តល់ជាភស្តុតាង។ ជំហររបស់ខ្ញុំ គឺសាមញ្ញដូច្នេះ។ សៀវភៅភាគច្រើន ដែលសរសេរអំពីសម័យកាល៧៥, ៧៩ ក្រោយពេលនោះ មុនពេលនោះ អ្នកកាសែត អ្នកប្រវត្តិវិទូ អ្នកដែលជាសាក្សីផ្ទាល់ភ្នែកមុនឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ១៩៧៩ គឺអ្នកទាំងអស់នុ៎ង គាត់បាន-- អ្នកសារព័ត៌មាន អ្នកប្រវត្តិសាស្ត្រទាំងអស់ហ្នឹង គឺបានធ្វើការសម្ភាសជាមួយនឹងបុគ្គលផ្សេងៗ ហើយសរសេរចូលក្នុងសៀវភៅ។ ដូច្នេះ យើងខ្ញុំសូមលើកឡើងថា ប្រភេទឯកសារនេះមិនគួរទទួលយកមកទេ លើកលែងតែអ្នកនិពន្ធចូលមកផ្តល់សក្ខីកម្ម ហើយធ្វើការសួរតទៅដោយភាគី។ អ្វីទាំងឡាយដែលបានរៀបចំនៅក្នុងរបាយការណ៍វិភាគដោយសហព្រះរាជអាជ្ញា ត្រូវតែដកចេញដោយស្វ័យប្រវត្តិ លើកលែងតែអ្នករៀបចំនោះចូលមកផ្តល់សក្ខីកម្ម។ ជាពិសេស យើងដឹងហើយអ្នកនិពន្ធគឺគាត់នៅឆ្ងាយរាប់រយម៉ាលពីយើង ហើយយើងមិនអាចចេញលុយឱ្យគាត់មកបាន ទើបយើងមិនអាចកោះហៅគាត់បាន។

[១៥:៣១:៤៤]

ខ្ញុំគិតថា អ្នកដែលរៀបចំរបាយការណ៍សម្រាប់សហព្រះរាជអាជ្ញានោះ ប្រហែលជាផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០១រួចទៅហើយ ឧទាហរណ៍លោក ក្រេក អេតឆេសាន់។ ដូច្នេះហើយ លោក ក្រេក អេតឆេសាន់ គួរតែចូលមកផ្តល់សក្ខីកម្មអំពីរបាយការណ៍វិភាគនេះផងដែរ។

ខ្ញុំសូមលើកឡើងវិញ ថយក្រោយបន្តិច។ ឯកសារនៅក្នុងសំណុំរឿង០០១ ឬក៏របាយការណ៍វិភាគរបស់សហព្រះរាជអាជ្ញា ជាពិសេសបុគ្គលដែលមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០១ នោះលើកលែងតែគាត់មិនផ្តល់សក្ខីកម្ម។ យើងមិនមែនជាភាគីនៅក្នុងសំណុំរឿង០០១ នោះទេ។ មេធាវីការពារក្តី ឌុច ប្រហែល ឬក៏មិនបានធ្វើការ-- កិច្ចការមួយចំនួនសម្រាប់លោក ឌុច។ ហើយហេតុដូច្នេះ ហើយយើងមិនគិតថាមិនសមស្រប ចំពោះការលើកលែងរបស់ខ្ញុំពាក់ព័ន្ធទៅនឹងបញ្ហានេះទេ។

ប្រភេទឯកសារចុងក្រោយ គឺរបាយការណ៍ស្តីពីដីកាចាត់ឱ្យស៊ើបសួរជំនួស ដូចដែលខ្ញុំលើកឡើងកំណត់សម្គាល់របស់ខ្ញុំកាលពីមុន របាយការណ៍ស្តីពីដីកាចោទចាត់ឱ្យសួរជំនួសហ្នឹង គឺវារួមទាំង

សេចក្តីប្រកាសរបស់សាក្សីដែលធ្វើឡើងដោយស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតផងដែរ។

[១៥:៣៣:១៨]

ដូច្នេះវាមិនមែនជារបាយការណ៍ដែលអ្នកស៊ើបអង្កេតធ្វើឡើងនៅតាមខេត្តនោះទេ គឺគាត់ភ្ជាប់ទៅនឹងសេចក្តីប្រកាស និងកិច្ចសម្ភាសន៍មួយចំនួនផងដែរ។ របាយការណ៍នោះ គឺរួមទាំងសេចក្តីសង្ខេបចម្លើយរបស់សាក្សី ឬក៏រួមមានសេចក្តីអង្កេតដោយវិភាគ ដោយសហចៅក្រមស៊ើបអង្កេត។ ដូច្នេះយើងខ្ញុំសូមលើកឡើងថា របាយការណ៍បែបនេះ មិនគួរទទួលយកមកនោះឡើយ ប្រសិនបើទទួលយកមកនោះ លើកលែងតែអ្នករៀបចំរបាយការណ៍នោះចូលមកផ្តល់សក្ខីកម្មក្នុងតុលាការ។ ឧទាហរណ៍ D91/29 រួមទាំងអត្តសញ្ញាណរបស់សាក្សី ហើយនិងកិច្ចសម្ភាសន៍របស់សាក្សីចំនួនបួននាក់ទៀតផងដែរ។ ដូច្នេះប្រសិនបើយើងទទួលយករបាយការណ៍សេចក្តីពីដីកាចាត់ឱ្យសួរជំនួសនោះ លោក លោកស្រីចៅក្រម សេចក្តីប្រកាសយើងទទួលយកមកដាក់ចូលឯកសារ ហើយសាក្សីមិនមកផ្តល់សក្ខីកម្មនោះទេ។ ហើយប្រសិនបើយើងយករបាយការណ៍ដែលរៀបចំដោយសហចៅក្រមស៊ើបអង្កេតនោះ យើងធ្វើយ៉ាងម៉េចឱ្យមានមូលដ្ឋានចំពោះរបាយការណ៍ដែលរៀបចំឡើងដោយសហចៅក្រមស៊ើបអង្កេត។

សហមេធាវីការពារក្តីមិនអាចគាត់មើលគ្រប់ឯកសារទាំងអស់ ដើម្បីបង្ហាញ ដើម្បីព្យាយាមបង្ហាញ ថាតើរបាយការណ៍ទាំងអស់នេះគឺបានដាក់បញ្ចូលយកគ្រប់ចំណុចទាំងអស់ ដែលមិនមានការពិចារណាទៅខាងការពារក្តី ឬក៏យ៉ាងម៉េច?

[១៥:៣៥:១៣]

ឯកសារមួយទៀត គឺD91/27។ ឯកសារនេះ រៀបរាប់អំពីការពាក់ព័ន្ធតួនាទីរបស់លោក អៀង សារី។ ឯកសារនេះ គឺជាកិច្ចសម្ភាសន៍ ជាសេចក្តីប្រកាស ហើយវាលើកឡើងអំពីទង្វើ និងអំពើសកម្មភាពរបស់លោក អៀង សារី។ ដូច្នេះ ប្រសិនបើយើងអនុញ្ញាតយកឯកសារនេះមកបញ្ចូលនោះ ដោយមិនយកបុគ្គលដែលត្រូវបានគេសម្ភាសមកដេញដោលតទល់នោះទេ ដូច្នេះវានឹងរំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការតទល់ជាមួយនឹងសាក្សី។

និយាយដោយត្រង់ទៅ ខ្ញុំសូមនិយាយសារភាពថា របាយការណ៍ស្តីដីកាចាត់ឱ្យសួរជំនួសនេះ ខ្ញុំមិនដឹងថាតើយកមកធ្វើជាភស្តុតាងយ៉ាងម៉េចនោះទេ? ប្រសិនបើយកមកធ្វើភស្តុតាងនោះ គឺវាជាចម្លើយរបស់បុគ្គលជាសាក្សីមួយចំនួន ហើយបើសិនដូច្នេះនោះ ភាគីដែលស្នើសុំដាក់របាយការណ៍នេះគួរតែស្នើសុំបញ្ចូលសាក្សីមកផងដែរ។ យើងមិនចាំបាច់យកសេចក្តីសង្ខេបរបស់សាក្សីនោះមកដាក់

បញ្ចូលឡើយ។ តើទម្ងន់ប៉ុនណា? តម្លៃប៉ុនណា ដែលរបាយការណ៍ស្តីពីដីកាចាត់ឲ្យសួរជំនួសនេះមានតម្លៃនោះ? អ្វីដែលសហព្រះរាជអាជ្ញាព្យាយាមធ្វើនោះ គឺថាព្យាយាមលួចដាក់បញ្ចូលនូវឯកសារតាមរយៈរបាយការណ៍ប្រភេទនេះ។

ខ្ញុំមិនមែនលើកឡើង អ្វីដែលរៀបចំឡើងដោយសហចៅក្រមស៊ើបអង្កេតមិនអាចបង្ហាញនោះទេ ក៏ប៉ុន្តែពេលខ្លះ យើងមិនអាចឲ្យឯកសារប្រភេទនេះបញ្ចូលមកក្នុងសំណុំរឿងរបស់យើងនោះទេ។ នេះជាអ្វី ជាជំហររបស់យើងខ្ញុំពាក់ព័ន្ធទៅនឹងរបាយការណ៍ស្តីពីដីកាចាត់ឲ្យសួរជំនួស។

[១៥:៣៧:១៧]

ប្រធានបទមួយទៀត គឺខ្ញុំសូមលើកឡើងអំពីឯកសាររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំបញ្ចប់-- អម្បាញ់មិញខ្ញុំបញ្ចប់ឯកសាររបស់សហព្រះរាជអាជ្ញារួចហើយ ហើយខ្ញុំគិតថា ខ្ញុំនឹងបញ្ចប់មុនពេលវេលាបញ្ចប់របស់យើងនៅថ្ងៃនេះ ដបនាទី។ ខ្ញុំយល់ថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបញ្ហាពាក់ព័ន្ធទៅនឹងការបកប្រែ ហើយខ្ញុំគាំទ្រការលើកឡើងរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងបញ្ហានេះផងដែរ។ ក៏ប៉ុន្តែប្រសិនបើយើងមើលទៅលើឯកសារមួយចំនួនដែលបានបង្ហាញ ខ្ញុំនឹងចូលទៅលើ-- ចូលលើកឡើងទៅលើឯកសារទាំងនេះមួយចំនួន។ ខ្ញុំនឹងលើកឡើងឯកសារនេះមួយចំនួន។

ឯកសារមួយ ទំនងបង្ហាញឲ្យយើងឃើញថា វាជាឯកសារមួយរៀបចំដោយ*ស្មូខិន* នៅសាកលវិទ្យាល័យយ៉ៃល គឺឯកសារ E250/3.7។ គឺពាក់ព័ន្ធទៅនឹងអំពើនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ៧៥ ដល់ ៧៩ ដោយ ខេមីម៉ាក ហើយបុគ្គលនេះ គឺជានិស្សិតម្នាក់ថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យយ៉ៃល។

[១៥:៣៩:០១]

នៅពេលដែលយើងមើលសៀវភៅរបស់លោក ឃៀរនិន "Blood and Soil" ដែលសៀវភៅនេះ និយាយអំពីបញ្ហាប្រល័យពូជសាសន៍ វាបង្ហាញឲ្យយើងឃើញថា ប្រធានបទនៅក្នុងសេចក្តីផ្តើមនៃលិខិត ឬក៏ឯកសារមួយនេះ ដែលពាក់ព័ន្ធទៅនឹងនិក្ខេបបទរបស់លោក ឃៀរនិន ពាក់ព័ន្ធទៅនឹងលោក ឃៀរនិន។ នៅពេលដែលយើងមើលសេចក្តីផ្តើមឯកសារនេះ ចាប់ផ្តើមដោយលើកឡើងថា បទប្រល័យពូជសាសន៍ គ្រីស្តូហ្វឺ និយាយអំពីការជជែកវែកញែកអំពីអ្នក*អ៊ុនធិនស្បូណលលីស* និង*ហ្វាំងស្បូណលលីស* នៅក្នុងសម័យសោកនាដកម្ម។ បន្ទាប់មក គេព្យាយាមធ្វើការប្រៀបធៀបរវាងលោក ហ៊ីត្លែរ នៅ

ប្រទេសអាល្លឺម៉ង់ និងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៥:៤០:០២]

ដូច្នេះ យើងខ្ញុំមានចម្ងល់ ថាតើឯកសារនេះវាស៊ីសង្វាក់យ៉ាងម៉េចទៅនឹងសំណុំរឿង០០២ ហើយថាតើឯកសារនេះជាភស្តុតាងយ៉ាងម៉េច? វាជាឯកសាររៀបចំឡើងដោយនិស្សិតម្នាក់ចេញមកពីសាកលវិទ្យាល័យល្បីមួយ ក៏ប៉ុន្តែខ្ញុំសូមសួរថាហេតុអ្វីឯកសារមួយនេះចាំបាច់យកមកដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២ ហើយប្រសិនបើយើងទទួលយកឯកសារមួយនេះ។ ដូច្នេះ យើងត្រូវតែចាត់បុគ្គលនេះចាត់ទុកបុគ្គលនេះថាជាប្រវត្តិវិទូ ហើយនិងជាអ្នកជំនាញ ហើយយើងត្រូវតែមានសិទ្ធិធ្វើការដេញដោលតទល់ជាមួយនឹងបុគ្គលរូបនេះ។ ហេតុដូច្នេះ យើងខ្ញុំសូមជំទាស់ទៅនឹងឯកសារមួយនេះ។ វាជាឧទាហរណ៍មួយល្អ។

ឯកសារឧទាហរណ៍មួយទៀត គឺ D250/6/3.36, D250/3/3.36 ការជំនុំជម្រះខ្មែរក្រោម និងសវនាការខ្មែរក្រហម ថាតើវាពាក់ព័ន្ធទៅនឹងសំណុំរឿង១ក្តីយើងយ៉ាងម៉េច? អ្នកណាជាអ្នករៀបចំឡើង? ជាមន្ត្រីទីប្រឹក្សាច្បាប់នៅ ឌី.ស៊ី.ខេម បុគ្គលម្នាក់ដែលគាត់តែងតែផ្សព្វផ្សាយ ឌី.ស៊ី.ខេម ហើយតែងតែផ្តល់នូវមតិយោបល់ផ្នែកច្បាប់នៅក្នុងប្រទេសនេះ។ គាត់ជាអ្នកលម្អៀងមួយរូប យើងខ្ញុំសូមលើឡើងដូច្នេះ។

[១៥:៤១:៥១]

ប្រសិនបើយើងមើលកថាខណ្ឌទីមួយ ដែលវាជាអារម្ភកថា ដែលក្នុងនោះលើកឡើងថា នៅក្នុងអត្ថបទនេះ ខ្ញុំបានពិនិត្យឡើងវិញដោយសង្ខេបទៅលើប្រជាជនខ្មែរក្រោម ហើយសួរសំណួរផ្នែកច្បាប់ដែលពាក់ព័ន្ធទៅនឹងនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)៖ ថាតើការកាប់សម្លាប់របស់ខ្មែរក្រហមទៅលើខ្មែរក្រោមមានភាពខុសគ្នាទៅនឹងប្រជាជនផ្សេងទៀតដែរឬទេ?

ខ្ញុំសូមបញ្ជាក់ថាឲ្យបានច្បាស់លាស់ ជំហររបស់មេធាវីការពារក្តី អៀង សារី បញ្ជាក់យ៉ាងច្បាស់ទៅលើចំណុចនេះ។ ជំហររបស់យើងខ្ញុំនោះ គឺថាការជំនុំជម្រះទាំងឡាយនៅចំពោះមុខ អ.វ.ត.ក គឺត្រូវតែជំនុំជម្រះឲ្យបានអស់គ្រប់ជ្រុងជ្រោយសម្រាប់ភាគីជំនុំជម្រះ ទាំងសម្រាប់ភាគីសហព្រះរាជអាជ្ញា និងភាគីដទៃទៀត ហើយសម្រាប់ឲ្យអង្គជំនុំជម្រះពិចារណា។ ចៅក្រម គឺមានអំណាចឯករាជ្យ ហើយជាអ្នកសម្រេច។

[១៥:៤៣:១៩]

ដូច្នេះ យើងមិនព្យាយាមដកចេញនូវក្រុមណាមួយជាក់លាក់នោះទេ យើងក៏មិនចង់ធ្វើឱ្យជនរងគ្រោះមួយចំនួនក្លាយជាជនរងគ្រោះផងដែរ ហើយយើងក៏មិនចង់ដកចេញជនរងគ្រោះណាមួយចេញពីនីតិវិធីនោះផងដែរ។ ក៏ប៉ុន្តែ អ្វីដែលយើងលើកឡើងអត្ថបទមួយនេះ គឺវាមិនពាក់ព័ន្ធ ហើយវាមិនជាប់ទាក់ទងទៅនឹងរឿងក្តី០០២/០១ ក៏ប៉ុន្តែវាអាចពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីណាមួយផ្សេងនៅពេលក្រោយ។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំមើលឯកសារកថាខណ្ឌនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីពិចារណាទៅលើអត្ថបទមួយដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ គឺយើងឃើញថាអត្ថបទអម្បាញ់មិញដែលខ្ញុំលើកឡើងនេះ គឺវាមិនពាក់ព័ន្ធទៅនឹងសវនាការរបស់យើងនោះទេ។

[១៥:៤៤:១៨]

ឯកសារមួយទៀត គឺ D366/7.1.76 ឯកសារនេះមានចំណងជើងថា "ការបះបោរនៅសំឡូត និងផលវិបាកកើតចេញពីពេលនោះ ឆ្នាំ១៩៦៧ ទៅដល់ឆ្នាំ ១៩៧០ ចលនានៅក្នុងប្រទេសកម្ពុជា" ផ្នែកទីមួយ សរសេរឡើងដោយ ឃៀវនិន។

ជាថ្មីម្តងទៀត ដូចដែលខ្ញុំបញ្ជាក់ការពីពេលមុន នេះជាឯកសារស្រាវជ្រាវតែប៉ុណ្ណោះដែលបានដាក់បញ្ចូល។ លើកលែងតែវាពាក់ព័ន្ធទើបយើងអាចទទួលយកបាន ហើយលើកលែងតែអ្នកនិពន្ធអ្នកសរសេរនោះចូលមកផ្តល់សក្ខីកម្ម ហើយតទល់គ្នា ទើបយើងអាចទទួលយកបាន។ យើងខ្ញុំទុកឱ្យអង្គជំនុំជម្រះជាអ្នកសម្រេចកិច្ចដំណើរការនីតិវិធីនៅចំពោះមុខយើងទាំងអស់គ្នា ក៏ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ទៅលើចំណុចហ្នឹង។ យើងក៏មានឯកសារមួយទៀតផងដែរ ដែលសរសេរឡើងដោយអ្នកនិពន្ធដដែលនេះ គឺឯកសារ D250/3.212 ឯកសារនេះពាក់ព័ន្ធទៅនឹងការរស់រានមានជីវិតនៃវប្បធម៌ ហើយនៅចុងក្រោយនេះយើងយល់ឃើញថា លោក ឃៀវនិន គាត់បានបោះពុម្ពផ្សាយឯកសារនេះក្រោយពីឆ្នាំ១៩៩០។

[១៥:៤៦:០៥]

ដូច្នេះយើងខ្ញុំសូមបញ្ជាក់ថា ឯកសារមួយនេះ គឺមិនពាក់ព័ន្ធ បើមិនដូច្នោះទេ អ្នកនិពន្ធត្រូវតែចូលខ្លួនមកតទល់។ ចំណុចនេះ គឺដូចគ្នាទៅនឹងឯកសារ D250/3.329 គឺ D250/2.350 ឯកសារនេះគឺពាក់ព័ន្ធទៅនឹងខ្សែវីដេអូ អំពីជនជាតិវៀតណាម និងបញ្ហានយោបាយ។ លោក លោកស្រីចៅក្រមជាទីគោរព នៅពេលដែលលោក លោកស្រីចៅក្រមពិនិត្យមើលឯកសារទាំង១០ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមដាក់បញ្ចូល។ យើងខ្ញុំសូមលើកឡើងដោយគោរពថា ឯកសារទាំងអស់នោះ

ត្រូវតែមានភាពពាក់ព័ន្ធយ៉ាងជាក់ស្តែង និងពិតប្រាកដទៅនឹងកថាខណ្ឌដែលអង្គជំនុំជម្រះបានចង្អុលបញ្ជាក់ ហើយដែលវាពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១។

[១៥:៤៧:១៨]

ដូច្នេះហើយយើងខ្ញុំសូមលើកឡើងថា ឯកសារទាំងអស់ ទាំង១០នោះ គឺវាមិនពាក់ព័ន្ធនោះឡើយ។ ពាក់ព័ន្ធទៅនឹងឯកសារដែលបានដាក់ជូនដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ក្រុមមេធាវីការពារក្តីបានលើកឡើង សូមដាក់បញ្ចូលឯកសារចំនួន៧៨។ ឯកសារមួយក្នុងចំណោមនោះ គឺយើងសូមជំទាស់ គឺឯកសារស្តីអំពីការសម្ភាស អៀង ធីរិទ្ធ ដោយ អេលីហ្សាប៊ែត បេកយ័រ ឯកសារ D108/5.1,D28។ ដូច្នេះ យើងខ្ញុំសូមលើកឡើងថា ពាក់ព័ន្ធទៅនឹងឯកសារមួយនេះ ដោយសារតែ អៀង ធីរិទ្ធ គាត់មិនជា មិនមែនជាជនជាប់ចោទនៅក្នុងសំណុំរឿងនេះទៀតទេ យើងត្រូវតែប្រុងប្រយ័ត្នទៅលើឯកសារ។ ជាពិសេសក្នុងការតទល់ទៅលើសាក្សីមួយចំនួន ជាពិសេសចំពោះសាក្សីទាំងឡាយដែលចូលមកដាក់បន្ទុកទៅលើលោកស្រី អៀង ធីរិទ្ធ។ នេះគឺជាជំហររបស់យើងខ្ញុំ។

[១៥:៤៨:៥៥]

យើងខ្ញុំទុកឆន្ទានុសិទ្ធិឱ្យអង្គជំនុំជម្រះ ជាអ្នកសម្រេចទៅលើឯកសារផ្សេងទៀតដែលបានដាក់ជូនដោយមេធាវីការពារក្តីលោក ខៀវ សំផន ថាតើទទួលយកបាន ឬក៏យ៉ាងណានោះ? សៀវភៅដោយ យៀវនិន, ឆេនដ៏ល័រ និងសៀវភៅផ្សេងទៀត ឬក៏និក្ខេបបទរបស់លោក ខៀវ សំផន។ ការទទួលយកឯកសារឯកសារ សៀវភៅទាំងអស់នេះ ភាគីគួរតែមានសិទ្ធិក្នុងការតទល់ទៅលើបុគ្គលដែលរៀបចំសៀវភៅទាំងអស់នេះ។ នេះគឺជាជំហររបស់យើងខ្ញុំ។ ខ្ញុំបានសន្យាជាមួយនឹងអង្គជំនុំជម្រះរួចហើយថា ខ្ញុំនឹងបញ្ចប់មុនដប់នាទី។ ខ្ញុំមិនមានអ្វីបន្ថែមទៀតទេ។ ខ្ញុំសូមអរគុណច្រើន។

[១៥:៤៩:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះហើយ ប៉ុន្តែមុននឹងសម្រាកអង្គជំនុំជម្រះសូមជម្រាបជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ តាមកាលវិភាគដែលបានគ្រោងទុក គឺត្រូវធ្វើនៅរសៀលថ្ងៃស្អែកទេ ប៉ុន្តែឥឡូវពេលវេលាបានលឿនទៅមុខ ដោយសារនៅរសៀលនេះ យើងធ្វើបានរហូតទៅដល់ពីរក្រុមនៅក្នុងការជំទាស់ទៅនឹងឯកសារដែលដាក់ដោយភាគីសហព្រះរាជអាជ្ញា ហើយនិងសហមេធាវីនាំមុខតំណាង

ដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹងគឺសូមជម្រាបថាស្អែកព្រឹកឡើង គឺដល់ពេលលោកដែលត្រូវធ្វើសេចក្តីថ្លែងការណ៍ និងសេចក្តីជំទាស់របស់ខ្លួន។

ហើយបញ្ហាមួយទៀត គឺអង្គជំនុំជម្រះសូមជម្រាបជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ថាការដែលសុំដាក់ការជំទាស់ទៅលើឯកសារជាលាយលក្ខណ៍អក្សរ ដែលក្រុមមេធាវីមានបំណងដាក់ជូនអង្គជំនុំជម្រះនៅថ្ងៃស្អែកនោះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើដូច្នេះទេ។ ដោយហេតុថា ក្រុមមេធាវីការពារក្តីលោក នួន ជា មានពេលវេលាគ្រប់គ្រាន់នៅក្នុងការធ្វើសេចក្តីជំទាស់ដោយផ្ទាល់មាត់នៅក្នុងសវនាការនៅវសៀលនេះ តែក្រុមមេធាវីការពារក្តីមិនបានប្រើប្រាស់ពេលវេលាដែលបានចែកជូននេះឲ្យអស់លទ្ធភាពទេ។

[១៥:៥១:២៨]

បញ្ហាទីពីរ ក៏សូមជម្រាបជូនដល់ទៅក្រុមមេធាវីការពារក្តី នួន ជា ផងដែរ ដែលបានស្នើសុំដល់អង្គជំនុំជម្រះឲ្យចេញសេចក្តីណែនាំឲ្យមានការពិភាក្សា អំពីការវាយតម្លៃភស្តុតាង។ អង្គជំនុំជម្រះសូមជម្រាបទៅក្រុមមេធាវីការពារក្តី នួន ជា ថាអង្គជំនុំជម្រះមិនចេញសេចក្តីណែនាំបែបនេះនោះឡើយ។ គូភាគីអាចលើកឡើងនូវសេចក្តីវិភាគ វាយតម្លៃភស្តុតាងនៅក្នុងនីតិវិធីសវនាការ ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលជាការអនុវត្តតាមវិធាន៩៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

ឥឡូវនេះ អង្គជំនុំជម្រះសូមប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅថ្ងៃស្អែក ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកតទៅ។ ហេតុដូច្នេះសូមឲ្យ សូមភាគី និងសាធារណជនជ្រាប។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីនាក់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ត្រឡប់មកកាន់សាលសវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំណត់។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥២ នាទី)*